សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបគតិយុត្ត នៃម៉ាកក្នុងបរិបទច្បាប់កម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ប៉ូ គឹមសាន់**
**កែវ រក្សា**

សាស្រ្តាចារ្យណែនាំ
លោក **ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ម៉ូ គឹមសាន់** និងខ្ញុំបាទឈ្មោះ **កែវ រក្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចសូមសម្ដែងនូវកតញ្ញូតាធម៌និងការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោក ឪពុកឈ្មោះ **មាស ម៉ូ**, **កែវ សុខ** និងអ្នកម្ដាយឈ្មោះ **ទូចគឹមលី**, **ស សាន** ដ៏មានគុណទាំងបួនដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុងដល់យើងខ្ញុំទាំងពីរនាក់តាំងពី ចាប់កំណើតរហូតដល់ធំដឹងក្ដីពេញរូបពេញរាង។ លោកទាំងពីរនាក់តែងតែយកចិត្តទុកដាក់ ពុះពារគ្រប់ឧបសគ្គ ដើម្បីផ្គត់ផ្គង់ទាំងមិនគិតពីសុខទុក្ខ លំបាករបស់ខ្លួនឯងធ្វើយ៉ាងណាឱ្យកូនបានទទួលការអប់រំឱ្យមានចំណេះដឹង និងមានចំណេះដឹងមកដល់សព្វថ្ងៃ។ បើគ្មានអ្នកមានគុណទាំងពីរ យើងទាំងពីរនាក់ក៏មិនទទួលបានអ្វីៗមកដល់សព្វថ្ងៃដែល ព្រហ្មវិហារធម៌ និងឧបការគុណរបស់អ្នកទាំងពីរពិតមានតម្លៃណាស់មិនអាចកាត់ថ្លៃបានឡើយ។

ឯកឧត្ដមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ប្រធានដេប៉ាតឺម៉ង់ អនុប្រធានដេប៉ាតឺម៉ង់ និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

លោក លោកស្រីដែលជា សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន និងអប់រំឱ្យយើងខ្ញុំទាំងពីរនាក់ ក៏ដូចជានិស្សិតទាំងអស់ឱ្យមានចំណេះដឹង ដើម្បីចូលរួមចំណែកកសាងធនធានមនុស្ស និងកសាងប្រទេសជាតិនាថ្ងៃមុខ។ ជាពិសេសលោកគ្រូ សាស្ត្រាចារ្យ **ឌិន វណ្ណារ៉ា** ប្រធានដេប៉ាតឺម៉ងនីតិសាធារណៈ និងជាសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀន អប់រំទូន្មានបង្ហាញណែនាំផ្លូវដ៏ល្អសម្រាប់ពួកយើង ព្រមទាំងណែនាំក្រុមយើងខ្ញុំទាំងពីរនាក់ ក្នុងការសរសេរអត្ថបទសារណា ស្រាវជ្រាវនេះដោយបានផ្ដល់នូវគំនិត និងវិធីសាស្ត្រតាំងពីដើមរហូតបានសម្រេចជាលទ្ធផល។ នូវសេចក្ដីដឹងគុណនេះពួកយើងទាំងពីរនាក់សូមធ្វើការបួងសួង ដល់វត្ថុសាកសិទ្ធិទាំងអស់នៅក្នុងពិភពលោក សូមជួយថែរក្សាការពារ លោកសាស្ត្រចារ្យ ព្រមទាំងក្រុមគ្រួសារទទួលបាន នូវសេចក្ដីសុខ សេចក្ដីចម្រើន ព្រមទាំងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាកខានឡើយ។

# អារម្ភកថា

ខ្ញុំបាទឈ្មោះ **ម៉ូ គឹមសាន់** និងខ្ញុំបាទឈ្មោះ **កែវ រក្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ច មានកិត្តិយសដ៏ថ្លៃថ្លា និងមិនអាចកាត់ថ្លៃបាននៅក្នុងឱកាសដ៏វិសេសវិសាលនេះក្នុងការតាក់តែង និងស្រាវជ្រាវប្រធានបទមួយ នៃសារណាបញ្ចប់ការសិក្សាស្តីពី "**របបគតិយុត្តនៃម៉ាកក្នុងបរិបទច្បាប់កម្ពុជា**" ដែលជានីតិវិធីសាស្ត្រមួយនៃការយល់ដឹងក្នុងបង្កើត អ្វីមួយដែលជាស្នាដៃរបស់ខ្លួនព្រមទាំងសិទ្ធិក្នុងការប្រើប្រាស់ និងការការពារផលិតផលដែលជាម៉ាកសញ្ញារបស់ខ្លួនស្របទៅតាមនីតិរដ្ឋ។ ជាការពិតណាស់ របបគតិយុត្តនៃម៉ាកក្នុងបរិបទច្បាប់កម្ពុជា ជានីតិវិធីមួយដែលមានលក្ខណៈស្មុគស្មាញបន្តិច។ កត្តានេះហើយដែលជាជំរុញទឹកចិត្ត យើងខ្ញុំឱ្យមានសេចក្តីក្លាហាន មោទនភាព និងហ៊ានពុះពារក្នុងការលើកយកប្រធានបទនេះមក ចងក្រងឡើងជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំដើម្បីទុកជាស្នាដៃសម្រាប់ខ្លួនឯង និងសម្រាប់ជាស្នាដៃសម្រាប់និស្សិតជំនាន់ក្រោយផង។

ក្នុងនាមជានិស្សិត ការឃ្លាតចាកចេញពីសាកលវិទ្យាល័យដែលជាលំនៅឋានទីពីររបស់ខ្លួន តើខ្ញុំបាទគួរតែបន្សល់ទុកអ្វីសម្រាប់ជាស្នាដៃ? ក៏ដូចជាអានុស្សាវរីយ៍សម្រាប់សាកលវិទ្យាល័យដែលបានខិតខំផ្តួចផ្តើមអប់រំ ផ្តល់កន្លែងសិក្សារយៈពេលបួនឆ្នាំសម្រាប់យើងខ្ញុំ ដើម្បីធ្វើជាទុនចំណេះដឹងក្នុងការប្រកបរបរចិញ្ចឹមជីវិតទៅអនាគត និងបង្កើនធនធានមនុស្សនៅកម្ពុជាបន្ថែម។ ដូច្នេះអ្វីដែលសាកសម និងការតបស្នងក្នុងការតម្កល់ទុកនោះគឺស្នាដៃសារណានេះហើយជាចំណងដៃជូនចំពោះសាកលវិទ្យាល័យ។

យើងខ្ញុំសូមអភ័យទោសផងដែរ នូវរាល់កង្វះខាត និងកំហុសឆ្គងដែលអាចកើតមានឡើងដោយប្រការណាមួយ ហើយខ្ញុំបាទសូមទទួលយក ដោយសេចក្តីរីករាយនូវមតិកែលំអក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋានដើម្បីបំពេញចំណុចខ្វះខាតដោយប្រការណាមួយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............ ១

## ជំពូកទី១
## សញ្ញាណគតិយុត្តនៃម៉ាក

**ផ្នែកទី១៖ បញ្ញាត្តិទូទៅ** ............ ៤

**កថាខណ្ឌទី១៖ សញ្ញាទូទៅនៃម៉ាក និងពាណិជ្ជនាម** ............ ៤

ក. និយមន័យនៃម៉ាក ............ ៥

ខ. ប្រភេទនៃម៉ាក ............ ៥

គ. ពាណិជ្ជនាម ............ ៦

**កថាខណ្ឌទី២៖ លក្ខណៈបង្ហាញនៃម៉ាក និងពាណិជ្ជនាម** ............ ៧

ក. ប្រភេទសញ្ញាដែលមើលឃើញនានា ............ ៧

ខ. ម៉ាកដែលមានលក្ខណៈគ្រប់គ្រាន់ ............ ៨

គ. ភាពមិនទំនេរចំពោះម៉ាក ............ ៩

**កថាខណ្ឌទី៣៖ ឯកទេសកម្មនៃម៉ាក** ............ ៩

ក. សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ............ ១០

ខ. រយៈពេលនៃសិទ្ធិប្រើប្រាស់ម៉ាក ............ ១០

គ.ម៉ាកត្រូវមានលក្ខណៈមិនផ្ទុយនិងទំនៀមទំលាប់ប្រពៃណី ............ ១០

## ជំពូកទី២
## នីតិវិធីចុះបញ្ជីម៉ាក និងលក្ខណៈសម្បត្តិទទួលបានការការពារម៉ាក

**ផ្នែកទី១៖ នីតិវិធីនៃការចុះបញ្ជីម៉ាក** ............ ១២

**កថាខណ្ឌទី១៖ការដាក់ពាក្យស្នើសុំចុះបញ្ជី** ............ ១៣

ក. អ្នកដាក់ពាក្យស្នើសុំ ........................................................................................................ ១៣
ខ. សំណុំឯកសារចាំបាច់ក្នុងការស្នើសុំ ........................................................................................ ១៣
គ. មន្ត្រីមានសមត្ថកិច្ចក្នុងការចុះបញ្ជីម៉ាក .................................................................................. ១៤
**កថាខណ្ឌទី២៖ ការត្រួតពិនិត្យ និងការសម្រេចលើពាក្យស្នើសុំ** ................................ ១៥
ក. មូលដ្ឋាននៃការត្រួតពិនិត្យ........................................................................................................ ១៥
ខ. ការត្រួតពិនិត្យលើភាពគ្រប់គ្រាន់នៃឯកសារស្នើសុំចុះបញ្ជី .................................................... ១៦
គ. ការត្រួតពិនិត្យលើភាពស្របច្បាប់នៃខ្លឹមសារម៉ាក ........................................................................ ១៦
ឃ.ការបដិសេធពាក្យស្នើសុំ ............................................................................................................ ១៧
ង. លទ្ធភាពប្ដឹងទាស់ និងសេចក្ដីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី .................................................. ១៨
ច. ការយល់ព្រមចុះបញ្ជី ................................................................................................................. ១៨
ឆ. កាតព្វកិច្ចប្រកាសផ្សាយ ............................................................................................................. ១៩
ជ. នីតិវិធីនៃប្ដឹងជំទាស់.................................................................................................................. ២០
**ផ្នែកទី២៖លក្ខណៈសម្បត្តិទទួលបានការការពារម៉ាក**............................................................ ២០
**កថាខ័ណ្ឌទី១៖ សិទ្ធិដែលទទួលតាមរយៈការការពារម៉ាក** ...................................................... ២០
**កថាខ័ណ្ឌទី២៖ គោលការណ៍ការពារតាមទំហំដែនដីនៃម៉ាក** ................................................ ២១
ក. ម៉ាកដែលត្រូវបានហាមឃាតក្រោមច្បាប់ជាតិ ................................................................................ ២១
**កថាខណ្ឌទី៣៖អនុភាពនៃការចុះបញ្ជីម៉ាក** ............................................................................ ២២
**ផ្នែកទី៣៖ វិធានគតិយុត្តកម្ពុជាដែលទាក់ទងទៅ និងម៉ាកក្នុងក្របខណ្ឌអន្តរជាតិ**. ២២
**កថាខណ្ឌទី១៖ សិទ្ធិ និងលក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីម៉ាក**.......................................... ២២
ក. សិទ្ធិក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក .................................................................................. ២២
ខ. ឯកសារ ឬលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្របខណ្ឌអន្តរជាតិ ២៣
គ. កម្រៃដាក់ពាក្យ............................................................................................................................. ២៤
ឃ. កម្រៃចុះបញ្ជីម៉ាកអន្តរជាតិ.......................................................................................................... ២៤
**កថាខណ្ឌទី២៖ នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ**...................................................... ២៤
ក. ការត្រួតពិនិត្យពាក្យស្នើសុំ.......................................................................................................... ២៤

ខ. ការបញ្ជាក់ភាពត្រឹមត្រូវ ............ ២៤
គ. ការអស់សុពលភាព នៃពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល ............ ២៥

## ជំពូកទី៣
## វិធានការក្នុងការដោះស្រាយវិវាទម៉ាកនៅកម្ពុជា

**ផ្នែកទី១៖ ចរិកលក្ខណៈនៃអំពើរំលោភបំពាន់ម៉ាក** ............ ២៦
**កថាខ័ណ្ឌទី១៖ សញ្ញាណនៃការរំលោភបំពានម៉ាក** ............ ២៦
**កថាខណ្ឌទី២៖ សំណើសុំធ្វើសវនាការនៃម៉ាក** ............ ២៧
ក. ភស្តុតាង ............ ២៧
ខ. សារណាការពារ ............ ២៧
គ. ការប្តឹងជំទាស់ និងមន្ត្រីកាន់កាប់បញ្ជី ............ ២៨
ឃ. ការប្តឹងជំទាស់ និងការស្នើសុំចុះបញ្ជី ............ ២៨
ង. មោឃភាព និងការលុបចេញពីបញ្ជី ............ ២៨
ច. ការរំលោភ និងវិធានការដោះស្រាយ ............ ២៩
ឆ. សិទ្ធិបេតិកភណ្ឌរបស់ម្ចាស់ម៉ាក ............ ៣០
**ផ្នែកទី២៖ ដំណោះស្រាយតាមផ្លូវតុលាការ** ............ ៣១
**កថាខណ្ឌទី១៖ វិធានការតាមច្រកព្រំដែន** ............ ៣១
ក. សមត្ថកិច្ចតាមមាត់ច្រកព្រំដែន ............ ៣២
ខ.ពាក្យបណ្តឹង ............ ៣២
គ. ការធានា និងការបដិសេធចំពោះការឃាត់ទុក ............ ៣៣
ឃ. ការបដិសេធចំពោះការឃាត់ទុក ............ ៣៤
ង. ចំណាត់ការរបស់សមត្ថកិច្ចតាមច្រកព្រំដែន ............ ៣៤
**កថាខណ្ឌទី២៖ សវនាការ** ............ ៣៦
ក. យន្តការដោះស្រាយក្រៅប្រពន្ធតុលាការ ............ ៣៦
ខ. ការបើសវនាការ ............ ៣៧

គ. សវនាការអន្តរភាគី ..................................................................................... ៣៧
ឃ. សវនាការឯកតោភាគី ..................................................................................... ៣៨
**កថាខណ្ឌទី២៖ ទោសបញ្ញត្តិ នៃអំពើរំលោភបំពាន** ..................................................... ៣៨
ក. ទណ្ឌកម្មរដ្ឋប្បវេណី ..................................................................................... ៣៨
ខ. ទោសព្រហ្មទណ្ឌ ..................................................................................... ៣៩
**សេចក្ដីសន្និដ្ឋាន** ..................................................................................... ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយដែលត្រូវបានប្រជាជាតិនៅក្នុងពិភពលោកចាត់ទុកថាជាប្រទេសដែលមានប្រវត្តិសាស្ត្រវ័យចំណាស់មួយ ក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ មិនតែប៉ុណ្ណោះ ក៏ជាប្រទេសដែលសម្បូរទៅដោយ អរិយធម៌ វប្បធម៌ សិល្បៈ ធនធានធម្មជាតិ គ្រប់សមបែបយ៉ាង ដែលជាពិសេសនោះ គឺកេរ្តិ៍តំណែលដែលបន្សល់ទុកមកពីដូនតាដែលរួមមានប្រាង្គ-ប្រាសាទសិលា ដែលមានការរចនាបថដ៏អស្ចារ្យរៀបរាប់ពីជីវភាពប្រចាំថ្ងៃ នាសម័យកាលនោះ។ ប៉ុន្តែអ្វីដែលគួរឱ្យអនោចអធ្មមបំផុតនោះ គឺប្រទេសកម្ពុជាបានទទួលរងនូវការឈឺចាប់ ខូចខាតបាត់បង់លំបាកវេទនាស្ទើតែទាំងស្រុង គឺនៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមក ដែលបានធ្វើឱ្យប្រទេសកម្ពុជាស្ទើតែបាត់ឈ្មោះពីពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ ស្រមោលអន្ធកាលនេះត្រូវបានរសាត់អណ្ដែតចាកឆ្ងាយទៅហើយ។ ទាំងអស់នេះគឺដោយសារការខិតខំប្រឹងប្រែងក្រោកឈរបន្តិចម្ដងៗ រហូតមកដល់បច្ចុប្បន្ន ព្រមទាំងស្តារគ្រប់ហេដ្ឋារចនាសម្ព័ន្ធនៃប្រទេសជាតិ ឱ្យមានឈ្មោះបោះសម្លេងជាថ្មីនៅថ្នាក់តំបន់ និងអន្តរជាតិផងដែរ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះព្រះរាជាណាចក្រកម្ពុជា បានទទួលជោគជ័យយ៉ាងកត់សម្គាល់នៅក្នុងវិស័យពាណិជ្ជកម្ម ទាំងក្នុងតំបន់ និងក្រៅតំបន់ រួមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍ។ ការបញ្ជ្រៀបចូលនៃផ្នែកពាណិជ្ជកម្មនៅក្នុងតំបន់ បានធ្វើឱ្យមានការកើនឡើងនៃទំនាក់ទំនងរវាងពាណិជ្ជកម្ម និងសេដ្ឋកិច្ចក្នុងតំបន់។ ការកើនឡើងនេះរួមមានដូចជា ការវិនិយោគហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេមាននៅក្នុងវិស័យនានាដូចជា អភិបាលកិច្ចសាជីវកម្ម និងរបបសិទ្ធិនៃវិស័យកម្មសិទ្ធិបញ្ញាផងដែរ។ ការរួមបញ្ចូលនៃផ្នែកទាំងអស់នេះបានលើកកម្ពស់កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ចដ៏ទូលំទូលាយ និងការគៀរគរធនធានតាមរយៈការតភ្ជាប់សេដ្ឋកិច្ចក្នុងតំបន់ជាមួយ និងសកលលោក។ នៅក្នុងគម្រោងការណ៍នៃការអភិវឌ្ឍសេដ្ឋកិច្ចដ៏ធំនេះ ព្រះរាជាណាចក្រកម្ពុជា បានពិនិត្យមើលនូវគោលនយោបាយ និងត្រួតពិនិត្យច្បាប់ និងការការពារទៅលើផ្នែកកម្មសិទ្ធិបញ្ញា ដែលជាផ្នែកសំខាន់ក្នុងសេដ្ឋកិច្ចប្រទេស។ បច្ចុប្បន្ននេះប្រទេសកម្ពុជាគឺទទួលបានការវិនិយោគជាច្រើនពីសំណាក់បណ្ដាប្រទេសនៅក្នុងពិភពលោក រួមមានសាធារណៈរដ្ឋប្រជាមានិតចិនជាដើម-ល-។ ពិតណាស់ ឆ្លើយតបទៅនិងការអភិវឌ្ឍ និងការវិនិយោគដោយសន្តិសុខ ស្ថេរភាព និងភាពជាការសហការ។ រាជរដ្ឋាភិបាលក៏បានធ្វើការកំណត់នូវសេចក្ដីព្រាងច្បាប់ក៏ដូចជាយុទ្ធសាស្ត្រផ្សេងៗទៀត ក្នុងការគ្រប់គ្រងទៅវិស័យ ជាច្រើនទៀតដោយក្នុងនោះសង្កេតឃើញថាច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើការប្រកួតប្រជែងមិនស្មោះត្រង់ ដែលមាន

ចែងយ៉ាងច្បាស់ចំនួន **១៦ជំពូក** និង **៧២មាត្រា** ដែលបានចែងអំពីម៉ាកសញ្ញា ដែលក្នុងនាមជាពាណិជ្ជករមួយរូប ថាតើគួរតែងស្វែងរកនីតិវិធីការពារ ផលិតផលរបស់ខ្លួន ព្រមទាំងធ្វើយ៉ាងណាឱ្យម៉ាកនេះស្ថិតនៅក្រោមច្បាប់កំណត់។ ជំហានដំបូងនៃការប្រើប្រាស់ម៉ាក ដំបូងឡើយគឺមានគោលបំណងក្នុងការសម្គាល់នូវម្ចាស់នៃទំនិញ ឬផលិតផលដែលជាផលិតផល របស់ពួកគេតែប៉ុណ្ណោះដោយមិនទាន់មានគំនិតគិតដល់មានការប្រកួតប្រជែងគ្នានោះទេ។ តែដោយសារការវិវត្តន៍នៃសង្គមបានធ្វើឱ្យមនុស្សកាន់តែមានការយល់ដឹងច្រើន មានគំនិតច្នៃប្រឌិតខ្ពស់ ចំពោះការកែច្នៃលើម៉ាកសញ្ញារបស់ពួកគេជាពិសេស គឺសារៈសំខាន់នៃម៉ាកសញ្ញាទាំងនោះ ដែលគេបានប្រើប្រាស់។ ទំនាក់ទំនងនៃវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម ពីប្រទេសមួយទៅប្រទេសមួយទៀតកាន់តែមានសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃហើយការបង្កើននៃការបង្កើតសញ្ញា ដើម្បីសម្គាល់ផលិតផល ឬទំនិញ សេវារបស់ម្ចាស់ទំនិញទាំងនោះបានជ្រាបដល់បណ្តាប្រទេសជិតខាង ដែលកត្តាទាំងនេះធ្វើឱ្យមនុស្សចាប់ផ្តើមធ្វើការពង្រឹង និងពង្រីកសក្តានុពលនៃផ្នែកពាណិជ្ជកម្ម ឧស្សាហកម្មរបស់ខ្លួន។ ជាមួយគ្នានេះដែលម៉ាកបានដើរតួនាទីកាន់តែសំខាន់ សម្រាប់ពាណិជ្ជករ ផលិតករ ដោយសារតែមានការប្រកួតប្រជែងគ្នារវាងបណ្តាប្រទេសទាំងអស់នោះបណ្តាយុត្តាធិការមួយចំនួនបាន ចាប់ផ្តើមធ្វើការបង្កើតលក្ខណៈក្នុងការគ្រប់គ្រង និងការពារពីការរំលោភបំពានពីបុគ្គល ដែលមិនមែនជាម្ចាស់នៃទំនិញ ឬផលិតផលនោះក្នុងដែនដីរបស់ខ្លួន។ មួយវិញទៀត គឺមនុស្សបានចាប់ផ្តើមគិតអំពីតម្លៃនៃម៉ាកសម្គាល់លើទំនិញ ឬផលិតផលរបស់ខ្លួន។ ហេតុដូច្នេះហើយគេបានចាប់ផ្តើមធ្វើការចុះបញ្ជីទទួលស្គាល់ជាផ្លូវការទៅលើម៉ាក និងពាណិជ្ជនាមដើម្បីការពារតម្លៃ នៃកេរ្តិ៍ឈ្មោះកត្តិយសរបស់ម្ចាស់កម្មសិទ្ធិដែលទាក់ទងដល់សេដ្ឋកិច្ចពាណិជ្ជកម្មជាតិរបស់ពួកគេ។

ជាការពិតណាស់ យើងសង្កេតឃើញថាតួលេខផ្លូវការ និងតារាងទិន្នន័យរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក **(WTO)** ដែលបានធ្វើបច្ចុប្បន្នភាពប្រចាំថ្ងៃបានបង្ហាញថា ម៉ាកពាណិជ្ជកម្មជាង **៤៦៨៥** ត្រូវបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីដើមឆ្នាំ២០១៤ មកម្លេះបើធៀបទៅនិងឆ្នាំ២០១៥ មានចំនួននៃការចុះបញ្ជីមានចំនួន **៤១៩៩**។[1] ដើម្បីសិក្សាទៅលើប្រធានស្តីពី

[1] យោងតាមប្រសាសន៍របស អប់ ព៉ាឌី ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។ បានឱ្យដឹងថាភាពខុសគ្នានេះគឺដោយសារតែក្រសួងប្រើប្រាស់តួលេខចុះបញ្ជីរយៈពេល ១១ខែ នៅក្នុងរបាយការណ៍ របស់ខ្លួនធៀបនឹងតួលេខឆ្នាំ២០១៥ មួយឆ្នាំពេញ ដែលនាំឲ្យប្រព័ន្ធព័ត៌មានក្នុងស្រុកមួយចំនួនបកស្រាយខុសទិន្នន័យនេះ។

**"របបគតិយុត្តនៃម៉ាកក្នុងបរិបទច្បាប់កម្ពុជា"** នេះឱ្យបានលម្អិត និងងាយស្រួលយល់នោះ យើងសុំនិងធ្វើការចោទជាសំនួរគតិយុត្តសំខាន់នៅក្នុងប្រធានបទនេះគឺ៖

១. តើរបបគតិយុត្តនៃម៉ាក នៅប្រទេសកម្ពុជាបង្កើតឡើងក្នុងគោលបំណងអ្វី?

២. តើនីតិវិធីនៃការចុះបញ្ជីម៉ាក ត្រូវមានលក្ខខណ្ឌចាំបាច់អ្វីខ្លះ?

៣.ក្នុងករណីមានការរំលោភបំពានម៉ាក តើយើងត្រូវមាននីតិវិធីអ្វីខ្លះទប់ស្កាត់ការពារ និងបង្ក្រាបនូវអំពើរំលោភម៉ាកនោះ?

មូលហេតុដែលធ្វើឱ្យក្រុមយើងខ្ញុំ ជ្រើសរើសយកប្រធានបទនេះ មកសិក្សាស្រាវជ្រាវគឺដោយសារតែក្រុមខ្ញុំបាទមានបំណងចង់សិក្សាស្រាវជ្រាវលើ ក្របខណ្ឌគតិយុត្តនៃច្បាប់ជាតិដែលកំពុងមានជាធរមានពាក់ព័ន្ធនឹងម៉ាក នីតិវិធីនៃការចុះបញ្ជីម៉ាក ដំណោះស្រាយនៃវិវាទម៉ាក ក៏ដូចជានីតិវិធីមួយចំនួនផ្សេងៗក្រោមទម្រង់រូបភាពនៃបទបញ្ញត្តិដទៃទៀត។ ដើម្បីឆ្លើយតបទៅនិងសំនួរគតិយុត្តខាងលើនេះ យើងបានរៀបរៀងឱ្យមានជា **៣ជំពូក** ដែលជំពូកទាំងនោះរួមមាន៖ **ជំពូកទី១** សញ្ញាគតិយុត្តនៃម៉ាក **ជំពូកទី២** នីតិវិធីចុះបញ្ជីម៉ាក និងលក្ខណៈសម្បត្តិទទួលបានការការពារម៉ាក និង**ជំពូកទី៣**វិធានាការក្នុងការដោះស្រាយវិវាទម៉ាក។

ដូចនេះ ដើម្បីឱ្យកាន់តែជ្រាបច្បាស់សូមមិត្តអ្នកអានមើលការបកស្រាយ និងការរៀបរាប់ដែលមាននៅក្នុងអត្ថបទនេះតាមលំដាប់លំដោយដូចខាងក្រោមនេះ៖

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃម៉ាក

ម៉ាកសញ្ញាបានកើតមានជាយូរមកហើយ ដែលវាមានអាយុកាលជាង ៣០០០ឆ្នាំ កន្លងទៅហើយដោយ សិប្បករជនជាតិឥណ្ឌាបានឆ្លាក់ហត្ថលេខារបស់ខ្លួន នៅលើផលិតផលសិល្បៈទាំងឡាយមុនបញ្ជូនទៅលក់នៅប្រទេសអ៊ីរ៉ង់។[2] ដែលវត្ថុទាំងអស់នោះមានម៉ាកដូចជាម៉ាកគ្រឿងក្អមរ៉ូម៉ាំង និងវត្ថុផ្សេងៗទៀតជាង១០០មុខ ហើយបានដាក់ប្រើប្រាស់ដោយរាប់បញ្ចូលម៉ាក FORTIS ដែលជាម៉ាកល្បីល្បាញបំផុត រហូតត្រូវបានគេថតចម្លង និងក្លែងបន្លំដោយសារម៉ាកសញ្ញាមានការរីកចម្រើនខ្លាំងក្នុងបច្ចុប្បន្នភាពសម័យកាលនោះ។ នៅក្នុងសម័យទំនើប ម៉ាកគឺជាសញ្ញាសម្គាល់ផលិតផលទំនិញ ឬសម្គាល់សេវាកម្មរបស់បុគ្គល ឬក្រុមហ៊ុននីមួយៗដែលមានលក្ខណៈសម្គាល់ប្លែកៗពីគ្នា។ ការបែងចែកឱ្យមានម៉ាកនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះតាមរយៈការប្រើប្រាស់ម៉ាក អតិថិជនងាយស្រួលធ្វើការបែងចែកប្រភព ឬអត្តសញ្ញាណនៃទំនិញ។

## ផ្នែកទី១៖ បញ្ញាត្តិទូទៅ

ម៉ាក គឺជាប្រភេទមួយនៃកម្មសិទ្ធិឧស្សាហកម្ម ដែលប្រើប្រាស់ភ្ជាប់ជាមួយ និងឈ្មោះសហគ្រាស ទាក់ទង និងកេរ្តិ៍ឈ្មោះលើទីផ្សារប្រកួតប្រជែង និងដែលអាចទាក់ទាញអតិថិជនរបស់សហគ្រាសមួយនៅក្នុងវិស័យពាណិជ្ជកម្ម។

### កថាខណ្ឌទី១៖ សញ្ញាទូទៅនៃម៉ាក និងពាណិជ្ជនាម

ម៉ាកជាគ្រឿងសំគាល់នូវទំនិញ ឬសេវា ដែលជាទូទៅវាអាចត្រូវបានគេបង្កើតវាឡើងក្រោមទម្រង់ជា៖ រូបភាព អក្សរ លេខ ពាក្យស្លោក ស្លាកសញ្ញា ពណ៌មួយ ឬការរួមបញ្ចូលនៃពណ៌ឈ្មោះ ហត្ថលេខា ទំរង់បីខ្នាត ជាដើម។ ក្រោមការបង្កើតពីទំរង់ដែលបានរៀបរាប់ខាងលើនាំឱ្យគេអាចធ្វើការបែងចែក ម៉ាកជាបួនប្រភេទគឺ៖ ពាណិជ្ជនាម ពាណិជ្ជសញ្ញា សេវាសញ្ញា និងម៉ាកសមូហភាព។ ម៉ាកទាំងបួនខាងលើនេះ ក្រោយពីម្ចាស់នៃម៉ាកបានធ្វើការបង្កើតវារួចហើយជាគោលការណ៍គេតែងយកវាទៅធ្វើការចុះបញ្ជីដើម្បី ទទួលបានអត្ថប្រយោជន៍ បន្ទាប់ពីបានចុះបញ្ជីរួច។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងយល់យើងគួរគប្បីស្វែងយល់អំពីអត្ថន័យនៃម៉ាកជាមុនសិន។

---

[2] យោងតាមឯកសាររបស់លោកសាស្ត្រចារ្យ លឹម យូសួ *នីតិកម្មសិទ្ធិបញ្ញា* បោះពុម្ពឆ្នាំ២០០២ ទំព័រទី ៣១

### ក. និយមន័យនៃម៉ាក

ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃ ទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថា ពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សំរាប់សេវាសញ្ញាហៅថា សេវាសញ្ញា។[3] សញ្ញាទាំងនេះរួមមាន ឈ្មោះបុគ្គល អក្សរ លេខ សមាសធាតុរូបភាព និងបង្គុំនៃពណ៌ ព្រមទាំងបង្គុំ នៃសញ្ញាទាំងនេះអាចត្រូវបានទទួលបានការចុះបញ្ជីជាម៉ាក។[4]

### ខ. ប្រភេទនៃម៉ាក

ច្បាប់ម៉ាកនៃប្រទេសកម្ពុជាការពារតែទៅលើម៉ាក ដែលអាចមើលឃើញតែប៉ុណ្ណោះ។ ប៉ុន្តែនៅបណ្ដាប្រទេសមួយចំនួនទៀតនៅលើពិភពលោក ច្បាប់នៃរដ្ឋមួយចំនួនការពារលើម៉ាកដែលពុំអាចមើលឃើញ មានជាអាទិ៍ សំឡេង ក្លិន រសជាតិ។ ដូច្នេះ ម៉ាកអាចត្រូវបានបែងចែកជាប្រភេទខុសៗពីគ្នា។

#### ១. ពាណិជ្ជសញ្ញា

ពាណិជ្ជសញ្ញា គឺជាសញ្ញាដែលបញ្ជាក់ដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីតាំងឱ្យក្រុមហ៊ុន ឬផលិតផលណាមួយ។ ពាណិជ្ជសញ្ញា អាចជារូបភាព ពាក្យ ឬជាការបូកបញ្ចូលគ្នាទាំងរូបភាពព្រមទាំងពាក្យ។

#### ២. សេវាសញ្ញា

សេវាសញ្ញា គឺជាម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញដោយហៅថាពាណិជ្ជសញ្ញាហើយម៉ាកដែលប្រើប្រាស់ដែលប្រើប្រាស់សម្រាប់សញ្ញាគេហៅថា សេវាសញ្ញា។[5]

---

[3] យោងតាមមាត្រា២ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[4] យោងតាមមាត្រា៥ នៃកិច្ចព្រមព្រៀងស្ដីពី ទិដ្ឋភាពាណិជ្ជកម្មទាក់ទង នឹងកម្មសិទ្ធិបញ្ញា Trip ឆ្នាំ១៩៩៤

[5]យោងតាមមាត្រា២ (កថាខ័ណ្ឌទី១) នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ ២០០២

### ៣. ម៉ាកសមូហភាព

ម៉ាកសមូហភាព គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញាហើយម៉ាកដែលប្រើប្រាស់សំរាប់សេវាហៅថា សេវាសញ្ញា។[6] ម៉ាកសមូហភាពនេះ ជាម៉ាកមួយដែលត្រូវបានគ្រប់គ្រងដោយសមាគមន៍ ម៉ាកសមូហភាពនេះដែរត្រូវបានកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

### ៤. ម៉ាកដែលបញ្ជាក់ពីគុណភាពទំនិញ

ម៉ាកបញ្ជាក់គុណភាពទំនិញ ឬផលិតផល សំដៅទៅលើសញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃផលិតផលមួយតាមការតម្រូវ នៃស្តង់ដារផលិតផលមួយ មានសញ្ញាបញ្ជាក់គុណភាព សុវត្ថិភាព និងចុះបញ្ជីផលិតផល[7]។ ម៉ាកប្រភេទនេះបុគ្គលណាក៏មានសិទ្ធិប្រើប្រាស់ដែលដោយគ្រាន់តែគោរពតាមលក្ខខណ្ឌតម្រូវតាមច្បាប់ សម្រាប់ផលិតផលឧស្សាហកម្ម។ វាពុំមានសិទ្ធិផ្តាច់មុខសម្រាប់បុគ្គលណាមួយជាក់លាក់នោះទេ។ សញ្ញាទាំងនេះរួមមានបីប្រភេទ[8]៖

- សញ្ញាបញ្ជាក់ពីគុណភាពទំនិញ
- សញ្ញាបញ្ជាក់សុវត្ថិភាពទំនិញ
- សញ្ញាបបញ្ជាក់ពីការចុះបញ្ជីផលិតផល

ម៉ាកទាំងបី ខាងលើនេះត្រូវតែស្ថិតនៅក្រោមក្របខណ្ឌដោយឡែកស្របតាមច្បាប់ស្តីពីស្តង់ដារកម្ពុជាពោលគឺមិនស្ថិតក្រោមច្បាប់ម៉ាកឡើយ។

## គ. ពាណិជ្ជនាម

នាម ឬសញ្ញាសំគាល់មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយប្រសិនបើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសំគាល់ដែលបានកំណត់នោះប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ

---

[6] យោងតាមមាត្រា២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[7] យោងតាមមាត្រា៣ នៃច្បាប់ស្តីពី ស្តង់ដារ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧

[8] យោងតាមប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល លេខ១១២ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤

សីលធម៌ និងជាពិសេសអាចបំភ័ន្តដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាសដែលកំណត់ដោយនាមនោះ។[9]

## កថាខណ្ឌទី២៖ លក្ខណៈបង្ហាញនៃម៉ាក និងពាណិជ្ជនាម

លក្ខណៈរបស់ម៉ាក និងពាណិជ្ជនាម គឺសម្រាប់សំគាល់អំពីលក្ខណៈខុសគ្នារវាងទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ ក្នុងការកំណត់អំពីសញ្ញាសំគាល់នៃឈ្មោះងាយស្រួលក្នុងការកំណត់អំពីលក្ខណៈខុសៗគ្នានៃផលិតផលណាមួយ។

### ក. ប្រភេទសញ្ញាដែលមើលឃើញនានា

ច្បាប់បានកំណត់ចំពោះម៉ាកថា ត្រូវតែជាសញ្ញាដែលមើលឃើញនិងភ្នែកបាន ពីព្រោះវាធ្វើឱ្យមានភាពងាយស្រួលដល់អតិថិជន ឬអ្នកប្រើប្រាស់នូវទំនិញ ឬសេវាទាំងនោះក្នុងការបែងចែកលក្ខណៈខុសគ្នារវាងទំនិញមួយទៅ និងទំនិញមួយទៀតបាន និងអាចជួយសម្រួលដល់កិច្ចការការពារម៉ាកពីការក្លែងបន្លំ និងការរំលោភបំពានទៅលើម៉ាកនៃទំនិញ ឬសេវាទាំងនោះបានទៀតផងដែរ។ តាមរយៈការចុះបញ្ជីម៉ាកនេះដែរត្រូវធ្វើឡើងដោយអាជ្ញាមន្ត្រីកាន់កាប់ញ្ជី។ ដូច្នេះថាតើប្រភេទនៃសញ្ញាមើលឃើញអ្វីខ្លះ ដែលអាចទទួលបានការចុះបញ្ជីជាម៉ាកបាន។ ព្រមទាំងសញ្ញាដែលមិនអាចមើលឃើញ និងភ្នែកបានអាចទទួលបានកិច្ចការពារដូចសញ្ញាដែលមើលឃើញនោះ។ នៅខាងក្រោមនេះ និងធ្វើការសិក្សាទៅលើសញ្ញាផ្សេងៗដែលអាចជាម៉ាក។ ទាំងអស់នេះគឺ និងត្រូវធ្វើការបកស្រាយបន្ថែមផងដែរ។

#### ១. លក្ខណៈសម្គាល់នៃម៉ាក

ការប្រើប្រាស់ម៉ាកមួយមានគោលដៅតែមួយគត់ គឺអាចកំណត់អំពីអត្តសញ្ញាណនៃទំនិញ ឬសេវារបស់សហគ្រាសណាមួយ ដើម្បីឱ្យអតិថិជនទាំងឡាយដែលជាអ្នកប្រើប្រាស់ធ្វើការបែងចែកនូវភាពខុសប្លែកពីគ្នានៃទំនិញ ឬសេវារបស់សហគ្រាសនោះបានសំដៅប្រឆាំងទល់ និងការក្លែងបន្លំម៉ាកពីសហគ្រាសខិលខូចនានា។

[9] យោងតាមមាត្រា២០ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

## ២. លក្ខណៈសម្គាល់ប្រភេទសញ្ញាមើលឃើញផ្សេងទៀត

ច្បាប់ត្រូវតែកំណត់ឱ្យម៉ាក គឺជាសញ្ញាដែលគេអាចមើលឃើញ និងភ្នែកបានពីព្រោះមានតែម៉ាកសញ្ញាទេដែលគេអាចមើលឃើញដោយភ្នែកទទេបានប៉ុណ្ណោះ ដែលអាចជាសញ្ញាងាយស្រួលសម្គាល់ដល់អតិថិជន ក្នុងការបែងចែកភាពខុសគ្នានេះរវាងផលិតផលមួយទៅផលិតផលមួយទៀតបានផងដែរ និងក៏អាចជួយសម្រួលដល់យន្តការនៃការការពារម៉ាក ពីរាល់ការក្លែងបន្លំផ្សេងៗបានផងទៀត។ តាមរយៈការបង្ហាញរូបរាងពិសេសនៃម៉ាកដែលអាចមើលឃើញនោះនៅក្នុងបញ្ជីនៃម៉ាកនាពេលស្នើសុំការការពារចំពោះមុខមន្ត្រីកាន់កាប់បញ្ជី។

### ២.១ ជាពាក្យពេចន៍

ម៉ាកជាពាក្យពេចន៍ គឺជាអក្សរមួយពាក្យមួយ ឬអាចជាឈ្មោះបុគ្គលណាមួយ ឬក៏ជាឈ្មោះទីតាំងនៃតំបន់ណាមួយ ឬជាការបញ្ចូលគ្នានៃពាក្យពេចន៍ដែលទាំងអស់នេះ។ យើងអាចរៀបរាប់ម៉ាកមួយចំនួននៅក្នុងន័យនេះដូចជា ម៉ាកDELL ឬម៉ាកIBM សម្ភារៈសម្រាប់កុំព្យូទ័រជាដើម។

### ២.២ ជាលេខ

ម៉ាកប្រភេទនេះ គឺអាចសម្តែងចេញតាមរយៈលេខ ឬអាចជាការរួមបញ្ចូលគ្នារវាងលេខ និងអក្សរ។ លេខធម្មតាគឺមិនអាចធ្វើការកំណត់សម្គាល់ម៉ាកបានទេដូចជាលេខមួយតួ ឬជាអក្សរមួយតួចធម្មតា។ ហេតុដូច្នេះហើយ បានជាកម្ពុជាមិនធ្វើកិច្ចការពារទៅលើម៉ាកទាំងនោះមួយវិញទៀតលេខដែលអាចទទួលបានកិច្ចការពារទាល់តែលេខនោះអាចឱ្យគេសម្គាល់ថាវាជាម៉ាកតាមរយៈម៉ូតឬការរចនានៅលើម៉ាកជាលេខនោះ។[10]

## ខ. ម៉ាកដែលមានលក្ខណៈគ្រប់គ្រាន់

ដើម្បីទទួលបាននូវកិច្ចការពារ ជាក់លាក់លើម៉ាកមួយម្ចាស់ម៉ាក ត្រូវកំណត់អំពីវិស័យពាណិជ្ជកម្មដែលម៉ាកនោះត្រូវយកទៅអនុវត្ត។ ជាគោលការណ៍ ម៉ាកដែលបានដាក់ពាក្យក្រោយនិងដែលមានសញ្ញាដូច ឬប្រហាក់ប្រហែលទៅ និងម៉ាកដែលបានចុះបញ្ជីមុនមិនត្រូវបានអនុញ្ញាត

[10] យោងតាមឯកសារបណ្តុះបណ្តាលស្តីពីម៉ាក *(Training course on Legal Mark Agent),* រៀបចំដោយ វ៉ា រត្ន័សាន ទីប្រឹក្សារបស់ក្រសួងពាណិជ្ជកម្ម។

ឱ្យចុះបញ្ជីឡើយប្រសិនបើម៉ាកនោះត្រូវបានដាក់ពាក្យស្នើសុំចុះបញ្ជី ដើម្បីប្រើប្រាស់លើផលិតផល ឬសេវាដូចគ្នាជាមួយ និងម៉ាកដែលបានចុះបញ្ជីរួច។ ប្រសិនបើម៉ាកដូចគ្នាប៉ុន្តែត្រូវបានចុះបញ្ជីនៅក្នុងជំពូកនៃទំនិញ ឬសេវាខុសគ្នា ម៉ាកនោះអាចអនុញ្ញាឱ្យចុះបញ្ជីបាន។

### គ. ភាពមិនទំនេរចំពោះម៉ាក

សញ្ញាដែលអាចប្រើប្រាស់ និងចុះបញ្ជីជាម៉ាក បានកាលណាដែលសញ្ញានោះគោរពតាមលក្ខខ័ណ្ឌនៃការចុះបញ្ជី និងជាសញ្ញាដែលនៅទំនេរ ពោលគឺសញ្ញានោះពុំមែនជាកម្មសិទ្ធិរបស់តតិយជនណាមួយឡើយ។ ក្នុងន័យនេះយើងអាចនិយាយម្យ៉ាងទៀតបានថា សញ្ញាដែលអាចចុះបញ្ជីជាម៉ាកបានត្រូវមានភាពថ្មី។ ជានោះផងដែរដើម្បីឱ្យដឹងថាម៉ាកមួយជាកម្មសិទ្ធិរបស់តតិយជន អ្នកដាក់ពាក្យសុំអាចធ្វើការស្រាវជ្រាវលើភាពទំនេរនៃម៉ាកនោះ និងសុំយោបល់ពីមន្ត្រីកាន់កាប់បញ្ជីនោះ។[11] បន្ទាប់ពីទទួលបានពាក្យស្នើសុំបញ្ជាក់ពីភាពទំនេរនៃម៉ាកនៅ នាយកដ្ឋានកម្មសិទ្ធិបញ្ញា និងចេញលិខិតបញ្ជាក់ថាម៉ាកដែលបានដាក់ពាក្យសុំនោះជាម៉ាកដែលនៅទំនេរ ឬដែលជាម៉ាកកម្មសិទ្ធិរបស់តតិយជនណាផ្សេងទៀត។

## កថាខណ្ឌទី៣៖ ឯកទេសកម្មនៃម៉ាក

ឯកទេសកម្មនៃម៉ាក គឺមានន័យថាជាម៉ាកមួយដែលត្រូវបានការពារឱ្យតែចំពោះទំនិញ ឬសេវាដែលស្ថិតនៅក្នុងវិស័យតែមួយដូចគ្នា និងទំនិញ ឬសេវាដែលបានចុះបញ្ជីម៉ាកនោះប៉ុណ្ណោះ។ ពោលគឺជាការការពារម៉ាកដោយគិតទៅលើប្រភេទនៃទំនិញ។

*(ឧទាហរណ៍ សញ្ញា ផ្លែប៉ោម ដែលត្រូវបានចុះបញ្ជីជាម៉ាក និងទទួលបានការការពារចំពោះទំនិញជា ទូរស័ព្ទ, I pad, និងLAPTOP គឺមានឯកទេសកម្មរបស់ខ្លួនពោលគឺទទួលបានការការពារប្រឆាំង និងការបំពានម៉ាក។ តែនៅក្នុងតែវិស័យនៃផលិតផល ទូរស័ព្ទ, I pad, និងLAPTOP ដូចដែលខ្លួនបានចុះបញ្ជីនោះប៉ុណ្ណោះ)។*

[11] យោងតាមមាត្រា៣០ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

## ក. សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

ផលប្រយោជន៍នៃការទទួលបាន សិទ្ធិតាមរយៈការចុះបញ្ជីម៉ាកនេះ គឺជាការទទួលស្គាល់ និងផ្តល់កិច្ចការពារដល់ម្ចាស់ម៉ាកនៅក្នុងការប្រើប្រាស់ម៉ាកនោះលើទំនិញ ឬសេវារបស់ខ្លួន។ បើទោះបីជាច្បាប់ពុំបានចែងនូវរូបភាពនៃបម្រើបម្រាស់សិទ្ធិនេះយ៉ាងមិចក៏ដោយ ក៏ប៉ុន្តែបើមានតួនាទីនៃម៉ាកដូចដែលបានកំណត់ក្នុងនិយមន័យ នៃម៉ាកការប្រើប្រាស់ម៉ាកនេះគឺមានន័យថា ម្ចាស់ម៉ាកអាចផលិតម៉ាកនោះជាថ្មីបិទ ឬមិនឱ្យធ្វើការចរាចរណ៍ចំពោះផលិតផល ទំនិញសេវាដែលម្ចាស់ម៉ាកនោះបានចុះបញ្ជី។[12]

## ខ. រយៈពេលនៃសិទ្ធិប្រើប្រាស់ម៉ាក

សុពលភាពនៃម៉ាកដែលបានចុះបញ្ជី គឺមានរយៈពេល ១០ ឆ្នាំ ប៉ុណ្ណោះរាប់ចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជីមក។[13] ប៉ុន្តែរយៈពេលនេះអាចជា កម្មវត្ថុនៃការចុះបញ្ជីបន្តបន្ថែម ១០ ឆ្នាំ ឡើងវិញទៀតកាលបើម្ចាស់ម៉ាកដែលចុះបញ្ជីនោះស្នើសុំ និងបង់អាករចុះបញ្ជីជាថ្មីតាមការកំណាតពោលគឺយ៉ាងយូរបំផុតមិនអាចហួសពីរយៈពេលអនុគ្រោះ ៦ ខែ នៅក្រោយកាលបរិច្ឆេទនៃការផុតរយៈពេលកំណត់នោះឡើយ។ គឺនៅក្នុងកំឡុងពេលនៃសុពលភាពនេះហើយដែលម្ចាស់ម៉ាកអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនលើម៉ាកនោះបាន។ ចំពោះសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកដូចដែលបានរៀបរាប់ នេះត្រូវបានចាត់ទុកថាជាសិទ្ធិធ្វើអាជីវកម្មផ្ទាល់របស់ម្ចាស់ម៉ាកលើម៉ាករបស់ខ្លួន។

## គ.ម៉ាកត្រូវមានលក្ខណៈមិនផ្ទុយ និងទំនៀមទំលាប់ប្រពៃណី

ម៉ាកដែលត្រូវបានស្នើសុំចុះបញ្ជីរួចហើយ គឺមិនត្រូវមានលក្ខណៈផ្ទុយ និងសណ្តាប់ធ្នាប់សាធារណៈឡើយ។ ម៉ាកមិនត្រូវបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិទេ។[14] ប្រសិនបើម៉ាកដែលជាកម្មវត្ថុ នៃការចុះបញ្ជីត្រូវបានចាត់ទុកថាមានលក្ខណៈផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈរបស់ ព្រះរាជាណាចក្រកម្ពុជាបានឡើយ។ ក្នុងករណីនេះ

[12] យោងតាម សារាចរណែនាំ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥

[13] យោងតាមមាត្រា១២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[14] យោងតាមមាត្រា៤ (ខ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

មន្ត្រីកាន់កាប់បញ្ជីម៉ាកអាចបដិសេធមិនទទួលយល់ព្រមក្នុងការចុះបញ្ជីម៉ាកនោះ។ ម៉ាកដែលដូចគ្នា ឬត្រាប់តាម ឬមានចំនុចណាមួយដូចសញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប អក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការដែលអនុម័តដោយរដ្ឋណាមួយអង្គការរដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិ មួយលើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋនោះ ឬអង្គការនោះ។[15]

[15] យោងតាមមាត្រា៤ (ឃ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

# ជំពូកទី២
# នីតិវិធីចុះបញ្ជីម៉ាក និងលក្ខណៈសម្បត្តិទទួលបានការការពារម៉ាក

ម៉ាកមួយអាចទទួលបាននូវកិច្ចការពារស្របច្បាប់ កាលណាតែម៉ាកនោះត្រូវបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ម្ចាស់ម៉ាកអាចដាក់ពាក្យសុំចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយត្រូវបំពេញលក្ខខណ្ឌទាំងឡាយតាមច្បាប់កំណត់ព្រមទាំងលក្ខខណ្ឌទម្រង់ផងដែរ។

## ផ្នែកទី១៖ នីតិវិធីនៃការចុះបញ្ជីម៉ាក

គោលការណ៍ចុះបញ្ជី គឺជាប្រភពផ្ទាល់នៃសិទ្ធិលើម៉ាកខុសគ្នាអំពីសិទ្ធិអ្នកនិពន្ធ សិទ្ធិលើម៉ាកពុំត្រូវបានទទួលដោយស្វ័យប្រវត្តិនោះឡើយ។[16] ក្នុងន័យនេះ យើងអាចកត់សម្គាល់បានថាប្រភពផ្ទាល់នៃសិទ្ធិផ្តាច់មុខលើម៉ាក គឺកើតចេញពីការចុះបញ្ជី ពុំមែនចេញពីគំនិតច្នៃប្រឌិតបង្កើតឡើងដោយប្រាជ្ញា ឬមនោសញ្ចេតនាផ្ទាល់អ្វីនោះឡើយ។ ម្យ៉ាងទៀតម៉ាកមួយពុំត្រូវបានការពារឡើយប្រសិនបើម៉ាកនោះពុំត្រូវបានយកទៅចុះបញ្ជី។ ការដែលគ្រាន់តែបានប្រើប្រាស់ជាធម្មតានូវម៉ាកមួយដោយពុំបានយកទៅចុះបញ្ជី និងពុំដឹកនាំដល់ការបង្កើតសិទ្ធិស្របច្បាប់លើម៉ាកនោះឡើយលើកលែងតែជាម៉ាកល្បី។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយក៏ការប្រើប្រាស់ម៉ាកណាមួយដោយពុំបានចុះបញ្ជីពុំត្រូវបានចាត់ទុកថាជាបទល្មើសនោះដែលពោលគឺគ្រាន់តែ អ្នកប្រើប្រាស់ចំពោះម៉ាកនោះ និងពុំអាចទាមទារបាននូវសិទ្ធិឱ្យមានការការពារពីច្បាប់ នាពេលដែលមានការរំលោភបំពានសិទ្ធិប្រើប្រាស់ម៉ាកនោះពីសំណាក់ជនខិលខូចប៉ុណ្ណោះ។

ដើម្បីទទួលបានសិទ្ធិលើម៉ាក ម្ចាស់ម៉ាកត្រូវតែដាក់ពាក្យស្នើសុំចុះបញ្ជីដោយមានភ្ជាប់ជាមួយនូវរាល់សំណុំឯកសារចាំបាច់មួយចំនួនដូចជា ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចដែលជាមន្ត្រីមានតួនាទីធ្វើការពិនិត្យវិនិច្ឆ័យ និងសម្រេចថាគប្បីផ្តល់សិទ្ធិផ្តាច់មុខដល់អ្នកស្នើសុំនោះដែរ ឬយ៉ាងណា។

[16] យោងតាមមាត្រា៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

## កថាខណ្ឌទី១៖ ការដាក់ពាក្យស្នើសុំចុះបញ្ជី

សម្រាប់នីតិវិធីក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីភាពចាំបាច់គឺត្រូវកំណត់ថា តើនរណាទៅដែលអាចជាអ្នកដាក់ពាក្យស្នើសុំ ជាពិសេសតើត្រូវដាក់សំណុំឯកសារចាំបាច់អ្វីខ្លះ និងថាតើអាជ្ញាធរមួយណាដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យស្នើសុំ និងសម្រេចពីការចុះបញ្ជីនេះ។ យើងនិងសិក្សាមើលពីចំណោទសំខាន់ៗ នៃនីតិវិធីចុះបញ្ជីនេះ តាមរយៈបញ្ញត្តិនៃច្បាប់ក៏ដូចជាវិធានជាបទបញ្ញាពាក់ព័ន្ធ និងម៉ាកនេះម្តងមួយៗ។[17]

### ក. អ្នកដាក់ពាក្យស្នើសុំ

គ្រប់បុគ្គលទាំងអស់អាចដាក់ពាក្យស្នើសុំបាន ថ្វីត្បិតតែច្បាប់ស្តីអំពីម៉ាកបានកំណត់និយមន័យឱ្យម៉ាកថាគឺជាសញ្ញាសម្គាល់នូវលក្ខណៈខុសប្លែកគ្នានៃទំនិញ ឬសេវារបស់សហគ្រាសនីមួយៗក៏ការស្នើសុំចុះបញ្ជីពុំបានរក្សាសិទ្ធិសម្រាប់តែសហគ្រាស ឬមួយត្រូវតែជានីតិបុគ្គលនោះឡើយ។ ដោយពុំបានកំណត់ការរិតត្បិតណាមួយដល់គុណភាព នៃអ្នកដាក់ពាក្យស្នើសុំនៅក្រោមទម្រង់ជាវិធានដោយឡែកនៃការចុះបញ្ជីម៉ាកនេះយើងអាច បកស្រាយបានថា ច្បាប់ស្តីពីម៉ាកបើកសិទ្ធិទូលាយក្នុងការស្នើសុំចុះបញ្ជីម៉ាក ឱ្យដល់គ្រប់បុគ្គលទាំងឡាយដែលមានគុណសម្បត្តិធ្វើជាម្ចាស់សិទ្ធិតាមបញ្ញត្តិវិធានរួម។ ក្នុងន័យនេះ គ្រប់បុគ្គលទាំងអស់ ទោះបីជារូបវន្តបុគ្គល ឬជានីតិបុគ្គល និងបើទោះបីជាម៉ាកដែល និងត្រូវយកទៅចុះបញ្ជីនោះជាម៉ាកដែលត្រូវបានប្រើប្រាស់លើទំនិញ ឬសេវារួចហើយក្តី ឬក៏នៅក្តីសុទ្ធសឹងតែអាចជាអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកបានទាំងអស់លើកលែងតែជាជនបរទេសដែលពុំអាចមានសិទ្ធិទទួលបានកិច្ចគាំពារពីច្បាប់របស់កម្ពុជាប៉ុណ្ណោះ។

### ខ. សំណុំឯកសារចាំបាច់ក្នុងការស្នើសុំ

ក្នុងសំណុំឯកសារដែលចាំបាច់សម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងត្រូវបានបំពេញបន្ថែមដោយ អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាកនេះ។[18] អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងឡាយ

---

[17] យោងតាមមាត្រា១០ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[18] យោងតាមមាត្រា៥ (១) នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

ត្រូវបំពេញនូវពាក្យស្នើសុំចុះបញ្ជីមួយច្បាប់ផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវគំរូម៉ាកដែលស្នើសុំចុះបញ្ជី និងបញ្ជាក់នូវប្រភេទនៃទំនិញ ឬសេវាដែលត្រូវបិទម៉ាក នោះក្រោមទម្រង់ជាបញ្ជីមួយផងដែរ។ អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់ជាមុនអំពីការប្រើប្រាស់ ឬមិនប្រើប្រាស់ចំពោះម៉ាកដែលខ្លួនស្នើសុំចុះបញ្ជីនោះនៅពេលដាក់ពាក្យស្នើសុំ។ ពាក្យស្នើសុំចុះបញ្ជីម៉ាកអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី និងទទួលបានគំរូនៃពាក្យស្នើសុំមួយច្បាប់ដោយឥតគិតថ្លៃពីមន្ត្រីកាន់កាប់បញ្ជី និងអាជ្ញាធរទទួលបន្ទុកចុះបញ្ជីម៉ាកនេះ។[19] ក្រោយពីទទួលបានពាក្យស្នើសុំនេះហើយអ្នកស្នើសុំត្រូវបំពេញពាក្យស្នើសុំនេះ និងចុះហត្ថលេខាបញ្ជាក់ជាមុន និងដាក់ត្រលប់ទៅមន្ត្រីកាន់កាប់បញ្ជីវិញ។ គំរូម៉ាកអ្នកដាក់ពាក្យស្នើសុំទាំងឡាយត្រូវផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវគំរូម៉ាកដែលខ្លួនប្រាថ្នាចង់បាន កិច្ចការពារក្រោយពេលចុះបញ្ជីរួច។ គំរូម៉ាកដែលត្រូវបានផ្តល់នេះត្រូវតែគោរពតាមលក្ខខ័ណ្ឌនៃទំហំ សណ្ឋាន សម្លេងអាន ការបកប្រែ និងចំនួនកំណត់ដូចដែលមានចែង។[20] គ្រប់ករណីទាំងអស់គំរូម៉ាកនេះ និងត្រូវប្រើប្រាស់ជាមធ្យោបាយភស្តុតាងដើម្បីបញ្ជាក់នូវសិទ្ធិរបស់ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចប្រឆាំងទល់ និងការក្លែងបន្លំម៉ាកទាំងឡាយនាពេលដែល ម៉ាកនោះត្រូវបានការពារដោយស្របច្បាប់។ ដូចនេះការបញ្ជាក់ពីលក្ខណៈពិសេសរបស់ម៉ាកដោយ អ្នកដាក់ពាក្យស្នើសុំនាពេលចុះបញ្ជីនេះគឺពិតជាមានសារៈសំខាន់ក្រៃលែងដល់កិច្ចការការពារម៉ាកនាពេលអនាគត ហើយអ្នកដែលដាក់ពាក្យស្នើសុំពុំខ្ជីខ្ជានោះឡើយ។ បញ្ជីទំនិញ ឬសេវានៃម៉ាកដែលស្នើសុំចុះបញ្ជី ដើម្បីងាយស្រួលគោរពតាមគោលការណ៍ឯកទេសកម្មនៃម៉ាកអ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់ជូនដល់ មន្ត្រីកាន់កាប់បញ្ជីជាមុននូវប្រភេទទំនិញ ឬសេវាដែលខ្លួន និងប្រើប្រាស់ជាមួយអនាគតម៉ាករបស់ខ្លួន។

### គ. មន្ត្រីមានសមត្ថកិច្ចក្នុងការចុះបញ្ជីម៉ាក

ក្រសួងពាណិជ្ជកម្ម អាជ្ញាធរមានសមត្ថកិច្ចតែមួយគត់ដែលត្រូវទទួលបន្ទុកលើកិច្ចការចុះបញ្ជីម៉ាក គឺជាក្រសួងពាណិជ្ជកម្មដែលតំណាងដោយមន្ត្រីកាន់កាប់បញ្ជី។[21] លើសពីនេះទៅទៀតមានតែក្រសួងពាណិជ្ជកម្មនេះតែមួយគត់ដែលសិទ្ធិអំណាចក្នុងកាន់កាប់ការចុះបញ្ជីម៉ាក ការចុះបញ្ជី

[19] យោងតាមមាត្រា៣ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[20] យោងតាមមាត្រា១១, ១២ នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[21] យោងតាមមាត្រា៥ (ក) ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

សារឡើងវិញការបដិសេធមិនចុះបញ្ជី ការលុបម៉ាកចេញពីបញ្ជី និងការងារផ្សេងទៀតដែលពាក់ព័ន្ធនិងនីតិវិធីចុះបញ្ជីម៉ាកដូចជាការផ្តល់នូវសវនាការជាដើម។[22] សិទ្ធិអំណាចរបស់ក្រសួងពាណិជ្ជកម្មនៅក្នុងការចុះបញ្ជីនេះ គឺការពិតទៅត្រូវបានអនុវត្តដោយផ្ទាល់ ដោយនាយកដ្ឋានចំណុះមួយនៃក្រសួងនេះមានឈ្មោះថា នាយកដ្ឋានកម្មសិទ្ធិបញ្ញា។[23]

## កថាខណ្ឌទី២៖ ការត្រួតពិនិត្យ និងការសម្រេចលើពាក្យស្នើសុំ

ដើម្បីអាចធ្វើការសម្រេចលើពាក្យស្នើសុំចុះបញ្ជី នូវសញ្ញាសម្គាល់ណាមួយជាម៉ាកបានមន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការត្រួតពិនិត្យលើពាក្យស្នើសុំនោះដោយផ្អែកលើ មូលដ្ឋានច្បាប់ជាធរមានពុំមែនដោយឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជីនោះឡើយ។ នៅក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីសម្រេចធ្វើការចុះបញ្ជីឱ្យនោះនីតិវិធីនៃការប្រកាសផ្សាយអំពី ការយល់ព្រមចុះបញ្ជីនេះរួមទាំងការបើកផ្លូវឱ្យមានការប្តឹងជំទាស់សម្រេចនេះ និងត្រូវបានដាក់ឱ្យដំណើរការនៅមុនពេលដែលមានការទទួលស្គាល់សុពលភាព នៃម៉ាកដែលបានចុះបញ្ជីនោះជៀសវាងនូវការចុះបញ្ជីដោយមានបំពានសិទ្ធិម្ចាស់ម៉ាកស្របច្បាប់ណាមួយផ្សេងទៀត។

### ក. មូលដ្ឋាននៃការត្រួតពិនិត្យ

មន្ត្រីកាន់កាប់បញ្ជី និងសម្រេចធ្វើការចុះបញ្ជី ឬសម្រេចការបដិសេធការចុះបញ្ជីម៉ាកដល់បណ្តាពាក្យស្នើសុំចុះបញ្ជីទាំងឡាយណាដែលស្រប ឬពុំស្របតាមលក្ខខ័ណ្ឌតម្រូវនៅក្នុងច្បាប់ និងបទបញ្ញាផ្សេងទៀតស្តីពីម៉ាក។ វាពុំមែនជាសិទ្ធិនោះទេប៉ុន្តែជាកាតព្វកិច្ចចងមន្ត្រីកាន់កាប់បញ្ជីតាមរយៈការបង្កើតឱ្យមានមូលដ្ឋានគតិយុត្តនៃការត្រួតពិនិត្យ និងសម្រេចក្នុងរឿងចុះបញ្ជីម៉ាកនេះ។ មានលក្ខខ័ណ្ឌពីរយ៉ាងដែលមន្ត្រីកាន់កាប់បញ្ជី ត្រូវផ្អែកលើដើម្បីធ្វើការត្រួតពិនិត្យថាពាក្យស្នើសុំនោះត្រឹមត្រូវអាចទទួលចុះបញ្ជីបាន ឬខុសឆ្គងដែលអាចបដិសេធ។[24] ជាដំបូងមន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលលើភាពត្រឹមត្រូវខាងទម្រង់បែបបទ នៃសំណុំឯកសារដាក់ពាក្យស្នើសុំទាំងអស់ថា

---

[22] យោងតាមមាត្រា៥៣ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[23] យោងតាមមាត្រា៥៤ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[24] យោងតាមមាត្រា៨ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

តើមានភាពខ្វះខាតណាមួយកើតមាន ឬទេមុននឹងត្រូវពិនិត្យជាបន្ទាប់លើភាពត្រឹមត្រូវខាងខ្លឹមសារនៃម៉ាកដែលជាកម្មវត្ថុនៃការស្នើសុំចុះបញ្ជីនោះម្តងទៀត។

## ខ. ការត្រួតពិនិត្យលើភាពគ្រប់គ្រាន់នៃឯកសារស្នើសុំចុះបញ្ជី

មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យលើពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវ តាមលក្ខខ័ណ្ឌនៃបែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក។[25] ក្នុងន័យនេះ លក្ខខ័ណ្ឌតម្រូវដែលមន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការត្រួតពិនិត្យគឺសំដៅដល់បញ្ហាលក្ខខ័ណ្ឌតម្រូវខាងរដ្ឋបាល នៃសំណុំលិខិតដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនេះ។[26] នៅក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកបានបំពេញតាមត្រឹមត្រូវនូវរាល់សំណុំឯកសារចាំបាច់នេះហើយមន្ត្រីចុះបញ្ជីសម្រេចទទួលពាក្យស្នើសុំទុកដើម្បីត្រួតពិនិត្យលើភាពត្រឹមត្រូវខាងខ្លឹមសារលើម៉ាកនោះបន្តទៀត។ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ដល់ពាក្យស្នើសុំនោះនូវរាល់ការបរិច្ឆេទ និងលេខរៀងនៃពាក្យស្នើសុំចុះបញ្ជីម៉ាកតាមទម្រង់ដែលបានកំណត់។[27] រួចធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរ ស្តីពីការទទួលយកពាក្យស្នើសុំចុះបញ្ជីម៉ាកនេះជូនទៅអ្នកដាក់ពាក្យស្នើសុំវិញ។ ការស្នើសុំដែលទទួលយកដោយមន្ត្រីចុះបញ្ជីក្រោយពីពិនិត្យលើលក្ខខ័ណ្ឌទម្រង់នេះ និងក្លាយជាកម្មវត្ថុនៃការត្រួតពិនិត្យលើលក្ខខ័ណ្ឌគ្រឹះដែលជាការពិនិត្យលើភាពត្រឹមត្រូវនៃខ្លឹមសាររបស់ម៉ាកដែលស្នើសុំចុះបញ្ជីនោះម្តងទៀត។

## គ. ការត្រួតពិនិត្យលើភាពស្របច្បាប់នៃខ្លឹមសារម៉ាក

ការត្រួតពិនិត្យលើភាពស្របច្បាប់ខ្លឹមសារនៃម៉ាក គឺជាការត្រួតពិនិត្យមួយចំពោះម៉ាកឱ្យសមស្របតាមលក្ខខ័ណ្ឌហើយអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។[28] តាមរយៈការបកស្រាយនេះអាចឱ្យយើងដឹងថាមូលដ្ឋានត្រួតពិនិត្យខ្លឹមសារ ឬលើលក្ខខ័ណ្ឌគ្រឹះនៃម៉ាកដែលចងកាតព្វកិច្ចមន្ត្រីកាន់កាប់បញ្ជី ឱ្យត្រូវតែធ្វើការត្រួតពិនិត្យជាមុន និងដាច់ខាតនោះគឺ

[25] យោងតាមមាត្រា៨ (ក) ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[26] យោងតាមប្រការ២ នៃប្រកាសអន្តរក្រសួងស្តីពី កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និង កម្រៃរដ្ឋបាលពាក់ព័ន្ធនានា ឆ្នាំ ២០០៧

[27] យោងតាមមាត្រា១៦, ៥៤ ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[28] យោងតាមមាត្រា៨ (ខ) ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

សំដៅដល់លក្ខខ័ណ្ឌត្រួតពិនិត្យលើភាពដែលអាចចុះបញ្ជីបាននៃម៉ាកពោល គឺថាតើម៉ាកដែលអាចស្នើសុំចុះបញ្ជីម៉ាកនោះពិតជា ម៉ាកដែលច្បាប់ហាមឃាត់ ឬអត់ជាម៉ាកដែលមិនអាចបែងចែកលក្ខណៈដូចគ្នាឬអត់ និងជាម៉ាកដែលនៅទំនេរ ឬអត់ (លើកលែងតែការត្រួតពិនិត្យលើភាពទំនេរ ឬមិននៅទំនេរដោយសារការដូច ឬប្រហាក់ប្រហែលគ្នា និងម៉ាកដែលបានចុះបញ្ជីមុនរួចហើយ។[29] នៅក្នុងន័យនេះមន្ត្រីកាន់កាប់បញ្ជីពុំមានកាតព្វកិច្ចត្រួតពិនិត្យលើភាពស្រដៀង ឬដូចគ្នានៃម៉ាកដែលកំពុងស្នើសុំចុះបញ្ជី ឬដែលបានចុះបញ្ជី និងដែលទទួលបានការការពាររួចរាល់ហើយនោះទេ។ ប៉ុន្តែពុំមានន័យថា ច្បាប់ស្តីពីម៉ាក ពុំធ្វើការការពារដល់ម៉ាកដែលបានចុះបញ្ជី និងបង់ពន្ធដល់រដ្ឋដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាកនោះផងទេ។ ប៉ុន្តែបទប្បញ្ញត្តិច្បាប់ត្រង់ចំណុចនេះគឺគ្រាន់តែចាត់ទុកសិទ្ធិប្តឹងជំទាស់ និងការស្នើសុំចុះបញ្ជីម៉ាកដែលស្រដៀង ឬដូចគ្នានឹងម៉ាកដែលបានចុះបញ្ជីរួចហើយនោះថាជាសិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចរាល់បានមុននោះតែប៉ុណ្ណោះ។ ពោលគឺមានតែម្ចាស់ម៉ាកដែលបានចុះបញ្ជី មុនគេនោះឯងដែលមានសិទ្ធិប្តឹងប្រឆាំង និងការយកម៉ាកដែលដូច ឬប្រហាក់ប្រហែល និងម៉ាករបស់ខ្លួនទៅស្នើសុំចុះបញ្ជីពីព្រោះនេះគឺជាការការពារផលប្រយោជន៍ផ្ទាល់ខ្លួន។

ដោយផ្អែកលើមូលដ្ឋានការត្រួតពិនិត្យទាំងពីរខាងលើ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មដែលជាមន្ត្រីកាន់កាប់បញ្ជី និងត្រូវធ្វើការសម្រេចសេចក្តីថាត្រូវបដិសេធការចុះបញ្ជី ឬពិតជាអាចចុះបញ្ជីបានដល់ម៉ាកដែលបានស្នើសុំនោះ។

### ឃ.ការបដិសេធពាក្យស្នើសុំ

មន្ត្រីកាន់កាប់បញ្ជី និងធ្វើការបដិសេធចុះបញ្ជីដល់ម៉ាកទាំងឡាយណាដែលបានស្នើសុំពុំអាចបំពេញតាមបាននូវរាល់លើលក្ខខ័ណ្ឌតម្រូវដោយច្បាប់។ ក្នុងករណីនេះ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិចាត់ឱ្យអ្នកស្នើសុំចុះបញ្ជីធ្វើការកែតម្រូវក្នុងរយៈពេល ៤៥ ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែតម្រូវដោយមន្ត្រីកាន់កាប់បញ្ជី។[30] ប៉ុន្តែរយៈពេល ៤៥ ថ្ងៃ នេះអាចនិងត្រូវពន្យាឱ្យបានដោយអំណាចឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជី។ ការមិនធ្វើការកែតម្រូវកំហុសឆ្គងក្នុងរយៈពេលកំណត់ខាងលើ មន្ត្រីកាន់កាប់បញ្ជីអាចចាត់ទុកថាអ្នកដាក់ពាក្យស្នើសុំនោះថាបាន

[29] យោងតាមមាត្រា៤ (ឆ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[30] យោងតាមមាត្រា១០ (ខ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

បោះបង់ពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនទៅវិញហើយ។ ម៉្យាងទៀត តាមសំណើរជាលាយលក្ខណ៍អក្សររបស់អ្នកដាក់ពាក្យស្នើសុំមន្ត្រីកាន់កាប់បញ្ជី អាចទទួលព្រមឱ្យមានសវនាការមួយមុន និងសម្រេចបដិសេធការដាក់ពាក្យស្នើសុំចុះបញ្ជីនេះផងដែរ។[31]

## ខ. លទ្ធភាពប្តឹងទាស់ និងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី

សេចក្តីសម្រេចក្នុងការចុះបញ្ជី ឬបដិសេធចុះបញ្ជីដែលធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជីត្រូវបានចាត់ទុកដូចជាសេចក្តីសម្រេចរដ្ឋបាលទូទៅមួយដែលជាកម្មវត្ថុនៃការប្តឹងទាស់បាន។ នេះគឺជាវិវាទរវាងអ្នកស្នើសុំចុះបញ្ជី និងអាជ្ញាធរចុះបញ្ជីម៉ាក។ ដូចគ្នាទៅ និងសេចក្តីសម្រេចបែបរដ្ឋបាលផ្សេងទៀតផងដែរ។ អ្នកដាក់ពាក្យស្នើសុំដែលមិនពេញចិត្ត និងការសម្រេចរបស់អាជ្ញាធរចុះបញ្ជីអាចជ្រើសរើសរវាងការធ្វើបណ្តឹងរដ្ឋបាលទៅកាន់អ្នកចេញសេចក្តីសម្រេច និងការធ្វើបណ្តឹងទៅកាន់តុលាការមានសមត្ថកិច្ចដើម្បីបដិសេធសេចក្តីសម្រេច រដ្ឋបាលនោះចោលតែម្តងក៏បាន។ បណ្តឹងទាស់ខាងផ្នែករដ្ឋបាលដើម្បីប្រឆាំងទៅ និងសេចក្តីសម្រេចបដិសេធមិនចុះបញ្ជីម៉ាករបស់មន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើទៅកាន់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ាចំណុះ ក្រសួងពាណិជ្ជកម្ម។[32] រីឯបណ្តឹងទៅកាន់តុលាការវិញគឺធ្វើឡើងក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច បើពុំដូច្នេះទៀតសោតអ្នកដាក់ពាក្យស្នើសុំ និងត្រូវបាត់បង់សិទ្ធិ។[33]

## ច. ការយល់ព្រមចុះបញ្ជី

ផ្ទុយទៅវិញបើមន្ត្រីកាន់កាប់បញ្ជី ពិនិត្យឃើញថាពាក្យស្នើសុំ បំពេញតាមត្រឹមត្រូវនូវលក្ខខ័ណ្ឌតម្រូវនានាដោយច្បាប់មន្ត្រីកាន់កាប់បញ្ជី ត្រូវតែធ្វើការចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រចុះបញ្ជីជូនដល់អ្នកដាក់ពាក្យស្នើសុំរួចត្រូវធ្វើការ ចុះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួង-ពាណិជ្ជកម្មស្តីពី ការចុះបញ្ជីម៉ាកថ្មីនេះ។[34] ចំពោះការព្រមចុះបញ្ជីនេះដែលមន្ត្រីកាន់កាប់បញ្ជីក៏មាន

[31] យោងតាមមាត្រា៥៦ (ខ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[32] យោងតាមមាត្រា១៨ (កថាខ័ណ្ឌ២) នៃអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[33] យោងតាមមាត្រា៦២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[34] យោងតាមមាត្រា១០ (ក) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

សិទ្ធិអំណាចក្នុងការសម្រេច យល់ព្រមដោយមានភ្ជាប់លក្ខខ័ណ្ឌ ពោលគឺលក្ខខ័ណ្ឌឱ្យមានការកែតម្រូវការកែសម្រួលការឈប់ទាមទារសិទ្ធិ ឬការកម្រិតសិទ្ធិណាមួយដែលបើលក្ខខ័ណ្ឌភ្ជាប់នេះពុំត្រូវបានយល់ព្រមឱ្យមានដោយអ្នកស្នើសុំចុះបញ្ជី ទេនោះមន្ត្រីកាន់កាប់បញ្ជី អាចសម្រេចការច្រានចោលការស្នើសុំចុះបញ្ជីម៉ាកនោះបាន។ ប៉ុន្តែសិទ្ធិអំណាចយល់ព្រមចុះបញ្ជីម៉ាក ដោយមានលក្ខខ័ណ្ឌនេះពុំឃើញមានចែងទទួលស្គាល់ ឬចែងបើកផ្លូវឱ្យមានណាមួយដោយ ច្បាប់ស្តីពីម៉ាកសោះឡើយ។ មួយវិញទៀត ច្បាប់ស្តីពីម៉ាកក៏ជាអនុក្រឹត្យស្តីពីការអនុច្បាប់ស្តីពីម៉ាកនេះផងដែរ។ ហាក់ពុំខ្វាយខ្វល់អំពីការបញ្ញត្តិនូវរយៈពេលចង់ឱ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងការចេញសេចក្តីសម្រេចយល់ព្រម ឬបដិសេធការចុះបញ្ជីទាល់តែសោះ។ ហេតុនេះចំណោទនៃរយៈពេលនៃការចុះបញ្ជីអាចនិងកើតមានហើយចម្លើយរបស់វាគឺប្រហែលជាអាស្រ័យ និងការអនុវត្តជាក់ស្តែងក៏អាចពុំទៀតទាត់នោះផងដែរ។

### ឆ. ភាតព្វកិច្ចប្រកាសផ្សាយ

ក្រោយពីសម្រេចទទួលព្រមចុះបញ្ជីដល់ម៉ាកដែលបានស្នើសុំរួចមក ក្រសួងពាណិជ្ជកម្ម (តាមរយៈមន្ត្រីកាន់កាប់បញ្ជី) មានកាតព្វកិច្ចក្នុងការប្រកាសផ្សាយនូវសេចក្តីសម្រេចរបស់ខ្លួនអំពីការចុះបញ្ជីម៉ាកទៅក្នុងសៀវភៅព្រឹត្តិបត្រផ្លូវការរបស់ក្រសួង។[35] ការប្រកាសផ្សាយក្រោយការចុះបញ្ជីម៉ាកនេះពុំមែនមានន័យថាម៉ាកនោះត្រូវបានចុះបញ្ជី និងមានសុពលភាពនោះឡើយ។ ប៉ុន្តែការប្រកាសផ្សាយគឺគ្រាន់តែជាផ្នែកមួយនៃនីតិវិធីចុះបញ្ជីប៉ុណ្ណោះ ពោលគឺមានន័យថាម៉ាកដែលបានសម្រេចចុះបញ្ជីឱ្យដោយមន្ត្រីកាន់កាប់បញ្ជី ត្រូវតែរងចាំបញ្ចប់នីតិវិធីប្រកាសផ្សាយនេះទៀតសិនទើបអាចចាត់ទុកបានថា ការចុះបញ្ជីចប់សព្វគ្រប់ត្រឹមត្រូវតាមផ្លូវការច្បាប់បាន។ ការពិតទៅការប្រកាសផ្សាយជាសាធារណៈនេះ មានគោលបំណងសំខាន់ចង់បើក លទ្ធភាពឱ្យដល់តតិយជនទាំងឡាយដែលផលប្រយោជន៍របស់ពួកគាត់អាច និងត្រូវបានបំពានដោយសារសុពលភាពនៃអនាគតម៉ាកដែល និងត្រូវបានចុះបញ្ជីឱ្យនេះអាចធ្វើការប្រឆាំងជំទាស់ និងការចុះបញ្ជីនោះនៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជីម៉ាកនាពេលនោះតែម្តង។ ហើយនេះជាយន្តការដ៏មានប្រសិទ្ធិភាពក្នុងការផ្ទៀងផ្ទាត់ភាពទំនេរនៃម៉ាកដែលបានការពាររួចដោយម្ចាស់ម៉ាកខ្លួនឯងប្រឆាំងទល់ និងការយកទៅចុះបញ្ជីម្តងទៀតដោយអ្នកផ្សេងផងដែរ។

[35] យោងតាមមាត្រា៥៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

### ៤. នីតិវិធីនៃបណ្ដឹងជំទាស់

បណ្ដឹងជំទាស់អាចត្រូវបានធ្វើឡើងដោយតតិយជនដើម្បីប្រឆាំងជំទាស់ណា និងការចុះបញ្ជីម៉ាក។ នីតិវិធីនៃការធ្វើបណ្ដឹងប្រភេទនេះ គឺត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីចុះបញ្ជី ពុំមែនធ្វើនៅតុលាការមានសមត្ថកិច្ចនោះទេ។[36] វាបានបង្កើតនូវអាជ្ញាយុកាល ៩០ ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការមកសម្រាប់បើកលទ្ធភាពដល់បណ្ដឹងជំទាស់ និងការចុះបញ្ជីម៉ាករបស់ជនទាំងឡាយណាដែលមានការពាក់ព័ន្ធផលប្រយោជន៍ក្នុងការចុះបញ្ជីនេះ។ ផុតរយៈពេល ៩០ ថ្ងៃ នេះការចុះបញ្ជីម៉ាកនិងត្រូវចាត់ទុកថាមានសុពលភាពហើយបណ្ដឹងជំទាស់ណាមួយដើម្បីប្រឆាំង និងម៉ាកមានសុពលភាពនេះបានគឺមានតែបណ្ដឹងសុំមោឃភាពនៃម៉ាកនោះចោលប៉ុណ្ណោះ។

## ផ្នែកទី២៖ លក្ខណៈសម្បត្តិទទួលបានការការពារម៉ាក

ម្ចាស់ម៉ាក មុននិងដាក់ពាក្យស្នើសុំចុះបញ្ជីក៏គួរពិនិត្យផងនូវលក្ខណៈសម្បត្តិតម្រូវការចំនួនពីរសម្រាប់ការចុះបញ្ជីម៉ាក។ ម៉ាកត្រូវមានលក្ខណៈលេចធ្លោ ឬអាចញែកដាក់បានចំពោះទំនិញ ឬសេវារបស់សហគ្រាសមួយទៅនិងទំនិញ ឬសេវារបស់សហគ្រាសមួយទៀត។ ម៉ាកមិនត្រូវមានឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ណាមួយដោយសារ តែលក្ខណៈដែលធ្វើឱ្យភាន់ច្រឡំ ឬរំលោភចំពោះសណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អ។

### កថាខណ្ឌទី១៖ សិទ្ធិដែលទទួលតាមរយៈការការពារម៉ាក

សិទ្ធិរបស់ម្ចាស់ម៉ាកលើការប្រើប្រាស់ម៉ាកអាចអនុវត្តបាននៅក្នុងរយៈពេលកំណត់ និងអាចអស់សុពលភាពទៅវិញប្រសិនបើម្ចាស់ម៉ាកពុំមានឆន្ទៈក្នុងការបន្តសុពលភាពនៃម៉ាកនោះទេ។ ក្នុងករណីដែលម៉ាកមួយត្រូវបានអនុវត្តឱ្យចុះបញ្ជីម្ចាស់ម៉ាកត្រូវប្រើប្រាស់ម៉ាក លើផលិតផល ឬសេវាតាមការស្នើសុំ។ សិទ្ធិរបស់ម្ចាស់ម៉ាកអាចត្រូវបានបាត់បង់ និងអាចត្រូវបានលុបចេញពីបញ្ជីម៉ាកប្រសិនបើម្ចាស់ម៉ាកមិនបានអនុវត្តនូវសិទ្ធិរបស់ខ្លួនតាមការកំណត់ដោយច្បាប់។ ចំពោះដែនកំណត់

[36] យោងតាមមាត្រា១០ (ក) នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

អនុវត្តសិទ្ធិនៃបណ្តឹងមោឃភាពក្នុង វិស័យនៃប្រកាសនីយបត្រតក្កកម្ម[37] លក្ខខណ្ឌនៃភាពថ្មីជាលក្ខខណ្ឌដាច់ខាត នៃតក្កកម្មក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីការពារតក្កកម្មមួយ។ ប៉ុន្តែនៅក្នុងវិស័យម៉ាកវិញលក្ខខណ្ឌនៃភាពថ្មីនេះជាលក្ខខណ្ឌបន្ទាប់បន្សំប៉ុណ្ណោះមានន័យថា ភាពថ្មីពុំមែនជាលក្ខខណ្ឌដាច់ខាតពុំអាចចុះបញ្ជីនោះទេ។ ការអនុវត្តន៍សិទ្ធិ នៃបណ្តឹងរបស់តតិយជនម្ចាស់ម៉ាកគោលការណ៍នៃលក្ខណៈពិសេសនៃម៉ាក និងគោលការណ៍ការពារតាមដែនដីនៃម៉ាក។

## កថាខ័ណ្ឌទី២៖ គោលការណ៍ការពារតាមទំហំដែនដីនៃម៉ាក

គោលការណ៍ការពារម៉ាកតាមដែនដី មានន័យថា គឺជាម៉ាកមួយនិងត្រូវបានការពារនៅប្រទេសកម្ពុជាប្រសិនបើម៉ាកនោះត្រូវបានចុះបញ្ជីនៅកម្ពុជា។ ដូចនេះម្ចាស់ម៉ាកដែលបានចុះបញ្ជីនៅកម្ពុជាពុំអាចធ្វើបណ្តឹងប្រឆាំង និងតតីយជនណាមួយដែលបានយកមកប្រើប្រាស់ ឬចុះបញ្ជីម៉ាករបស់ខ្លួននៅឯបរទេសឡើយ។ ប៉ុន្តែគោលការណ៍នេះមិនត្រូវយកមកអនុវត្តឡើយចំពោះម៉ាកដែលបានទទួលសិទ្ធិអាទិភាពក្នុងការចុះបញ្ជី និងម៉ាកល្បី។

## គ. ម៉ាកដែលត្រូវបានហាមឃាត់ក្រោមច្បាប់ជាតិ

ម៉ាក គឺជាសញ្ញាដែលមើលឃើញហើយអាចលក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ មានតែម៉ាកដែលអាចមើលឃើញទេទើបអាចត្រូវបានទទួលចុះបញ្ជី និងការការពារនៅក្នុងប្រទេសកម្ពុជា។ ម៉ាកដែលមើលមិនឃើញមិនត្រូវបានរាប់បញ្ចូលទេ ដូចជាអាទិ៍ ម៉ាកជាសម្លេង ក្លិន ឬរស់ជាតិ។ លើសពីនេះទៅទៀត គ្រប់ប្រភេទនៃម៉ាកមិនអាចទទួលឱ្យចុះបញ្ជីបានឡើយប្រសិនម៉ាកទាំងនោះជាប្រភេទម៉ាកដែលច្បាប់ម៉ាកបានហាមឃាត់។[38]

---

[37] ប្រកាសនីយបត្រតក្កកម្ម គឺជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារតក្កកម្ម។ យោងតាមច្បាប់ស្តីពី ប្រកាសនីយបត្រ តក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០៦។

[38] យោងតាមមាត្រា៤ (ក,ខ,គ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

### កថាខ័ណ្ឌទី៣៖ អនុភាពនៃការចុះបញ្ជីម៉ាក

ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មានសិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក និងហាមឃាត់តតិយជនពីការប្រើប្រាស់ម៉ាករបស់ខ្លួនតាមគ្រប់រូបភាព ដោយគ្មានការអនុញ្ញាតជាមុនពីម្ចាស់ម៉ាក។ តាមរយៈការចុះបញ្ជីម៉ាកមួយម្ចាស់ម៉ាក និងទទួលបាននូវកិច្ចការពារស្របច្បាប់នៅកម្ពុជាក្នុងរយៈពេលកំណត់ដោយច្បាប់ និងផ្ដល់នូវសិទ្ធិក្នុងការប្រើប្រាស់ម៉ាកដល់ម្ចាស់ម៉ាក។ ការប្រើប្រាស់ម៉ាកអាចជាការប្រើប្រាស់លើផលិតផល ឬសេវា ការផលិតឡើងវិញការផ្ទេរសិទ្ធិលើម៉ាកឱ្យទៅតតិយជនដោយទទួលបានមកវិញនូវតម្លៃតបស្នងសមរម្យ។

## ផ្នែកទី៣៖ វិធានគតិយុត្តកម្ពុជាដែលទាក់ទងទៅ និងម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

នីតិវិធីក្នុងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ សម្រាប់ប្រទេសកម្ពុជា គឺមាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ដែលជាអង្គភាពមានភារៈកិច្ចក្នុងការចុះបញ្ជី និងការពារម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដោយមានអនុភាពនៅក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។[39]

### កថាខ័ណ្ឌទី១៖ សិទ្ធិ និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ការស្នើសុំការដាក់ពាក្យចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ គឺត្រូវធ្វើការដាក់ពាក្យស្នើសុំនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្នុងនាមជាការិយាល័យដើមទទួលបន្ទុកក្នុងការចុះបញ្ជីម៉ាក ព្រមទាំងអត្ថប្រយោជន៍នានាក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។[40]

#### ក. សិទ្ធិក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីហើយក្នុងនាមបុគ្គលនោះនៅក្នុង នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មដែលជាការិយាល័យដើមអាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ក្នុងក្របខណ្ឌអន្តរជាតិ ប្រសិនបើរូបវន្តបុគ្គលនោះជា៖

[39] យោងតាមប្រការ៣ (៤,៦) នៃប្រកាស ស្ដីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

[40] យោងតាមប្រការ៣ (៥) នៃប្រកាស ស្ដីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

- ជាជនជាតិខ្មែរ ឬ
- មានលំនៅដ្ឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ
- មានគ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្ម ស្របច្បាប់និងកំពុងដំណើរការក្នុងព្រះរាជាណាចក្រកម្ពុជា។

ពាក្យស្នើសុំ និងឯកសារយោងសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងឯកសារទំនាក់ទំនងរវាងការិយាល័យអន្តរជាតិ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មត្រូវធ្វើជាភាសាអង់គ្លេស។[41]

### ខ. ឯកសារ ឬលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្របខណ្ឌអន្តរជាតិ

ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានកំណត់លក្ខខណ្ឌអប្បរមាដូចខាងក្រោម៖

- ឈ្មោះ អាសយដ្ឋានពិតប្រាកដ និងព័ត៌មានមានទំនាក់ទំនងលម្អិតរបស់អ្នកស្នើសុំ ព្រមទាំងឈ្មោះ អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងលម្អិតរបស់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ប្រសិនបើមាន
- គំនូម៉ាកស្របតាមលក្ខខណ្ឌតម្រូវ នៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ
- យថាប្រភេទ ទំនិញនិងសេវា ដែលនិងត្រូវស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និង
- ប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជី។

ពាក្យស្នើសុំអាចយកមកដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម រៀងរាល់ម៉ោងធ្វើការ។[42]

---

[41] យោងតាមប្រការ៤ នៃប្រកាស ស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

[42] យោងតាមប្រការ៥ នៃប្រកាស ស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

### គ. កម្រៃដាក់ពាក្យ

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបង់កម្រៃសេវារដ្ឋបាល និងកម្រៃសេវាពាក់ព័ន្ធផ្សេងទៀត តាមប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។[43]

### ឃ. កម្រៃចុះបញ្ជីម៉ាកអន្តរជាតិ

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបង់កម្រៃតាមការកំណត់របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

## កថាខណ្ឌទី២៖ នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

### ក. ការត្រួតពិនិត្យពាក្យស្នើសុំ

ក្នុងនាមជាការិយាល័យដើមទទួលបន្ទុកក្នុងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវផ្ទៀងផ្ទាត់ព័ត៌មានលម្អិតពាក់ព័ន្ធទាំងឡាយនៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិឱ្យដូចទៅ នឹងព័ត៌មានលម្អិតដែលមាននៅក្នុងពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល។[44]

### ខ. ការបញ្ជាក់ភាពត្រឹមត្រូវ

នៅពេលដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ បានបំពេញតាមលក្ខខណ្ឌកំណត់រួចហើយ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជាក់លើពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនោះអំពីភាពត្រឹមត្រូវ ដោយចុះកាលបរិច្ឆេទទទួលពាក្យស្នើសុំរួចបញ្ជូលទៅការិយាល័យអន្តរជាតិ។ នៅពេលដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិមិនបានបំពេញតាមលក្ខខណ្ឌកំណត់ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម មិនត្រូវបញ្ជូនពាក្យ

[43] យោងតាមប្រការ៦ នៃប្រកាស ស្ដីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

[44] យោងតាមប្រការ៨ នៃប្រកាស ស្ដីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

ស្នើសុំនោះទៅការិយាល័យអន្តរជាតិឡើយ ប៉ុន្តែត្រូវជូនដំណឹងទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេល ០៧ ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខា។[45]

## គ. ការអស់សុពលភាព នៃពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល

អនុលោមតាមមាត្រា ៦ នៃពិធីសារទីក្រុងម៉ាឌ្រីដ នៅពេលដែលពាក្យស្នើសុំគោល ឬការចុះបញ្ជីគោលលែងមានសុពលភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាការិយាល័យដើមដែលជានាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីបញ្ហានេះ និងត្រូវស្នើសុំលុបការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចំពោះទំនិញនិងសេវាដែលពាក់ព័ន្ធ។[46]

[45] យោងតាមប្រការ៩ (១,២) នៃប្រកាស ស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

[46] យោងតាមប្រការ១០ នៃប្រកាស ស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឆ្នាំ២០១៦

# ជំពូកទី៣
# វិធានការក្នុងការដោះស្រាយវិវាទម៉ាកនៅកម្ពុជា

គឺជាការរំលោភបំពាន់ទៅលើម៉ាកដោយជនណាម្នាក់ ក្រៅពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយ ដោយពុំមានការយល់ព្រមពីម្ចាស់ម៉ាក។[47]

## ផ្នែកទី១៖ ចរិកលក្ខណៈនៃអំពើរំលោភបំពាន់ម៉ាក

ជាទូទៅការប្រើប្រាស់ម៉ាកគ្រប់រូបភាព ដោយពុំមានការអនុញ្ញាតពីម្ចាស់ម៉ាក ត្រូវបានចាត់ទុកថា ជាអំពើរំលោភម៉ាក។ គោលការណ៍នេះត្រូវអនុវត្តតែចំពោះការប្រើប្រាស់ម៉ាកនៅក្នុងវិស័យពាណិជ្ជកម្មតែប៉ុណ្ណោះ មានន័យថា ការប្រើប្រាស់ជាលក្ខណៈឯកជនមិនត្រូវស្ថិតនៅក្នុងការអនុវត្តនៃច្បាប់ការពារម៉ាកនោះទេ។

### កថាខណ្ឌទី១៖ សញ្ញាណនៃការរំលោភបំពានម៉ាក

ក្នុងន័យទូទៅអំពើរំលោភបំពានសិទ្ធិលើម៉ាកត្រូវបានកំណត់ថា ជាការប្រើប្រាស់ម៉ាកគ្រប់រូបភាពដោយពុំមានការអនុញ្ញាតជាមុខពីម្ចាស់ម៉ាក។ នៅក្នុងក្របខណ្ឌ នៃការអនុវត្តច្បាប់ម៉ាកអំពើរំលោភម៉ាកអាចកើតមានឡើងតាមរយៈបីរូបភាព គឺការក្លែងបន្លំម៉ាក ការធ្វើត្រាប់តាមម៉ាក និងការប្រើប្រាស់ម៉ាកគេដោយពុំមានការអនុញ្ញាត។ ផលិតផលដែលកើតចេញពីអំពើខាងលើនេះត្រូវបានចាត់ទុកថា ជាទំនិញដែលពាក់ម៉ាកក្លែងក្លាយ។ ដូច្នេះហើយ សញ្ញាដែលស្រដៀងទៅ និងស្លាកសញ្ញាដែលបានចុះបញ្ជី យ៉ាងជិតស្និទ្ធនោះគឺជាសញ្ញាផ្ទុយគ្នា។ សញ្ញាបែបនេះទំនងជាធ្វើឱ្យអតិថិជនយល់ច្រឡំអំពីប្រភពនៃផលិតផល ឬសេវាកម្ម។[48]

---

[47] យោងតាមមាត្រា២៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[48] ដកស្រង់ចេញពីអត្ថបទ *«ការប៉ះទង្គិចម៉ាកសញ្ញានិងនិយមន័យច្បាប់»* បោះពុម្ពផ្សាយ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ តំណរវេបសាយចូលទស្សនា <https://definitions.uslegal.com/c/conflicting-marks/>

## កថាខណ្ឌទី២៖ សំណើសុំធ្វើសវនាការនៃម៉ាក

ការស្នើសុំធ្វើសវនាការមួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយផ្ញើទៅមន្ត្រីកាន់កាប់បញ្ជីនៅពេលទទួលបានពាក្យស្នើសុំនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ០១ (មួយ) ខែ មុនកាលបរិច្ឆេទដែលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវអញ្ជើញមកចូលរួមក្នុងសវនាការ។[49]

### ក. ភស្តុតាង

ភស្តុតាង គឺជាសេចក្តីពិពណ៌នាអំពីការពឹងផ្អែកលើភស្តុតាងរបស់ភាគីមួយ ឬច្រើនដែលពាក់ពន្ធ័កម្រិតនៃតម្រូវការព័ត៌មានលំអិតអាស្រ័យទៅលើកំរិតពាក់ព័ន្ធ និងការពឹងផ្អែកលើផ្នែកផ្សេងៗនៃភស្តុតាង។[50]

### ខ. សារណាការពារ

ប្រសិនបើម្ចាស់ម៉ាកដែលបានចុះបញ្ជីមាន គោលបំណងពឹងផ្អែកទៅលើសារណាការពារប្រឆាំងទៅ និងបណ្តឹងជំទាស់ខ្លួនត្រូវដាក់សារណាការពារជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៩០ ថ្ងៃគិតចាប់ថ្ងៃជូនដំណឹងជំទាស់ត្រូវបានផ្ញើទៅដល់ម្ចាស់ម៉ាកដែលបានចុះបញ្ជី។ ប្រសិនបើម្ចាស់ម៉ាកដែលបានចុះបញ្ជីមិនបានដាក់សារណាការពារក្នុងរយៈពេលកំណត់ ខាងលើទេការចុះបញ្ជីនោះត្រូវចាត់ទុកថាបានបោះបង់ចោល ដោយម្ចាស់ម៉ាកដែលបានចុះបញ្ជី ប៉ុន្តែរយៈពេលនៃការដាក់សារណាការពារអាចពន្យាពេលបាន។[51]

---

[49] យោងតាមមាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០

[50] យោងតាមមាត្រា៣៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[51] យោងតាមមាត្រា៥៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

### គ. ការប្តឹងជំទាស់ និងមន្ត្រីកាន់កាប់បញ្ជី

ការប្តឹងជំទាស់ គឺជាអ្នកដែលដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ាអំពីការបដិសេធមិនព្រមចុះបញ្ជីរបស់មន្ត្រីកាន់កាប់បញ្ជីទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្ម ឬតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី។[52] សម្រាប់ភាគីមានផលប្រយោជន៍មានសិទ្ធិប្តឹងតវ៉ាអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ឬទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ០៣ ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា។[53]

### ឃ. ការប្តឹងជំទាស់ និងការស្នើសុំចុះបញ្ជី

ដើម្បីរក្សាសុពលភាពនៃការចុះបញ្ជីម៉ាក ឬការចុះបញ្ជីម៉ាកសារឡើងវិញម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬមិនបានប្រើប្រាស់ម៉ាកក្នុងរយៈពេល ០១ ឆ្នាំ បន្ទាប់ពីខួបលើកទី ០៥ ឆ្នាំ នៃកាលបរិច្ឆេទចុះបញ្ជីម៉ាក។[54]

### ង. មោឃភាព និងការលុបចេញពីបញ្ជី

គ្រប់ជនណាដែលមានការពាក់ព័ន្ធអាចស្នើសុំមក ក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន។[55] ក្រសួងពាណិជ្ជកម្ម ត្រូវទុកការចុះបញ្ជីម៉ាកជាមោឃៈភាពប្រសិនបើជនដែលស្នើសុំឱ្យមានមោឃៈភាពនោះបង្ហាញថាមាន លក្ខខណ្ឌណាមួយសម្រាប់មោឃភាពនៃការចុះបញ្ជីម៉ាកត្រូវមានអនុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីហើយត្រូវបានកត់ត្រា និងបោះពុម្ពផ្សាយជាបន្ទាន់។ ក្រសួងពាណិជ្ជកម្ម មានសិទ្ធិលុបចោលម៉ាកដែលបានចុះបញ្ជីរួចដោយមានអ្នកដាក់ពាក្យសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើ សុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយតាម

[52] យោងតាមមាត្រា១៨នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦

[53] យោងតាមមាត្រា៦២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០២

[54] យោងតាមមាត្រា១៧ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦

[55] យោងតាមមាត្រា១៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

រយៈការដែលបានកំណត់នោះ។[56] ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយស្នើសុំលុបក្នុងរយៈពេល ៩០ ថ្ងៃ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយមិនគោរពតាមលក្ខខណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់។ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយលែងមានអាសយដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជាជឿជាក់ដោយផ្អែកលើភស្តុតាងថាម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយមិនមែនជាម្ចាស់ស្របច្បាប់ដោយជឿជាក់ថាម៉ាក ដែលបានចុះបញ្ជីរួចហើយប្រហាក់ប្រហែល ឬដូចទៅ និងម៉ាកល្បីដែលជាកម្មសិទ្ធិរបស់ភាគីទីបី។ ម៉ាកដែលបានចុះបញ្ជីរួចប៉ុន្តែមិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥ ឆ្នាំ ត្រូវលុបចេញពីបញ្ជីម៉ាក។ ប្រសិនបើម្ចាស់ម៉ាកបង្ហាញថាកាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាកហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេម៉ាកនោះ និងមិនត្រូវលុបចេញពីបញ្ជីឡើយ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យក្រសួងពាណិជ្ជកម្ម លុបម៉ាកចេញពីបញ្ជី ក្នុងរយៈពេល ១ ខែ មុនកាលបរិច្ឆេទ ៥ ឆ្នាំ នៃការមិនប្រើប្រាស់ ឬក្រោយកាលបរិច្ឆេទនេះ។

## ច. ការរំលោភ និងវិធានការដោះស្រាយ

ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយពុំមានការយល់ព្រមពីម្ចាស់ម៉ាក។[57] ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនិងជនណាម្នាក់ដែលប្រើប្រាស់ ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម។ ម្ចាស់ម៉ាកដើមក៏មានសិទ្ធិប្តឹងផងដែរចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែល និងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនិងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅ និងទំនិញ ឬសេវានៃម៉ាកដែលបានចុះបញ្ជីរួចហើយនោះហើយដែលអាចបណ្តាលឱ្យមានការភាន់ច្រឡំជាសាធារណៈ។ សម្រាប់សុពលភាពក្នុងការចុះបញ្ជីម៉ាក និងការចុះបញ្ជីសារជាថ្មីត្រូវតែជាម៉ាកដែលបានចុះបញ្ជីហើយមានសុពលភាព ១០ ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី។[58] តាមរយៈការស្នើសុំការចុះបញ្ជីម៉ាកមួយអាចធ្វើឡើងសារជាថ្មីសំរាប់រយៈពេល ១០ ឆ្នាំ ម្តងទៀតជាបន្តបន្ទាប់ក្នុងលក្ខខ័ណ្ឌដែលម្ចាស់ម៉ាកដើមបង់អាករចុះបញ្ជី

[56] យោងតាមមាត្រា១២ (ខ,ឃ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[57] យោងតាមមាត្រា១១ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[58] យោងតាមមាត្រា១២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

ជាថ្មីតាមការកំណត់។ ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយមុនពេលដែលច្បាប់នេះចូលជាធរមានអ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដែលចង់បានការពារដោយផ្អែកទៅតាមច្បាប់កំណត់។ ការអនុគ្រោះចំពោះការយឺតយ៉ាវក្នុងការចុះបញ្ជីសាជាថ្មីត្រូវបានអនុញ្ញាតត្រឹមតែរយៈពេល ៦ ខែ។ ការប្រើប្រាស់នូវសញ្ញាដូច ឬប្រហាក់ប្រហែលដែលធ្វើឱ្យភាន់ច្រឡំទៅ និងម៉ាកល្បីដែលបានចុះបញ្ជីរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានការយល់ព្រមពីម្ចាស់ម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះប្រសិនបើសញ្ញាទាំងនោះត្រូវបានយកមកប្រើប្រាស់ទាក់ទងទៅ និងទំនិញ ឬសេវាដែលដូច ឬប្រហាក់ប្រហែល និងទំនិញ ឬសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច។[59] ទាក់ទងទៅ និងទំនិញ ឬសេវាដែលមិនដូច ឬមិនប្រហាក់ប្រហែលទៅ និងទំនិញ ឬសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួចហើយការប្រើប្រាស់នូវសញ្ញាទាក់ទងនិងទំនិញ ឬសេវានោះបញ្ជាក់នូវការពាក់ព័ន្ធគ្នារវាងទំនិញ និងសេវានោះជាមួយ និងម្ចាស់នៃម៉ាកល្បីហើយដែលផលប្រយោជន៍នៃម្ចាស់ម៉ាកល្បីអាច និងត្រូវខូចខាតដោយការដោយការប្រើប្រាស់នោះ។ ការប្រើប្រាស់នូវសញ្ញាដែលដូច ឬប្រហាក់ប្រហែល និងម៉ាកល្បីដែលមិនបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បីជាការរំលោភលើម៉ាកល្បីនោះប្រសិនបើសញ្ញានោះត្រូវបានប្រើប្រាស់ទាក់ទង និងទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែល និងទំនិញ ឬសេវានៃម៉ាកល្បីនោះ។ តាមរយៈសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណតុលាការអាចចេញនូវ សេចក្តីសម្រេចបណ្តោះអាសន្នមួយដើម្បី ទប់ស្កាត់ការរំលោភបំពាន ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងមាត្រា២១ មាត្រា២២ និងមាត្រា២៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងសម្រេចឱ្យសងការខូចខាតហើយផ្តល់នូវដំណោះស្រាយផ្សេងៗទៀតដែលមានចែងក្នុងច្បាប់ជាធរមាន។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណបានស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការ ដើម្បីឱ្យជួសជុលនូវសំណងដ៏ជាក់លាក់មួយប៉ុន្តែបើម្ចាស់ម៉ាកបានបដិសេធ ឬខកខានមិនបានធ្វើតាមអ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន។

### ឆ. សិទ្ធិបេតិកភណ្ឌរបស់ម្ចាស់ម៉ាក

សិទ្ធិបេតិកភណ្ឌរបស់ម្ចាស់ម៉ាក គឺសំដៅលើសិទ្ធិក្នុងការធ្វើអាជីវកម្មតាមគ្រប់រូបភាពនិងសិទ្ធិក្នុងការផលិតឡើងវិញនូវម៉ាករបស់ខ្លួនតាមប្រភេទនៃទំនិញ ឬសេវាស្របតាមប្រភេទនៃទំនិញ

[59] យោងតាមមាត្រា២៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

ឬសេវាដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី។ លើសពីនេះទៅទៀតដោយហេតុថាម៉ាកជាទ្រព្យអរូបិយ ម្ចាស់ម៉ាកអាចជាការដាក់បញ្ចាំទ្រព្យនេះដើម្បីទទួលបាននូវដើមទុនក្នុងការពង្រីកអាជីវកម្ម ឬអភិវឌ្ឍ ពាណិជ្ជកម្ម និងអាចធ្វើមូលនិធិពាណិជ្ជកម្មសម្រាប់សហគ្រាស។ រាល់ប្រតិបត្តិការដូចបានរៀបរាប់ ខាងលើត្រូវចុះបញ្ជី និងកត់ត្រាជាមួយមន្ត្រីកាន់កាប់បញ្ជីដើម្បីជាលក្ខខណ្ឌតតាំងជាមួយតតិយជន។ ការខកខានមិនបានចុះបញ្ជីនូវប្រតិបត្តិផ្ទេរ ឬបញ្ចាំម៉ាកពីម្ចាស់ដើមទៅ តតិយជនដោយពុំបានធ្វើ កិច្ចសន្យានៃប្រតិបត្តិការនីមួយៗ ដូច្នេះពុំអាចមានសុពលភាពក្នុងការតតាំងជាមួយ តតិយជនបាន ឡើយ។

## ផ្នែកទី២៖ ដំណោះស្រាយតាមផ្លូវតុលាការ

ការដោះស្រាយតាមផ្លូវតុលាការ គឺជាវិធានការមួយដែលត្រូវបានអនុវត្តតាមរយៈបណ្ដឹង ដែលភាគីនៃការមានវិវាទដាក់ទៅកាន់តុលាការ។ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់របស់ម្ចាស់ ម៉ាកក្នុងគោលដៅដោយរួមមានការទប់ស្កាត់ការ រំលោភបំពានដែលកំពុងកើតមានឡើង ឬការ រំលោភបំពានដែលបម្រុង និងកើតមាននាពេលអនាគតដោយធ្វើការរក្សាទុកនូវ ភស្តុតាងដែល ពាក់ព័ន្ធជាក់ស្ដែង និងធ្វើការការពារព្យសនកម្មដែលមិនអាចជួសជុលបានចំពោះម្ចាស់ម៉ាក។

### កថាខ័ណ្ឌទី១៖ វិធានការតាមច្រកព្រំដែន

ប្រទេសកម្ពុជាមានច្រកទ្វារព្រំដែនជាលក្ខណៈអន្តរជាតិ និងច្រករបៀងដែលច្រកទាំងនេះ បានក្លាយជាតំបន់សេដ្ឋកិច្ចមួយដែលជំរុញឱ្យសេដ្ឋកិច្ចប្រទេសម្ពុជាកើនឡើងជាលំដាប់។ ក្នុងនោះគឺ មានសកម្មភាពការនាំទំនិញចេញចូលដោយមានលក្ខណៈដ៏សំបូរបែប។ ដោយហេតុនេះហើយទើប ប្រទេសកម្ពុជាបានបង្កើតច្បាប់ស្ដីពីអំពីម៉ាក ដែលមានចែងអំពីលក្ខណៈការពារតាមច្រកព្រំដែនក្នុង ការនាំចេញចូលផលិតដោយវាគឺជាវិធានការដែនអនុញ្ញាតឱ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចហើយ អាចធ្វើពាក្យបណ្ដឹងទៅរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យព្យួរទុកនូវការ ធ្វើបែបបទទំនិញ ណាដែលសង្ស័យថាមានម៉ាកក្លែងក្លាយ ដោយគ្រាន់តែបង្ហាញនូវភស្តុតាង

ច្បាស់លាស់ថាគាត់ជាម្ចាស់នៃម៉ាកដែលចុះបញ្ជី។[60] វិធានការនេះ គឺអនុញ្ញាតចំពោះតែម៉ាកដែលបានចុះបញ្ជីតែប៉ុណ្ណោះនេះមានន័យថា ប្រសិនបើម៉ាកនោះមិនបានចុះបញ្ជីទេ គឺមិនអាចធ្វើពាក្យបណ្ដឹងតាមវិធានការនេះបានទេ។ ក្រៅពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ នៅមានបុគ្គលមួយចំនួនទៀតដែលអាចធ្វើបណ្ដឹងបានដូចជា៖ អ្នកដែលទទួលអាជ្ញាប័ណ្ណ ឬភ្នាក់ងារតំណាងម៉ាកស្របច្បាប់ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី។[61]

### ក. សមត្ថកិច្ចតាមមាត់ច្រកព្រំដែន

យោងតាមមាត្រា៣៥ នៃច្បាប់ស្ដីពីម៉ាក បានបញ្ជាក់ថាបុគ្គលដែលជាអ្នកអនុវត្តនូវវិធានការតាមមាត់ច្រកព្រំដែនរួចមាន៖ រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ។ អាជ្ញាធរមានសមត្ថកិច្ចនៅទីនេះបើផ្អែកតាម មាត្រា៣៦ នៃអនុក្រឹត្យស្ដីពីច្បាប់ម៉ាក ដោយអាជ្ញាធរមានសមត្ថកិច្ចមានភារៈកិច្ចត្រួតពិនិត្យព្រមបង្ក្រាបការក្លែងបន្លំនៃទំនិញ។

### ខ. ពាក្យបណ្ដឹង

ពាក្យបណ្ដឹងដែលបានលើកឡើងពីខាងលើនេះ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវភ្ជាប់មកជាមួយនូវ[62]៖

- វិញ្ញាបនបត្រចុះបញ្ជីម៉ាក។
- សេចក្ដីថ្លែងពីមូលហេតុពីការប្ដឹង និងជាពិសេសភស្តុតាងជំបូងដែលបង្ហាញថាទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន។
- ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផងប្រសិនបើមានសំណួរពរ។

---

[60] យោងតាមមាត្រា៣៥ នៃច្បាប់ស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០២

[61] យោងតាមមាត្រា៣៨ (១) នៃអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦

[62] យោងតាមមាត្រា៣៦ នៃច្បាប់ស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០២

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង និងតំណាងរបស់គេដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់។

- លិខិតអនុញ្ញាតពីម្ចាស់ម៉ាក ដែលបានចុះបញ្ជីប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ។

- កម្រៃរដ្ឋបាលរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ពាក្យបណ្តឹងនេះមានសុពលភាព ៦០ ថ្ងៃ គិតពីថ្ងៃទទួលពាក្យប្តឹង។ បើផុតសុពលភាពនេះ អ្នកដាក់ពាក្យត្រូវធ្វើពាក្យប្តឹងឡើងវិញបើសំណូមពរនៃការឃាត់ និងត្រួតពិនិត្យទំនិញនៅមាននៅឡើយ។[63] ពាក្យបណ្តឹងនីមួយៗត្រូវអមជាមួយនូវការទូទាត់កម្រៃរដ្ឋបាលដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។

## គ. ការធានា និងការបដិសេធចំពោះការឃាត់ទុក

អ្នកដាក់ពាក្យត្រូវមានកាតព្វកិច្ចបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារអ្នកនាំចូលអ្នកទទួលអ្នកនាំចេញ ឬម្ចាស់ទំនិញ និងអាជ្ញាធរមានសមត្ថកិច្ចប្រសិនបើមានការស្នើពីររដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់នេះត្រូវបានកំណត់តាមរបៀប និងបែបបទមួយដែលមិនត្រូវឱ្យរារាំងដល់ការអនុវត្តនីតិវិធី នេះដោយមិនសមហេតុផល។[64] លើសពីនេះទៀតអ្នកដាក់ពាក្យមានភារៈកិច្ចទទួលខុសត្រូវចំពោះមធ្យោបាយដឹកជញ្ជូនឃ្លាំង ដែលត្រូវផ្ទុកទំនិញនៅពេលឃាត់រក្សាទុក។ ហើយឃ្លាំងស្តុកទំនិញត្រូវស្ថិតនៅក្នុងបរិវេនកំពង់ផែ ឬក្នុងបរិវេនមាត់ច្រកនាំចេញ

[63] យោងតាមមាត្រា៣៨ (កថាខ័ណ្ឌ៣) នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦

[64] យោងតាមមាត្រា៣៨ នៃច្បាប់ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

នាំចូលដែលបានកំណត់ និងគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ចតាមច្បាប់ជាធរមាន។ រាល់ការចំណាយនានាក្នុងការចោលទំនិញមិនស្របច្បាប់គឺជាកាតព្វកិច្ចរបស់អ្នកដាក់ពាក្យ។[65]

### ឃ. ការបដិសេធចំពោះការឃាត់ទុក

ក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំ ឃាត់ទំនិញមិនបានអនុវត្តកាតព្វកិច្ច តាមការទាមទារណាមួយរបស់អង្គភាពគយ និងរដ្ឋាករ ឬកាំកុងត្រូលមានសិទ្ធិបដិសេធការស្នើសុំឃាត់ទំនិញដែលសង្ស័យ ឬមានម៉ាកក្លែងក្លាយ។[66]

### ង. ចំណាត់ការរបស់សមត្ថកិច្ចតាមច្រកព្រំដែន

ក្នុងរយៈពេល ១០ ថ្ងៃ ក្នុងថ្ងៃធ្វើការបន្ទាប់ពីបានទទួលនូវពាក្យបណ្ដឹង (របស់ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ) រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្ដឹងថាពាក្យបណ្ដឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថា ត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកសម្រាប់ពិចារណានៅពេលក្រោយ។[67] រដ្ឋបាលគយ និងរដ្ឋាករ ត្រូវជូនព័ត៌មានភ្លាមឱ្យម្ចាស់សិទ្ធិអំពីទីកន្លែង និងថ្ងៃដែលព្យួរទុកនូវការធ្វើបែបបទរបស់គយហើយរដ្ឋបាលគយ និងរដ្ឋាករ ក៏អាចស្នើឱ្យម្ចាស់សិទ្ធិផ្ដល់នូវព័ត៌មានទាំងឡាយណាដែលអាចជាជំនួបក្នុងការអនុវត្តនូវអំណាចរបស់ខ្លួនផងដែរ។[68]

#### ង.១ រយៈពេលនៃការព្យួរទុក

ក្នុងពេលយល់ព្រមតាមកម្មវត្ថុនៃពាក្យបណ្ដឹងខាងលើនេះ រដ្ឋបាលគយ និងរដ្ឋាករ ត្រូវព្យួរទុកនូវការធ្វើបែបទំនិញដែលមានទាក់ទងទៅ និងពាក្យបណ្ដឹង។ ការព្យួរទុកនេះត្រូវនៅជាធរមាន

---

[65] យោងតាមមាត្រា៨០ នៃច្បាប់ស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦

[66] យោងតាមមាត្រា៨១ នៃច្បាប់ស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦

[67] យោងតាមមាត្រា៣៧ នៃច្បាប់ស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦

[68] យោងតាមមាត្រា៤៤ នៃច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

ក្នុងរយៈពេលដំបូង និងក្នុងរយៈពេលដែលបានពន្យាមិនលើសពី ១០ ថ្ងៃ នៃថ្ងៃធ្វើការ។[69] បន្ទាប់មក រដ្ឋបាលគយ និងរដ្ឋាករ ត្រូវជូនព័ត៌មានភ្លាមទៅអ្នកនាំចូល និងអ្នកប្តឹង អំពីការព្យួរទុកនូវការធ្វើបែបបទទំនិញហើយ ត្រូវតែបញ្ជាក់ពីមូលហេតុនៃការព្យួរទុកនេះផងដែរ ទន្ទឹមជាមួយគ្នានោះដែល រដ្ឋបាលគយ និងរដ្ឋាករ ត្រូវបញ្ជាក់នូវឈ្មោះ និងអាសយដ្ឋាននៃអ្នកប្តឹងដល់អ្នកនាំចូលផងដែរ។

## ខ.២ សិទ្ធិត្រួតពិនិត្យ និងសិទ្ធិទទួលព័ត៌មាន

រដ្ឋាបាលគយ និងរដ្ឋាករ អាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញពិនិត្យនូវទំនិញដែលបានព្យួរទុកតាមបែបបទគយ និងដកយកនូវគំរូដើម្បីពិនិត្យសាកល្បង និងវិភាគក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថាទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ។ ក្រោយពេលដែលពិនិត្យទំនិញហើយដឹងថាជាទំនិញពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និងរដ្ឋាករ អាចជូនព័ត៌មានទៅម្ចាស់សិទ្ធិនូវឈ្មោះអាសយដ្ឋាននៃអ្នកនាំចេញអ្នកនាំចូលអ្នកទទួល និងបរិមាណទំនិញ។ ដោយមិនធ្វើឱ្យប៉ះពាល់ដល់ការការពារនូវព័ត៌មានសម្ងាត់រដ្ឋបាលគយ និងរដ្ឋាករ អាចផ្តល់ទៅឱ្យម្ចាស់សិទ្ធិនូវច្បាប់ចម្លងនៃឯកសារទំនិញទាំងនោះនូវព័ត៌មានដែលមាន ឬឯកសារដែលទាក់ទង និងការនាំចូលនិងការនាំចេញនូវទំនិញប្រហាក់ប្រហែលពីមុនដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះតាមសំណូមពររបស់ម្ចាស់សិទ្ធិ។[70] អាជ្ញាធរ និងមន្ត្រីទទួលបន្ទុកត្រូវបានលើកលែងពីការទទួលខុសត្រូវចំពោះវិធានការដោះស្រាយ ដោយសមស្របនៅពេលដែលសកម្មភាពទាំងនោះត្រូវធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់។[71]

## ខ.៣ សំណងចំពោះអ្នកនាំចូល និងចំពោះម្ចាស់ទំនិញ

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានសិទ្ធិសម្រេចឱ្យអ្នកដែលប្តឹងសងទៅម្ចាស់អ្នកនាំចូលអ្នកនាំចេញ និងអ្នកទទួលទំនិញនូវសំណងសមស្របចំពោះការ ខូចខាតរបស់គេដែល

---

[69] យោងតាមមាត្រា៣៩ នៃច្បាប់ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦

[70] យោងតាមមាត្រា៤២ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[71] យោងតាមមាត្រា៤៥ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

បណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទុកទំនិញ ដែលបានដោះលែង។ ក្នុងករណីភាគីណាមួយមិនយល់ព្រមតាមសេចក្តីសម្រេចនេះភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ។[72]

### ខ.៤. ការបំផ្លាញនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយ

ដោយសារមានសេចក្តីសម្រេចពីតុលាការ រដ្ឋបាលគយ និងរដ្ឋាករ មានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយនោះ។ រដ្ឋបាលគយ និងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យធ្វើការនាំចេញបន្តនូវទំនិញដែលមានម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះឱ្យនៅក្រោមនីតិវិធិផ្សេងៗទៀត របស់គយឡើយ។[73]

### កថាខណ្ឌទី២៖ សវនាការ

សវនាការ គឺជាការធ្វើបទបង្ហាញទៅវិញទៅមកនៅក្នុងវេទិកាមួយ ដែលដឹកនាំដោយមន្ត្រីកាន់កាប់បញ្ជី។ នាពេលបច្ចុប្បន្ន ប្រធាន ឬអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជ-កម្ម ជាអ្នកដឹកនាំសវនាការទាំងអស់។ មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិដែលច្បាប់ ឬអនុក្រឹត្យប្រគល់ឱ្យមន្ត្រីកាន់កាប់បញ្ជីប្រឆាំង និងបុគ្គលណាម្នាក់មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងដល់បុគ្គលនោះអំពីឱកាសបញ្ចេញមតិក្នុង សវនាការប្រសិនបើបុគ្គលនោះចង់ចូលរួម។ សេចក្តីជូនដំណឹងនេះត្រូវធ្វើជាលាយល័ក្ខអក្សរ និងមានបញ្ជាក់ពីពេលវេលាកំណត់មានតិចជាង ១ ខែ។[74] បច្ចុប្បន្ននេះពេលវេលាកំណត់មានរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងនេះ។

### គ. យន្តការដោះស្រាយក្រៅប្រពន្ធតុលាការ

ការដោះស្រាយនេះ គឺជានីតិវិធីមួយដើម្បីក្នុងការស្វែងរកលក្ខខណ្ឌ ក្នុងការដោះស្រាយដោយសន្តិវិធី។ ការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះ មានដូចជា ការសម្រុះសម្រួល មជ្ឈត្តការ អាចមានភាពសមស្របសំរាប់ការ ដោះស្រាយវិវាទម៉ាកនេះដែរ។ ពីព្រោះក្នុងករណីវិវាទម៉ាក

---

[72] យោងតាមមាត្រា៤១ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[73] យោងតាមមាត្រា៤៦ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[74] យោងតាមមាត្រា៣២ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០៦

ស្រដៀងគ្នា (ម្ចាស់ម៉ាកមានអំណះអំណាងរៀងៗខ្លួន) ការធ្វើជំនួញប្រៀននាយ (ម្ចាស់ម៉ាក និងអ្នកទទួលសិទ្ធិធ្វើអាជីវកម្ម) ការចរចាដោយអ្នកសម្រុះសម្រួលជួយជា ជំរើសដែលល្អអាចផ្តល់ផលប្រយោជន៍ដល់គូវិវាទទាំងសងខាង និងនៅតែរក្សាទំនាក់ទំនងកិច្ចការជំនួញជាមួយគ្នាបន្តទៀត។ លើសពីនេះក្នុងករណីវិវាទផ្សេងៗទៀត ឬដូចករណីខាងលើនេះក៏អាចប្រើវិធីនេះផងដែរ។ ប្រសិនភាគីវិវាទគិតទៅលើការចំណាយពេលវេលាការចង់បានតែប្រាក់សំណងតែ ១មុខ ផលប៉ះពាល់ដែលមានលក្ខណៈត្រឹមតែសមល្មម ឬការខ្វះការយល់ដឹងពីភាគីរំលោភសិទ្ធិនោះ។[75]

### ខ. ការបើសវនាការ

ការបើសវនាការ គឺត្រូវធ្វើឡើងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ជាទូទៅសវនាការទាំងនោះត្រូវធ្វើឡើងដោយមានវត្តមានពីភាគីមួយ ឬភាគីទាំងឡាយ ឬមេធាវីរបស់ខ្លួនចូលរួម។ ក្នុងអំឡុងពេលសវនាការមន្ត្រីកាន់កាប់បញ្ជីអាចៈ

- ការកោះហៅសាក្សី
- ការទទួលយកភស្តុតាងជាលាយល័ក្ខអក្សរ ឬផ្ទាល់មាត់
- តម្រូវឱ្យបង្ហាញឯកសារ ឬអត្ថបទផ្សេងៗ
- នៅពេលមន្ត្រីកាន់កាប់បញ្ជីយល់ឃើញថាសមស្របជូនដំណឹងដល់បុគ្គលទាំងឡាយអំពីបញ្ហាដែលខ្លួនយល់ថាគួរតែជូនដំណឹងដល់បុគ្គលនោះ។ ភាគីទាំងអស់ក៏អាចធ្វើការជ្រើសរើសដើម្បីដាក់សារណាជាលាយល័ក្ខអក្សរបានផងដែរ។

### គ. សវនាការអន្តរភាគី

បញ្ហាទាំងឡាយដែលកើតឡើងក្រោមច្បាប់ ដែលតម្រូវឱ្យមន្ត្រីកាន់កាប់បញ្ជីធ្វើសេចក្តីសម្រេចដែលកំណត់អំពីសិទ្ធិរបស់ភាគីមួយ ពាក់ព័ន្ធទៅនិងភាគីផ្សេងទៀត បញ្ហាទាំងនោះត្រូវចាត់ទុកជាបញ្ហាអន្តរភាគី។ បញ្ហាទាំងនោះរួមមានបណ្តឹងជំទាស់ទៅ និងការចុះបញ្ជីម៉ាក និងបណ្តឹងជំទាស់លុបម៉ាក ដែលមិនបានប្រើប្រាស់ចេញពីបញ្ជី។[76] ភាគីនីមួយៗដែលមានចំណាប់អារម្មណ៍

[75] យោងតាមអត្ថបទវិវាទកម្មសិទ្ធិបញ្ញា INTELLECTUAL PROPERTY DISOUTE-LA DISPUTE DE LA PROPRIÉTÉ

[76] យោងតាមមាត្រា១០ មាត្រា១៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

មានឱកាសក្នុងការបញ្ចេញមតិនៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជីដែលជាអ្នកធ្វើសេចក្តីសម្រេចហើយ សវនាការលើបញ្ហាទាំងនោះត្រូវបានចាត់តទុកជាសវនាការអន្តរភាគី។

### ឃ. សវនាការឯកតោភាគី

នៅពេលដែលភាគីមួយដាក់ពាក្យសុំចុះបញ្ជីម៉ាកមួយ ហើយពាក្យសុំចុះបញ្ជីម៉ាកនោះត្រូវគេលើកឡើងថាគួរបដិសេធចោលភាគីនោះមានសិទ្ធិតាមផ្លូវច្បាប់ បញ្ចេញមតិអំពីបញ្ហានេះនៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជី។ សវនាការនេះត្រូវហៅថា ជាសវនាការឯកតោភាគី សវនាការឯកតោភាគីត្រូវចុះក្នុងបញ្ជីរឿងក្តីហើយ ធ្វើសវនាការដោយមន្ត្រីកាន់កាប់បញ្ជី។ សវនាការនេះអាចត្រូវបានស្នើសុំដោយអ្នកដាក់ពាក្យសុំចុះបញ្ជីម៉ាក ឬចុះក្នុងបញ្ជីរឿងក្តីដោយមន្ត្រីកាន់កាប់បញ្ជី។ អ្នកដាក់ពាក្យសុំចុះបញ្ជីម៉ាកអាចស្នើសុំធ្វើសវនាការនៅពេលណាមួយក៏បានក្រោយពេល មន្ត្រីកាន់កាប់បញ្ជីបានបដិសេធ ឬមិនអនុញ្ញាតចំពោះពាក្យសុំចុះបញ្ជីរបស់ខ្លួន។ បញ្ហាដែលអាចធ្វើឱ្យការស្នើសុំធ្វើសវនាការរួមមាន៖

- បដិសេធពាក្យសុំចុះបញ្ជីម៉ាក
- បដិសេធការកែតម្រូវម៉ាក
- បដិសេធការពន្យាពេល
- បដិសេធ ឬលុបម៉ាកចេញពីបញ្ជី។

## កថាខណ្ឌទី២៖ ទោសបញ្ញត្តិ នៃអំពើរំលោភបំពាន

រាល់អំពីរំលោភបំពាន់ទៅលើម៉ាក ដូចដែលបានកំណត់នេះត្រូវចាត់ទុកថា គឺជាបទល្មើសព្រហ្មទណ្ឌ ហើយម្ចាស់ម៉ាកមានសិទ្ធិទាមទារសំណងរដ្ឋប្បវេណី។

### ក. ទណ្ឌកម្មរដ្ឋប្បវេណី

ការទាមទារសំណង រដ្ឋប្បវេណីជាសិទ្ធិរបស់ម្ចាស់ម៉ាក។ ច្បាប់ម៉ាកពុំបានចែងអំពីវិបមន្តកំណត់អំពីការទាមទារសំណងឡើយ ប៉ុន្តែច្បាប់ក៏ពុំបានបិទសិទ្ធិរបស់ម្ចាស់ម៉ាកក្នុងការទាមទារសំណងលើការខូចខាតដែលកើតចេញពីអំពើ រំលោភសិទ្ធិរបស់ម្ចាស់ម៉ាកដែរ។ ការទាមទារសំណងអាចត្រូវបានធ្វើឡើងដោយម្ចាស់ម៉ាកស្របច្បាប់ ដោយផ្អែកលើទំហំនៃព្យសនកម្ម និងភស្តុតាងបញ្ជាក់។

### ខ. ទោសព្រហ្មទណ្ឌ

អំពើរំលោភបំពាននៃម៉ាក គឺជាកម្មវត្ថុនៃការផ្តន្ទាទោស ពិន័យជាប្រាក់រហូតដល់ ២០ លានរៀល ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅដល់ ៥ ឆ្នាំ។ ក្នុងករណីមិនរាងចាលត្រូវដាក់ទោសទ្វេដង។[77]

### ១. ព្យសនកម្ម និងសំណង

ព្យសនកម្ម ដែលរងគ្រោះដោយសារការរំលោភបំពានលើម៉ាកគឺមានទំហំធំធេង។ គោលដៅនៃម៉ាកគឺដើម្បីទាក់ទាញអតិថិជន និងទំនុកចិត្តរបស់អ្នកប្រើប្រាស់មក លើផលិតផលរបស់សហគ្រាស ឬបុគ្គលម្ចាស់ម៉ាកនោះ។ ផលិតផលក្លែងបន្លំមិនត្រឹមតែធ្វើឱ្យម្ចាស់ម៉ាកខាតបង់នូវរបរអាជីវកម្មរបស់គាត់តែប៉ុណ្ណោះទេតែថែមទាំង បាត់បង់នូវទំនុកចិត្តពីអ្នកប្រើប្រាស់ទូទៅដែលកើតចេញពីភាពពុំសមស្របនៃផលិតផល ក្លែងបន្លំរបស់អ្នករំលោភបំពាន។ ការខាតបង់ទាំងផ្នែកសេដ្ឋកិច្ច សំភារៈ និងជាពិសេស ទំនុកចិត្តរបស់អ្នកប្រើប្រាស់អាចត្រូវអូសបន្លាយពេលដល់ទៅរាប់សិបឆ្នាំនាពេលអនាគតក៏មាន។ ក្នុងករណីនេះ ការខូចខាតដែលអាចកើតមាន និងអាចទូទាត់បាននាពេលអនាគតអាចជាកម្មវត្ថុនៃការទាមទារសំណងពីអ្នករំលោភបំពានដោយម្ចាស់ម៉ាក។

### ២. អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

តើអ្វីជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់? ជាគោលការណ៍ត្រូវបានចាត់ថាជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់សំដៅលើអំពើនៃការប្រកួតប្រជែង ទាំងឡាយដែលផ្ទុយពីគោល-ការណ៍នៃការអនុវត្តទៀតត្រង់ក្នុងវិស័យ ពាណិជ្ជកម្ម។[78] ទង្វើទាំងឡាយនោះត្រូវបានចាត់ទុកជាការភាន់ច្រឡំលើសហគ្រាស ឬការភាន់ច្រឡំលើសកម្មភាពដូចជា សហគ្រាសជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង។[79] ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្មដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះសហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង។ ការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជ-

[77] យោងតាមមាត្រា ៦៤,៦៥,៦៦ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[78] យោងតាមមាត្រា២២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

[79] យោងតាមមាត្រា២៣ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០២

កម្មហើយដែលអាចធ្វើឱ្យសាធារណជន ភាន់ច្រឡំអំពើប្រភេទដំណើរការផលិតលក្ខណៈភាពសមស្របសំរាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ។

# សេចក្តីសន្និដ្ឋាន

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវខាងលើ បានបង្ហាញឱ្យឃើញថា ប្រធានបទដែលស្តីពី "**របបគតិយុត្តនៃម៉ាកក្នុងបរិបទនៃច្បាប់កម្ពុជា**" គឺយើងអាចសន្និដ្ឋានបានថា ច្បាប់ម៉ាកនៃប្រទេសកម្ពុជាត្រូវបានការពារ តែទៅលើម៉ាកដែលអាចមើលឃើញតែប៉ុណ្ណោះ។ ច្បាប់នេះបានកំណត់ចំពោះម៉ាកថា ត្រូវតែជាសញ្ញាដែលមើលឃើញនិងភ្នែកបាន ពីព្រោះវាធ្វើឱ្យមានភាពងាយស្រួលដល់អតិថិជន ឬអ្នកប្រើប្រាស់នូវទំនិញ ឬសេវាទាំងនោះក្នុងការបែងចែកលក្ខណៈខុសគ្នារវាងទំនិញមួយទៅ និងទំនិញមួយទៀតបាន និងអាចជួយសម្រួលដល់កិច្ចការពារម៉ាកពីការក្លែងបន្លំនិងការរំលោភបំពានទៅលើម៉ាកនៃទំនិញ ឬសេវាទាំងនោះបានទៀតផងដែរ។ ម្យ៉ាងទៀតក៏អាចជួយសម្រួលដល់យន្តការ នៃការការពារម៉ាកពីរាល់ការក្លែងបន្លំផ្សេងៗបានផងទៀត។ យ៉ាងណាមិញម៉ាកដែលត្រូវបានស្នើសុំចុះបញ្ជីគឺមិនត្រូវមានលក្ខណៈផ្ទុយ និងសណ្តាប់ធ្នាប់សាធារណៈឡើយ។ ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ។ ប្រសិនបើម៉ាកដែលជាកម្មវត្ថុ នៃការចុះបញ្ជីត្រូវបានចាត់ទុកថា មានលក្ខណៈផ្ទុយពីសណ្តាប់ធ្នាប់សាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជាបានឡើយ។ ផ្អែកតាមបរិបទនៃច្បាប់ ស្តីពីម៉ាកនៅក្នុងប្រទេសកម្ពុជា ម៉ាកមួយអាចទទួលបាននូវកិច្ចការពារពេញលេញដោយស្របច្បាប់ កាលណាតែម៉ាកនោះត្រូវបានចុះបញ្ជីរួចហើយ។ ម្ចាស់ម៉ាកអាចដាក់ពាក្យសុំចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយត្រូវបំពេញលក្ខខណ្ឌទាំងឡាយតាមច្បាប់កំណត់ ព្រមទាំងលក្ខខណ្ឌទម្រង់ផងដែរ។ ជាការពិតដើម្បីទទួលបានសិទ្ធិលើម៉ាកមួយ ម្ចាស់ម៉ាកត្រូវតែដាក់ពាក្យស្នើសុំចុះបញ្ជី ដោយមានភ្ជាប់ជាមួយនូវរាល់សំណុំឯកសារ ចាំបាច់ផ្សេងៗក្រោមទម្រង់ជាលាយលក្ខណ៍អក្សរ និងត្រូវបានបំពេញបន្ថែមទៀតដោយ អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាកនេះ។ ក្នុងករណីមានការរំលោភបំពាន់ទៅលើម៉ាក ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចការប្រើប្រាស់ម៉ាក គ្រប់រូបភាពដោយពុំមានការអនុញ្ញាត ពីម្ចាស់ម៉ាកត្រូវបានចាត់ទុកថា ជាអំពើរំលោភម៉ាក។ នៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ម៉ាកអំពើរំលោភម៉ាក អាចកើតមានឡើងច្រើនទម្រង់។ ដូច្នេះ ក្នុងករណីដែលកើតមានវិវាទម្ចាស់កម្មសិទ្ធិនៃម៉ាក អាចធ្វើការស្នើសុំធ្វើសវនាការនោះដោយការស្នើសុំធ្វើសវនាការ មួយនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ទៅកាន់មន្ត្រីកាន់កាប់បញ្ជីនៅពេលទទួលបានពាក្យស្នើសុំនេះមន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ០១ ខែ មុនកាលបរិច្ឆេទដែលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវអញ្ជើញមកចូលរួមក្នុង សវនាការក៏ដូចជាសេចក្តីពិពណ៌នា អំពីការពឹងផ្អែកលើភស្តុតាង

របស់ភាគីមួយ ឬច្រើនដែលពាក់ពន្ធ័កម្រិតនៃតម្រូវការព័ត៌មាន លំអិតអាស្រ័យទៅលើកំរិតពាក់ព័ន្ធ និងការពឹងផ្អែកលើផ្នែកផ្សេងៗនៃភស្តុតាង។

សរុបសេចក្តីមកបទប្បញ្ញត្តិដែលពាក់ព័ន្ធ និងច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គឺផ្តោតសំខាន់ទៅលើការអនុវត្តនៃគោលការណ៍ ក្នុងការក្លាយជាម្ចាស់ម៉ាកមួយដែលសមស្របតាមច្បាប់បានកំណត់ និងនាំយកផលិតផលរបស់ដែលជាយីហោរបស់ខ្លួនឱ្យទទួលបានការការពារពីច្បាប់ដោយអនុវត្តក្នុង នីតិវិធីចុះបញ្ជីនៃម៉ាករបស់ខ្លួនធ្វើយ៉ាងណាអោយម៉ាករបស់ខ្លួនក្លាយជានីតិបុគ្គលមួយដែលស្ថិតនៅក្រោមច្បាប់។ អំពីគោលការណ៍ នៃការទទួលបានសិទ្ធិជាម្ចាស់ពេញលេញ និងស្របច្បាប់ពិសេសប្រសិនមានករណី រំលោភបំពានដោយហេតុផលណាមួយទៅលើម៉ាក របស់ខ្លួនអាចមានសិទ្ធិប្តឹងជំទាស់ឱ្យ ពិនិត្យឡើងវិញហើយក៏អាចប្តឹងសុំទៅតុលាការដើម្បីទាមទារសំណងបានផងដែរ។

# ឯកសារយោង

## ១. ច្បាប់

- ច្បាប់ស្តីពី រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៩
- ច្បាប់ស្តីពី ក្រមរដ្ឋប្បវេណីខ្មែរ ឆ្នាំ២០០៧
- ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០២
- ច្បាប់ស្តីពី ស្តង់ដារកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ស្តីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែល មានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម ឆ្នាំ ២០០៦

## ២. កិច្ចព្រមព្រៀង

- កិច្ចព្រមព្រៀងស្តីពី ទិដ្ឋភាពពាណិជ្ជកម្មទាក់ទង និងកម្មសិទ្ធិបញ្ញា TRIP ឆ្នាំ១៩៩៤

## ៣. អនុក្រឹត្យ

- អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ ២០០៦
- អនុក្រឹត្យលេខ៦៤ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦

## ៣. ប្រកាស

- ប្រកាសស្តីពី នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញតកម្ម ឆ្នាំ២០១៦
- ប្រកាសលេខ ៤៥៧ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧
- ប្រកាសអន្តរក្រសួងស្តីពី កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និង កម្រៃរដ្ឋបាលពាក់ព័ន្ធនានា
- ប្រកាសស្តីពី នីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

- ប្រកាសស្តីពី នីតិវិធីសម្រាប់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ
- ប្រកាសស្តីពី ការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ៩៨៥, ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈ

## ៤. សារាចរណែនាំ

- សារាចរណែនាំស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

## ៣. ឯកសារផ្សេងៗ

- សន្ធានុក្រមច្បាប់ តាមបទដ្ឋានគតិយុត្តខ្មែរ បោះពុម្ពលើកទី២ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦
- សៀវភៅ "នីតិកម្មសិទ្ធិបញ្ញា" ដោយលោក កាន់ សុទ្ធប៉ូលីន បោះពុម្ពលើកទី១ ថ្ងៃទី០៩ ខែ តុលា ឆ្នាំ២០០៩
- សៀវភៅ "នីតិកម្មសិទ្ធិបញ្ញាកម្ពុជា" ដោយលោក នី វិចិត្រ បោះពុម្ពលើកទី១ ឆ្នាំ២០១៣
- សៀវភៅណែនាំ "សម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និង ការប្រកបអាជីវកម្មអនុលោមតាមច្បាប់ រៀបចំដោយ ក្រសួងពាណិជ្ជកម្ម" បោះពុម្ព ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦
- សៀវភៅ "នីតិកម្មសិទ្ធិបញ្ញា" រៀបរៀងដោយ លោកសាស្ត្រាចារ្យ ទេពសុខ បោះពុម្ព ឆ្នាំ ២០១៧
- សៀវភៅ "មេរៀនស្តីពី នីតិកម្មសិទ្ធិបញ្ញា" រៀបរៀងដោយ សាស្ត្រាចារ្យ លឹម យូសូ

# ឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖ ការបង្ក្រាបទំនិញក្លែងម៉ាកសញ្ញារបស់សាខាកាំកុងត្រូលខេត្តកំពង់ចាម
- ឧបសម្ព័ន្ធទី២៖ សាលដីកា តុលាការកំពូល ក្នុងការបើសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៣ ក្នុងវិវាទរឿង Lachemise lacoste និង Crocodile Inlernational
- ឧបសម្ព័ន្ធទី៣៖ វិញ្ញាបនបត្រចុះបញ្ជីម៉ាក
- ឧបសម្ព័ន្ធទី៤៖ ពាក្យស្នើសុំចុះបញ្ជីម៉ាក
- ឧបសម្ព័ន្ធទី៥៖ សារចរណៃនាំ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
- ឧបសម្ព័ន្ធទី៦៖ អនុសសាសន៍រួម ស្តីពីអាជ្ញាប័ណ្ណម៉ាក
- ឧបសម្ព័ន្ធទី៦៖ លិខិតទទួលស្គាល់ការដាក់ពាក្យ

## ការបង្ក្រាបទំនិញក្លែងម៉ាកសញ្ញារបស់
## សាខាកាំកុងត្រូលខេត្តកំពង់ចាម

កាលពីថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១១ សមត្ថកិច្ចចំរុះក្នុងខេត្តកំពង់ចាមបានចុះទៅធ្វើការត្រួតពិនិត្យទំនិញដែលក្លែងម៉ាកសញ្ញារបស់ក្រុមហ៊ុន[redacted] ដែលស្ថិតនៅតាមផ្ទះលក់គ្រឿងសំអាង និងនៅក្នុងផ្សារនានាៗក្នុងខេត្តកំពង់ចាម។

សមាសភាពចូលរួមមានដូចខាងក្រោម ៖

១- លោក [redacted] ប្រធានសាខាកាំកុងត្រូលប្រចាំខេត្តកំពង់ចាម

២- លោក[redacted] តំណាងប៉ូលីសសេដ្ឋកិច្ចខេត្តកំពង់ចាម

៣- លោក[redacted] មេធាវីរបស់ក្រុមហ៊ុន[redacted]

៤- លោកតំណាងអោយក្រុមហ៊[redacted]

ជាលទ្ធផល សមត្ថកិច្ចបានត្រួតពិនិត្យឃើញមានទំនិញក្លែងម៉ាកសញ្ញារបស់ក្រុមហ៊[redacted] ដែលដាក់តាំងលក់ដូចជាក្រែមលាបមុខម៉ាក **ផន**[redacted] សាប៊ូលាងចានម៉ាក [redacted]សាប៊ូកក់សក់ម៉ាក [redacted]និងផលិតផលក្លែងម៉ាកសញ្ញារបស់ក្រុមហ៊ុន[redacted]ផ្សេងៗទៀត។

**ដោយយោងតាម:**

- ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

សមត្ថកិច្ចយើងបានដកហូតនូវមុខទំនិញក្លែងក្លាយគុណភាពរបស់ក្រុមហ៊ុន[redacted]ដូចជាទឹកសាប៊ូលាងចានដែលផលិតក្នុងស្រុកច្រកក្នុងសំបកដបម៉ាក[redacted]។

[redacted]ចំណុះ 771 ml = 24 ដម

[redacted]ចំណុះ 434 ml = 29 ដម

ចំពោះទំនិញក្លែងក្លាយគុណភាពទាំងនេះសមត្ថកិច្ចយើងប្រគល់ជូនម្ចាស់ក្រុមហ៊ុន[redacted] ដើម្បីឲ្យគាត់រក្សាទុករៀបចំនីតិវិធីទៅតាមច្បាប់។

បន្ទាប់មកសមត្ថកិច្ចបានធ្វើការអប់រំណែនាំដល់អាជីវករ សូមអោយបញ្ឈប់លក់ជាបន្ទាន់នូវទំនិញក្លែងម៉ាកសញ្ញារបស់ក្រុមហ៊ុន [redacted] ដែលនាំចូលពីប្រទេសវៀតណាម។ សមត្ថកិច្ចយើងបានធ្វើកិច្ចសន្យាអោយអាជីវករផ្តិតមេដៃទុកជាភស្តុតាង ថ្ងៃក្រោយបើនៅតែបន្តការលក់នូវផលិតផលក្លែងម៉ាកសញ្ញារបស់ក្រុមហ៊ុន[redacted]ទៀត សមត្ថកិច្ចនិងធ្វើការរឹបអូស និងផាកពិន័យទៅតាមផ្លូវច្បាប់។

ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៤៧

ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២

នាមនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

**សាលដីកា**

លេខ : ៧៣

ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម [redacted] ប្រធាន

២- លោក [redacted] ចៅក្រម

៣- លោក [redacted] ចៅក្រម-របាយការណ៍

៤- លោក [redacted] ចៅក្រម

៥- លោក [redacted] ចៅក្រម

[redacted]

កញ្ញា [redacted]

តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ០៩"ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៤៧ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទអ្នកស្រី [redacted] "ជាម្ចាស់បណ្តឹងសាទុក្ខ" ប្រធានក្រុមហ៊ុន [redacted] Trading [redacted] ទីលំនៅផ្ទះលេខ០៩ ផ្លូវអង្គឌួង សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ។

លោក [redacted] ជាមេធាវី និង ជាតំណាងអោយដើមចោទ

និងចុងចម្លើយក្រុមហ៊ុន [redacted] "ជាចុងបណ្តឹងសាទុក្ខ"។

លោក [redacted] ជាមេធាវី និង ជាតំណាងអោយចុងចម្លើយ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំលុបសេចក្តីសំរេចចុះបញ្ជីសញ្ញាពាណិជ្ជកម្ម [redacted] ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៣ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២របស់មេធាវី[redacted] ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ០៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៤២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ របស់ឈ្មោះ ពៅ គីមលី ជាប្រធានក្រុមហ៊ុន [redacted] តំណាងអោយក្រុមហ៊ុន Lachemise Lacoste ប្តឹងសុំលុបសេចក្តីសំរេចចុះបញ្ជីសញ្ញាពាណិជ្ជកម្ម Crocodile International [redacted] ដោយសំអាងហេតុ ថា ក្រុមហ៊ុន [redacted] បានចុះបញ្ជីការពារផ្លាកសញ្ញាពាណិជ្ជកម្មរូបក្រពើនៅប្រទេស កម្ពុជាមានវិញ្ញាបនបត្រ័ចុះបញ្ជីលេខ៧១៣៥ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៦ និងបានប្រើប្រាស់លើកដំបូងពីឆ្នាំ១៩២៧មក ប៉ុន្តែក្រុមហ៊ុន [redacted] បានលួចចុះផ្លាកសញ្ញា ពាណិជ្ជកម្មរូបក្រពើនេះនៅកម្ពុជា និងបានប្រើប្រាស់រហូតមកដល់សព្វថ្ងៃ ជាហេតុធ្វើអោយប៉ះពាល់ ផលប្រយោជន៍នៃផលិតផលទំនិញ La coste យ៉ាងធ្ងន់ធ្ងរ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៤៩"ឆ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលស្គាល់លិខិតប្រគល់សិទ្ធិជូនមេធាវី [redacted] ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៩ របស់ក្រុមហ៊ុន [redacted] តំណាងអោយក្រុមហ៊ុន [redacted] ( LLC ) ប្រទេសបារាំងទុកជាត្រឹមត្រូវតាមច្បាប់ ។

២-ទទួលស្គាល់លិខិតប្រគល់សិទ្ធិជូនមេធាវី[redacted] ចុះថ្ងៃ១៤ ខែកុម្ភៈ ឆ្នាំ២០០០ របស់ក្រុមហ៊ុន[redacted] តំណាងឱ្យក្រុមហ៊ុន[redacted] Pte,Ltd ( CI ) ប្រទេសសិង្ហបុរីទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលពាក្យបណ្តឹងចុះថ្ងៃ២៨ ខែធ្នូ ឆ្នាំ១៩៩៩របស់ក្រុមហ៊ុន សានអាយភីអរ៍ តំណាងឱ្យក្រុមហ៊ុន [redacted] ប្រទេសបារាំងទុកជាត្រឹមត្រូវតាមទំរង់ ច្បាប់តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលតំណាងដើមចោទបានបង់ទុកជាស្រេច ។

៥-ទទួលពាក្យបណ្តឹងតបចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ របស់មេធាវី [redacted] តំណាងអោយក្រុមហ៊ុន [redacted] ប្រទេសសឹង្ហបុរី ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៦-តម្កល់សេចក្តីសំរេចចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាស្តីពីការបដិសេធ ការសុំចុះបញ្ជីកសញ្ញាម៉ាក្ស [redacted] ទុកជាបានការដដែល ។

៧-អោយឈ្មោះជូ ចាន់ធីរ៉ា បង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន១.៨០០រ៛ វង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល វង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល សរុប ៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រៀល ដែលឈ្មោះ [redacted] [redacted]ានបង់ទុកជាស្រេច ។

កាលបើហួសឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ [redacted] សងប្រាក់៧.០០០រៀលនេះ អោយទៅឈ្មោះ [redacted] វិញ ។

៨-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខតំណាងគូក្តីបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០២"ឆ" ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០១ របស់មេធាវី ជូ ចាន់-ធីរ៉ា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៤៩"ឆ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលា-ក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ០៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០១ របស់លោកមេធាវី ជូ ចាន់ធីរ៉ា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៤៩ "ឆ" ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល' ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ២.៥៥០រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ៥.០០០រ៛។ សរុប ១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៩៣ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់ ជូ ចាន់ធីរ៉ា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ របស់លោក ជូ ចាន់ធីរ៉ា ។

បានឃើញសារណាតប ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ របស់លោក អៀង វណ្ណៈ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ០៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

លោកជូ ចាន់ធីរ៉ា ជាមេធាវី និងជាតំណាងការពារអោយដើមចោទ ធ្វើសេចក្តីសន្និដ្ឋាននៅពេលសវនាការថា : ខ្លួនពុំសុខចិត្តនឹងសេចក្តីសំរេចរបស់តុលាការក្រុងភ្នំពេញ និង សាលាឧទ្ធរណ៍រូបភាពក្រពើនេះបានមកពី អ្នកពូកែវាយសីម្នាក់ពេលនេះក្រុមហ៊ុននេះបានយកមកផ្សាយពាណិជ្ជកម្ម ដែលធ្វើអោយមានការល្បីល្បាញ ហើយក្រុមហ៊ុន LLC បានចុះបញ្ជីពាណិជ្ជសញ្ញារូបក្រពើ Lacoste ចំនួន១៨៦ប្រទេសលើពិភពលោករួមទាំងប្រទេសកម្ពុជាផង ដែលបានចុះបញ្ជីតាំងពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ។ ឯការប្រើពាណិជ្ជសញ្ញារបស់ក្រុមហ៊ុនចុងចម្លើយពុំមានកើតឡើងពីប្រវត្តិដើមពិតនៃឈ្មោះភូមិសាស្ត្រ ឬ ឈ្មោះនៃអ្នកបង្កើតក្រុមហ៊ុនមុនគេ នៃក្រុមហ៊ុនចុងចម្លើយទេ ។ នេះបង្ហាញអោយឃើញថា ក្រុមហ៊ុន Crocodile Internationl ជ្រើសរើសពាណិជ្ជសញ្ញារូបក្រពើ Crocodile លើផលិតផលរបស់ខ្លួន ត្រាប់តាមក្រុមហ៊ុន LLC ដែលប្រើប្រាស់ពាណិជ្ជសញ្ញារូបក្រពើដែលសាធារណៈជនបាននិយមប្រើប្រាស់រួចមក ហើយធ្វើអោយសាធារណៈជនភាន់ច្រឡំថា ផលិតផលរបស់ក្រុមហ៊ុនចុងចម្លើយ ក៏ជាផលិតផលរបស់ក្រុមហ៊ុន LLC ដែរលុះដល់អតិថិជនយកទៅប្រើប្រាស់ទៅមានគុណភាពអន់ ក៏យល់ថាផលិតផលរបស់ក្រុមហ៊ុនLLC ធ្លាក់គុណភាពមិនល្អដូចដែលគេប្រើប្រាស់ពីមុនមក ។ ហើយក្រុមហ៊ុន LLC បានចុះបញ្ជីនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ មុនការចុះបញ្ជីពាណិជ្ជសញ្ញា របស់ក្រុមហ៊ុន Crocodile International គឺនៅថ្ងៃទី២២ ខែកុម្ភៈឆ្នាំ១៩៩៣ ។ ហើយផលិតផល Crocodile របស់ក្រុមហ៊ុន CI ទើបតែមានប្រើប្រាស់លក់ដូរនៅប្រទេសកម្ពុជា យើងក្នុងសម័យនេះទេ ពីមុនមកប្រជាពលរដ្ឋពុំដែលស្គាល់ឡើយ ។ ដូចនេះយើងឃើញថាផលិតផលទាំងពីរក្រុមហ៊ុននេះពិតជាមានលក្ខណៈដូចគ្នា ឬ ស្រដៀងគ្នាបេះបិទព្រោះផ្លាកសញ្ញាទាំងពីរគឺសត្វក្រពើដូចគ្នា ។

ដូចនេះខ្លួនសុំប្តឹងពីការក្លែងបន្លំផ្លាកសញ្ញារូបក្រពើរបស់ Lacoste និង Crocodile ហើយ Crocodile មានដាក់សញ្ញារូបក្រពាហើយមិនបានសរសេរអក្សរនៅខាងក្រោមទេ ហើយអក្សរខ្លះតូចៗមើលមិនចង់ឃើញ ដោយសារការក្លែងបន្លំនេះហើយទើបខ្លួនប្តឹងទៅតុលាការ ។ ខ្លួនបានចុះបញ្ជីនៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃឡង់ និង នៅសាំងហ្គាពួរ ហើយចំពោះការប្តឹងផ្តល់នៅប្រទេសទាំងនេះខ្លួនមិនបានដឹងទេ គ្រាន់តែបានចុះបញ្ជី Lachemise Lacoste មានពណ៌បៃតង ហើយពណ៌វាប្រែប្រួលទៅតាមផលិតផល ។ ចំពោះផលិតផលមួយចំនួនដាក់តែរូបក្រពើទេ តែខ្លះទៀតដាក់រូបក្រពើហើយដាក់អក្សរតូចថា Lacoste ។ អតិថិជនមួយចំនួនច្រើននិយាយថារូបក្រពើមិនល្អ ធ្វើអោយមានការក្លែងបន្លំដល់អតិថិជន និង ប៉ះពាល់ដល់ផលប្រយោជន៍របស់ក្រុមហ៊ុន Lacoste ។ ខ្លួនសុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ និង សុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ។

លោក អៀង វណ្ណៈ ជាមេធាវី និង ជាតំណាងការពារអោយចុងចម្លើយធ្វើសេចក្តីសន្និដ្ឋាននៅពេលសវនាការថា : សត្វក្រពើ និង ក្រពា តំណាងដូចគ្នាគ្រាន់តែរស់នៅប្រទេសផ្សេងគ្នាដែលជាហេតុធ្វើអោយរូបរាងមានលក្ខណៈខុសគ្នា ដូចនេះវាមិនមានលក្ខណៈដូចគ្នាទេ ។ ក្រុមហ៊ុននេះបានបោះរូបក្រពើ "ក្រពា" ហើយបានដាក់អក្សរតូចៗ នៅខាងក្រោមCrocodile បើមានការក្លែងបន្លំគេមិនអោយធ្វើចរាចរនៅក្នុងប្រទេសគេទេ សូម្បីប័ណ្ណលិខិតបញ្ជាក់ពលកម្មក៏គាត់ចុះបញ្ជីអោយដែរ នេះបញ្ជាក់ថាគ្មានការក្លែងបន្លំទេ ។ ចំពោះសត្វក្រពើ និង សត្វក្រពាខ្លួនបានមើលសៀវភៅបារាំង ចំពោះរូបសញ្ញាក្រពើវាមានពណ៌មិនទៀងទេ ដូចលោកមេធាវីខាងលើនេះបានជំរាបហើយសំខាន់គឺ ការសរសេរអក្សរទេ គេដាក់រូបក្រពើហើយសរសេរអក្សរតែម្តង ។

ខ្លួនសុំអោយឯកឧត្តម ប្រធានក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកាទាំងពីរថ្នាក់ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោមពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៣ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់លោក ជូ-ចាន់ធីវ៉ា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើង[redacted] មេធាវីការពារឱ្យក្រុមហ៊ុន[redacted] ក្នុងសារណាចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ ថា តាមអនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៩៦៧ កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និង សហរដ្ឋអាមេរិក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦ ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និងសិទ្ធិការពារកម្មសិទ្ធិបញ្ញា និងប្រកាសលេខ៣៦៨ព.ណ.ព.ក.ប.ប្រ របស់ក្រសួងពាណិជ្ជកម្ម បណ្តឹងរបស់ក្រុមហ៊ុន LLC សុំអោយក្រុមហ៊ុនCI លុបម៉ាកសញ្ញារូបក្រពើជៀសវាងការភ័ន្តច្រឡំដល់សាធារណៈជនវាជាការត្រឹមត្រូវ នោះគឺជាការភ័ន្តច្រឡំពីព្រោះថា :

-ឈ្មោះម៉ាករបស់ក្រុមហ៊ុន CI សឹង្ហបុរី គឺ[redacted]ឯឈ្មោះម៉ាករបស់ក្រុមហ៊ុន LLC បារាំងគឺ [redacted]

-រូបភាពម៉ាករបស់ក្រុមហ៊ុនCI សឹង្ហបុរីគឺ សត្វក្រពើ ឯរូបភាពម៉ាករបស់ក្រុមហ៊ុន LLC បារាំងគឺ សត្វក្រពា ។

- យល់ឃើញថា ក្រុមហ៊ុន [redacted] បានប្តឹងសុំលុបម៉ាកនេះនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ដោយបានបញ្ជូនឯកសារភ្ជាប់ជាមួយជាច្រើននាយកដ្ឋានកម្មសិទ្ធិបញ្ញាបានធ្វើការសិក្សា និង ស្រាវជ្រាវព្រមទាំងបានសន្និដ្ឋានថា ម៉ាកទាំងពីរនេះមិនអាចមានការភ័ន្តច្រឡំឡើយ ។

- យល់ឃើញថា ដើមចោទ និង ចុងចម្លើយពុំបានចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីរបស់គូភាគី បានចូលរួមដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះកំបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខមេធាវីគូភាគី កំបាំងមុខគូភាគី**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ៥៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០២ របស់លោក [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៩ "ឈ" ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រ៉ាប់អូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រី [redacted] បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើការប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៤- សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៣ និង ប្រកាសនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០០៣ ។

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE
នាយកដ្ឋានកម្មសិទ្ធិបញ្ញា
DEPARTMENT OF INTELLECTUAL PROPERTY RIGHTS

# វិញ្ញាបនបត្រចុះបញ្ជីម៉ាក
# CERTIFICATE OF MARK REGISTRATION

## បញ្ជីដើម
## PRINCIPAL REGISTER

លេខចុះបញ្ជី Registration No.: **KH/36596/11**

PETROLIMEX

ពិពណ៌នាអំពីម៉ាក Mark Description: PETROLIMEX & Device

| | |
|---|---|
| កាលបរិច្ឆេទចុះបញ្ជី Registration date | : February 28, 2011 |
| លេខដាក់ពាក្យ Application No. | : KH/38818/10 |
| កាលបរិច្ឆេទដាក់ពាក្យ Filing date | : October 12, 2010 |
| ម្ចាស់ម៉ាក Owner | [redacted] |
| អាសយដ្ឋាន Address | : No. 1 Kham Thien, Dong Da District, Hanoi, Vietnam |
| ជំពូក Class | : 35 |
| បញ្ជាក់ពណ៌ Claim of color | : Dark blue and orange |
| ល័ក្ខខ័ណ្ឌ Condition | : |
| ការបដិសេធ Disclaimer | : |
| មានសុពលភាពចាប់ពី ... រហូតដល់ Validity | : from **October 12, 2010** to **October 12, 2020** |
| អាសយដ្ឋានទំនាក់ទំនងក្នុងប្រទេស Local address for service | : INVESTIP / LPN IP AGENCY [redacted], Phnom Penh, Cambodia |
| អ្នកពិនិត្យ Examiner | : MOM THANA |

យោងតាមច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា ៣ និង១១ ម្ចាស់ម៉ាកមានសិទ្ធិផ្តាច់មុខលើការប្រើប្រាស់ម៉ាករបស់ខ្លួន។ សិទ្ធិផ្តាច់មុខនោះ រួមមាន ផលិត នាំចេញ នាំចូល និងចែកចាយជាដើម។

ដើម្បីជាសក្ខីភាព ខ្ញុំសូមចុះហត្ថលេខា និង ប្រថាប់ត្រានៃក្រសួងពាណិជ្ជកម្មថ្ងៃនេះ
In witness whereof, I have hereunto affixed my hand and the stamp of the Ministry of Commerce today

10 MAR 2011

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

(*អត្តសញ្ញាណអ្នកប្តឹង៖ ឈ្មោះ, តួនាទី, ពាណិជ្ជនាម, អាសយដ្ឋាន, លេខទំនាក់ទំនង*)....................................

**<u>សូមគោរពជូន</u>**

**ឯកឧត្តម [redacted] អនុរដ្ឋលេខាធិការ [redacted] និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ** (**គ.ប.ផ.ក.**)

**តាមរយៈ៖ ឧត្តមសេនីយ៍ទោ** [redacted] ប្រធានលេខាធិការដ្ឋាន [redacted]។
**កម្មវត្ថុ៖** សុំប្តឹងពីករណី.............................................................................................................................។
**យោង៖** លិខិតតំណាងដោយអាណត្តិ....

តបតាមកម្មវត្ថុនិងយោងខាងលើ(*ខ្ញុំ/យើងខ្ញុំ*)មានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** [redacted]. មេត្តាជ្រាបថា .........................
..............................................................................................................................................................
..............................។

សេចក្តីដូចបានជំរាបជូនខាងលើ ដើម្បីចូលរួមទប់ស្កាត់ និងបង្ក្រាបការនាំចូល ចែកចាយ និងធ្វើអាជីវកម្មខុសច្បាប់នូវផលិតផលក្លែងក្លាយ ដែលបណ្តាលអោយមានការខាតបង់ប្រាក់កាសរបស់ប្រជាពលរដ្ឋអ្នកប្រើប្រាស់ ក៏ដូចជាក្រុមហ៊ុនម្ចាស់ម៉ាក (*ខ្ញុំ/យើងខ្ញុំ*) សូមសំណូមពរដល់ឯកឧត្តមប្រធាន មេត្តាជួយធ្វើអន្តរាគមន៍ និងចាត់វិធានការសមស្របតាមផ្លូវច្បាប់ទៅលើឈ្មួញទុច្ចរិត ក៏ដូចជាផលិតផលក្លែងក្លាយ ដូចបានបញ្ជាក់ជូនខាងលើ តាមការគួរ ។

សូម **ឯកឧត្តម ប្រធាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពី (*ខ្ញុំ/យើងខ្ញុំ*) ។

រាជធានីភ្នំពេញ ថ្ងៃទី....ខែ....ឆ្នាំ.....
**ហត្ថលេខា ឬត្រា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**

Form: TM:001-APP/KH/2018
***CAMBODIA***

# ពាក្យស្នើសុំចុះបញ្ជីម៉ាក

**(សំរាប់មន្ត្រីប្រើប្រាស់ប៉ុណ្ណោះ)**
លេខដាក់ពាក្យ:
កាលបរិច្ឆេទដាក់ពាក្យ:

**ផ្នែកទី ១** : **អ្នកស្នើសុំ** (ម្ចាស់ម៉ាក)

(ក) ឈ្មោះ : ____________________

(ជាអក្សរឡាតាំង)____________________

(ខ) អាស័យដ្ឋាន : ____________________

(ជាអក្សរឡាតាំង)____________________

(គ) សញ្ជាតិ : ____________________

(ជាអក្សរឡាតាំង)____________________

(ឃ) ឈ្មោះ និងអាស័យដ្ឋានទំនាក់ទំនងក្នុងប្រទេសកម្ពុជា : (ជាអក្សរឡាតាំង)

____________________

លេខទូសព្ទ:__________លេខទូរសារ:__________សារអេឡិចត្រូនិច:__________

(ង) លេខចុះបញ្ជីនៃភ្នាក់ងារក្នុងប្រទេស (នៅពេលអនុវត្ត) :__________

**ផ្នែកទី ២** : **គំរូម៉ាក ដែលស្នើសុំចុះបញ្ជី**

**សំគាល់ :** គំរូម៉ាកត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំនេះ

៨ស.ម x ៨ស.ម
(សូមបិទម៉ាកនៅទីនេះ)

(ក) ឈ្មោះម៉ាក (ប្រសិនបើមាន) :

(ខ) ពិពណ៌នាម៉ាក (ម៉ាកជារូបភាព) :

(គ) ជំពូកទំនិញ ឬ សេវា:

(ឃ) យថាប្រភេទទំនិញ ឬ សេវា (ជាអក្សរអង់គ្លេស) :

(ង) ប្រសិនបើម៉ាកជាពណ៌ សូមបញ្ជាក់ពណ៌ទាំងនោះ :

(ច) ប្រសិនបើម៉ាកមានរូបភាពឆ្លុះឃើញបីជ្រុង (3-D): មែន ☐ មិនមែន ☐

(ឆ) ប្រសិនបើម៉ាកមានរូបភាពឆ្លុះឃើញបីជ្រុងនៃសំបកវេចខ្ចប់ ឬ ពណ៌ ដែលជាចំណុចពិសេសរបស់ម៉ាកត្រូវបានទាមទារឲ្យការពារសូមពិពណ៌នាចំណុចពិសេសនោះជាលាយលក្ខ័អក្សរ:

(ជ) ប្រសិនបើម៉ាកជាអក្សរ សូមផ្តល់ប្រភពនៃអក្សរទាំងនោះហើយត្រូវបញ្ជាក់ថា តើអក្សរទាំងនោះត្រូវបានបង្កើតឡើង ឬ មានក្នុងវចនានុក្រម:

(ឈ) ប្រសិនបើម៉ាកជាអក្សរដែលមិនមែនជាភាសាអង់គ្លេស និង / ឬ ជាភាសាបរទេសផ្សេងទៀត សូមផ្តល់ ព័ត៌មាន ដូចខាងក្រោម:

| ភាសា | អក្សរ | សំលេងអាន | អត្ថន័យ |
|---|---|---|---|
| | | | |
| | | | |
| | | | |

**ផ្នែកទី ៣ : ការប្រកាសសិទ្ធិជាអាទិភាព**

(ក) ឈ្មោះការិយាល័យដែលបានដាក់ពាក្យសុំសិទ្ធិអាទិភាពនៅបរទេស: ____________

____________________________________________________________

(ខ) កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំសិទ្ធិអាទិភាពនៅបរទេស: ថ្ងៃ___ ខែ___ ឆ្នាំ_____

(គ) លេខចុះបញ្ជីលើកដំបូង និងឈ្មោះប្រទេស ដែលបានដាក់ពាក្យលើកដំបូង:

____________________________________________________________

____________________________________________________________

*ត្រូវភ្ជាប់ច្បាប់ចំលងនៃឯកសារសុំសិទ្ធិជាអាទិភាព ដោយមានបញ្ជាក់ភាពស្របច្បាប់ នៃឯកសារនោះ

**ផ្នែកទី ៤ : ការកំរិតកំណត់ ឬ លក្ខខណ្ឌនានា**

បំពេញក្នុងបន្ទាត់ខាងក្រោម នូវការយល់ព្រមទទួលយកលក្ខ័ណ្ឌ ឬ ការបដិសេធ ឬ ការកំរិតកំណត់នានានៅពេលដែលម៉ាកនេះនឹងត្រូវបានចុះបញ្ជី:

**ផ្នែកទី ៥ : ហត្ថលេខារបស់អ្នកស្នើសុំ ឬ ភ្នាក់ងារតំណាង**

សំគាល់: ប្រសិនបើផ្នែកនេះត្រូវបានចុះហត្ថលេខាដោយភ្នាក់ងារតំណាងក្នុងនាមអ្នកស្នើសុំ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិមកជាមួយផង ។

(ក) : ហត្ថលេខា :________________________________

(ខ) : ឈ្មោះអ្នកចុះហត្ថលេខា :________________________

(គ) : តួនាទី ឋាន: ________________________________

(គ) : ថ្ងៃ ខែចុះហត្ថលេខា :__________________________

1835
12/08/15

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: 0៩ʊ សរណន

6274
12/08
1835

# សារាចរណែនាំ
## ស្តីពី
## ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

អនុលោមតាម ព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងសំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃ ដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និងការនាំចូលនិងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំអំពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ដូចតទៅ៖

១- សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកលើមុខទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ជាធរមាន។

២- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅមិនធ្វើពាណិជ្ជកម្ម ឬសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍ និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ ឬទំនិញប្រើរួចគ្រប់ប្រភេទ មិនស្ថិតក្រោមវិសាលភាពអនុវត្តនៃការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខឡើយ។

៣- ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការកត់ត្រាទទួលស្គាល់លិខិតប្រគល់សិទ្ធិនាំចូលជាទំនិញពាក់ម៉ាកផ្តាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន។

៤- អ្នកទិញយកទៅប្រើប្រាស់ ឬដើម្បីលក់ចែកចាយបន្ត អាចទិញទំនិញពីអ្នកចែកចាយប្រចាំបណ្តាខេត្ត រាជធានី ឬតំបន់ផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានការរើសអើង។ ក្នុងករណីដែលក្រសួងមានសមត្ថកិច្ចរកឃើញថា ក្រុមហ៊ុនណាមួយអនុវត្តផ្ទុយនឹងការណែនាំនេះ នឹងត្រូវបានធ្វើមោឃភាពនូវលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬទទួលទោសប្បញ្ញត្តិចែងក្នុងមាត្រាច្បាប់ជាធរមាន។

៥- ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសកំណត់នីតិវិធីលម្អិតស្តីពី ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខឲ្យមានអនុលោមភាពតាមកិច្ចព្រមព្រៀងអន្តរជាតិ បញ្ញត្តិនៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន និងស្របតាមសារាចរណែនាំនេះ សំដៅធានាឲ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ និងបម្រើឲ្យផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងសាធារណជនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦- ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្តាក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចុះណែនាំដល់ក្រុមហ៊ុន អាជីវករ និងប្រជាជន អំពីខ្លឹមសារសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឲ្យបានទូលាយ និងអនុវត្តក្នុងដែនសមត្ថកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព និងប្រកបទៅដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ៣ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# **អនុសាសន៍រួម ស្តីពីអាជ្ញាប័ណ្ណម៉ាក**

*អនុម័តដោយ*
សន្និបាតនៃសហភាពទីក្រុងប៉ារីសសម្រាប់
កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម

និង

មហាសន្និបាតនៃ
អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)

ក្នុង

កិច្ចប្រជុំបន្តបន្ទាប់លើក៣៥ នៃ
សន្និបាតនានារបស់រដ្ឋជាសមាជិកនៃអង្គការWIPO
ថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០០

# បុព្វកថា

អនុសាសន៍រួម ស្តីអំពីអាជ្ញាប័ណ្ណម៉ាក ដែលរួមមានអត្ថបទនៃបទប្បញ្ញត្តិទាំងឡាយ ដែលបានអនុម័តដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីអំពីច្បាប់ម៉ាក គំនូរឧស្សាហកម្ម និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ(SCT) នៅសម័យប្រជុំលើកទីបួនរបស់ខ្លួន (ថ្ងៃទី២៧ដល់៣១ ខែមីនា ឆ្នាំ២០០០) ត្រូវបានអនុម័តនៅសម័យប្រជុំរួមនៃសន្និបាតសហភាពទីក្រុងប៉ារីស សម្រាប់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងនៅមហាសន្និបាតអង្គការកម្ម សិទ្ធិបញ្ញាពិភព លោក (WIPO) នៅកិច្ចប្រជុំបន្តបន្ទាប់លើកទី៣៥ នៃសន្និបាតទាំងឡាយរបស់រដ្ឋជាសមាជិក អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (ថ្ងៃទី២៥ ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ២០០០)។

សេចក្តីព្រាងបទប្បញ្ញត្តិ ស្តីអំពីអាជ្ញាប័ណ្ណម៉ាក ត្រូវបានលើកមកពិចារណាដោយ គណៈកម្មាធិការជំនាញរបស់អង្គការWIPO ស្តីពីអាជ្ញាប័ណ្ណម៉ាក នៅសម័យប្រជុំលើកទីមួយ របស់ខ្លួន (ថ្ងៃទី១៧ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៧)។ គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីច្បាប់ ម៉ាក គំនូរឧស្សាហកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ(SCT) បានបន្តការងាររបស់ខ្លួន នៅសម័យប្រជុំលើកទីមួយ (ថ្ងៃទី១៣ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨) សម័យប្រជុំ លើកទី បី (ថ្ងៃទី៨ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៩) និងសម័យប្រជុំលើកទីបួនរបស់ខ្លួន (ថ្ងៃទី២៧ ដល់ថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០០០)។

អនុសាសន៍រួមនេះ មានបំណងធ្វើសុខដុមនីយកម្មនិងធ្វើឱ្យសាមញ្ញនូវលក្ខខណ្ឌទម្រង់ សម្រាប់ចុះបញ្ជីអាជ្ញាប័ណ្ណម៉ាកនិងបំពេញបន្ថែមឱ្យសន្ធិសញ្ញាស្តីពីច្បាប់ម៉ាក(TLT) ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ១៩៩៤ ដែលរៀបចំឡើងដើម្បីធ្វើឱ្យមានប្រសិទ្ធភាព និងធ្វើសុខដុមនីយកម្ម លក្ខខណ្ឌទម្រង់ ដែលកំណត់ដោយការិយាល័យជាតិឬតំបន់ សម្រាប់ការដាក់ពាក្យស្នើសុំចុះ បញ្ជីម៉ាកជាតិឬតំបន់ ការកត់ត្រាការផ្លាស់ប្តូរនិងការចុះបញ្ជីម៉ាកសាជាថ្មី។

បន្ថែមទៅលើការអនុម័តដោយអង្គការWIPOក្នុងខែកញ្ញា ឆ្នាំ១៩៩៩នៃអនុសាសន៍រួម ដែលទាក់ទងនឹងបទប្បញ្ញត្តិស្តីពីកិច្ចការពារម៉ាកល្បី អនុសាសន៍រួមនេះ ជាសមិទ្ធផលទីពីរនៃ គោលនយោបាយរបស់អង្គការWIPO ដើម្បីសម្របទៅតាមជំហាននៃផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ក្នុងវិស័យកម្មសិទ្ធិឧស្សាហកម្ម ដោយការពិចារណាលើជម្រើសថ្មីៗសម្រាប់ពន្លឿនការអភិ វឌ្ឍន៍គោលការណ៍រួមដែលមានសុខដុមនីយកម្មជាអន្តរជាតិ។ បញ្ហានៃគំនិតថ្មីចំពោះការអភិ វឌ្ឍន៍ប្រកបដោយវឌ្ឍនភាពនៃច្បាប់កម្មសិទ្ធិបញ្ញាអន្តរជាតិត្រូវបានអនុវត្តដោយអង្គការWIPO

ស្របតាមកម្មវិធីនិងថវិកាអង្គការWIPO សម្រាប់រយៈពេលពីរឆ្នាំ១៩៩៨-៩៩។

ឯកសារនេះមានអត្ថបទនៃអនុសាសន៍រួម ដែលអមដោយបទប្បញ្ញត្តិទាំងឡាយ រួមទាំង ទម្រង់គំរូអន្តរជាតិនិងកំណត់ពន្យល់ទាំងឡាយ ដែលបានរៀបចំដោយការិយាល័យអន្តរជាតិ។

# មាតិកា

ទំព័រ

អនុសាសន៍រួម
មាត្រា១: ពាក្យបំព្រួញ.........................................................................................................០៦
មាត្រា២: សំណើសុំចុះបញ្ជីអាជ្ញាប័ណ្ណ.................................................................................០៧
មាត្រា៣:សំណើសុំធ្វើវិសោធនកម្ម ឬលុបចោលការចុះបញ្ជី...........................................០៩
មាត្រា៤: អានុភាពនៃការមិនចុះបញ្ជីអាជ្ញាប័ណ្ណ...............................................................០៩
មាត្រា៥: ការប្រើប្រាស់ម៉ាកក្នុងនាមម្ចាស់.........................................................................១០
មាត្រា៦: ការចង្អុលបង្ហាញនៃអាជ្ញាប័ណ្ណ.........................................................................១០
ទម្រង់គំរូអន្តរជាតិ..................................................................................................................១១
កំណាត់ពន្យល់នានា ដែលបានរៀបចំដោយការិយាល័យអន្តរជាតិ...................................២៥

# **អនុសាសន៍រួម**

សន្និបាតសហភាពទីក្រុងប៉ារីសសម្រាប់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម និងមហាសន្និបាតរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO)

*ដោយពិចារណាពី* បទប្បញ្ញត្តិនានានៃអនុសញ្ញាទីក្រុងប៉ារីស សម្រាប់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្មនិង នៃសន្ធិសញ្ញាស្តីពីច្បាប់ម៉ាក(TLT)

*ផ្តល់អនុសាសន៍ថា* រដ្ឋជាសមាជិកនីមួយៗ អាចពិចារណាអំពីការប្រើប្រាស់បទប្បញ្ញត្តិណាមួយដែលអនុម័តដោយគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីអំពីច្បាប់ម៉ាក គំនូរឧស្សាហកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ(SCT) នៅសម័យប្រជុំលើកទី៤របស់ខ្លួន ជាមគ្គុទ្ទេសក៍ទាក់ទងនឹងអាជ្ញាប័ណ្ណម៉ាក

*ផ្តល់អនុសាសន៍បន្ថែមទៀត* ដល់រដ្ឋជាសមាជិកនីមួយៗ នៃសហភាពទីក្រុងប៉ារីស ឬនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលជាសមាជិកផងដែរនៃអង្គការអន្តររដ្ឋាភិបាលតំបន់ដែលមានសមត្ថកិច្ចក្នុងការចុះបញ្ជីម៉ាក ឱ្យអង្គការនេះយកចិត្តទុកដាក់លើ បទប្បញ្ញត្តិទាំងនេះ។

បទប្បញ្ញត្តិទាំងឡាយមានដូចខាងក្រោមៈ

## មាត្រា ១

## ពាក្យបំព្រួញ

សម្រាប់គោលបំណងនៃសេចក្ដីព្រាងបទប្បញ្ញត្តិទាំងនេះ លែកលែងតែចែងច្បាស់ផ្សេងពីនេះ:

i. "ការិយាល័យ" សំដៅដល់ ភ្នាក់ងារណាមួយ ដែលរដ្ឋជាសមាជិកប្រគល់កិច្ចការចុះបញ្ជីឱ្យ

ii. "ការចុះបញ្ជី" សំដៅដល់ ការចុះបញ្ជីម៉ាក ដោយការិយាល័យមួយ

iii. "ពាក្យស្នើសុំ" សំដៅដល់ ពាក្យស្នើសុំចុះបញ្ជី

iv. "ម៉ាក" សំដៅដល់ ម៉ាកមួយចំពោះទំនិញ (ពាណិជ្ជសញ្ញា) ឬចំពោះសេវា (សេវាសញ្ញា) ឬចំពោះទាំងទំនិញនិងសេវា

v. "ម្ចាស់" សំដៅដល់ បុគ្គលដែលការចុះបញ្ជីម៉ាក បង្ហាញថាជាម្ចាស់នៃការចុះបញ្ជី

vi. "ចំណាត់ថ្នាក់ទីក្រុងនីស" សំដៅដល់ ចំណាត់ថ្នាក់ ដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងទីក្រុងនីសទាក់ទងនឹងចំណាត់ថ្នាក់ជាអន្តរនៃទំនិញនិងសេវាសម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ដែលបានចុះហត្ថលេខានៅទីក្រុងនីស ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥៧ ដែលបានកែប្រែ និងធ្វើវិសោធនកម្ម

vii. "អាជ្ញាប័ណ្ណ" សំដៅដល់ អាជ្ញាប័ណ្ណសម្រាប់ប្រើប្រាស់ម៉ាក តាមច្បាប់ដែលអនុវត្តនៃរដ្ឋជាសមាជិក

viii. "អ្នកទទួលអាជ្ញាប័ណ្ណ" សំដៅដល់បុគ្គល ដែលម្ចាស់បានផ្ដល់អាជ្ញាប័ណ្ណឱ្យ

ix. "អាជ្ញាប័ណ្ណផ្ដាច់មុខ" សំដៅដល់ អាជ្ញាប័ណ្ណដែលផ្ដល់ឱ្យតែអ្នកទទួលអាជ្ញាប័ណ្ណមួយប៉ុណ្ណោះហើយដកម្ចាស់ចេញពីការប្រើប្រាស់ម៉ាកនិងពីការផ្ដល់អាជ្ញាប័ណ្ណទៅបុគ្គលណាម្នាក់ផ្សេងទៀត។

x. "អាជ្ញាប័ណ្ណតែមួយ" សំដៅដល់ អាជ្ញាប័ណ្ណ ដែលផ្ដល់ឱ្យតែ អ្នកទទួលអាជ្ញាប័ណ្ណមួយប៉ុណ្ណោះ ហើយដកម្ចាស់ចេញពីការផ្ដល់អាជ្ញាប័ណ្ណ ឱ្យបុគ្គលណាមួយផ្សេងទៀត ប៉ុន្តែមិនដកម្ចាស់ចេញពីការប្រើប្រាស់ម៉ាកទេ

xi. "អាជ្ញាប័ណ្ណមិនផ្ដាច់មុខ" សំដៅដល់ អាជ្ញាប័ណ្ណ ដែលមិនដកម្ចាស់ចេញពីការប្រើប្រាស់ម៉ាក ឬពីការផ្ដល់អាជ្ញាប័ណ្ណឱ្យបុគ្គលណាមួយផ្សេងទៀត។

## មាត្រា២
## សំណើចុះបញ្ជីអាជ្ញាប័ណ្ណ

(១) [*មាតិកានៃសំណើចុះបញ្ជី* ] នៅពេលដែលច្បាប់រដ្ឋជាសមាជិកមួយ ចែងពីការចុះបញ្ជីអាជ្ញាប័ណ្ណនៅការិយាល័យរបស់ខ្លួន រដ្ឋជាសមាជិកនេះ អាចតម្រូវឱ្យមានសំណើចុះបញ្ជី ដែលមានការចង្អុលបង្ហាញឬធាតុមួយចំនួន ឬទាំងអស់ដូចខាងក្រោម:

i. ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់
ii. នៅពេលដែលម្ចាស់មានតំណាង គឺឈ្មោះនិងអាសយដ្ឋានតំណាងនោះ
iii. នៅពេលដែលម្ចាស់មានអាសយដ្ឋានសម្រាប់សេវា គឺអាសយដ្ឋាននេះ
iv. ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ
v. នៅពេលដែលអ្នកទទួលអាជ្ញាប័ណ្ណមានតំណាង គឺឈ្មោះនិងអាសយដ្ឋាននៃអ្នកតំណាងនោះ
vi. នៅពេលដែលអ្នកទទួលអាជ្ញាប័ណ្ណ មានអាសយដ្ឋានសម្រាប់សេវា គឺអាសយដ្ឋាននេះ
vii. ឈ្មោះរដ្ឋដែលអ្នកទទួលអាជ្ញាប័ណ្ណជាពលរដ្ឋ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណជាពលរដ្ឋនៃរដ្ឋណាមួយ គឺឈ្មោះរដ្ឋ ដែលអ្នកទទួលអាជ្ញាប័ណ្ណមានលំនៅឋាន ប្រសិនបើមាន និងឈ្មោះរដ្ឋដែលអ្នកទទួលអាជ្ញាប័ណ្ណមានសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការ ប្រសិនបើមាន
viii. នៅពេលដែលម្ចាស់ឬអ្នកទទួលអាជ្ញាប័ណ្ណ ជានីតិបុគ្គល គឺលក្ខណៈផ្លូវច្បាប់នៃនីតិបុគ្គលនេះនិងឈ្មោះរដ្ឋ ហើយ នៅពេលដែលអនុវត្តបាន តំបន់ដែនដីក្នុងរដ្ឋនេះ តាមច្បាប់ដែលបង្កើតនីតិបុគ្គលនេះ
ix. លេខចុះបញ្ជីម៉ាក ដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណ
x. ឈ្មោះទំនិញនិង/ឬសេវា ដែលទទួលបានអាជ្ញាប័ណ្ណ កំណត់ជាក្រុមតាមថ្នាក់នៃចំណាត់ថ្នាក់ទីក្រុងនីស ក្រុមនីមួយៗនាំមុខដោយលេខថ្នាក់នៃចំណាត់ថ្នាក់របស់ក្រុមទំនិញឬសេវានោះ ហើយបង្ហាញតាមលំដាប់ថ្នាក់នៃចំណាត់ថ្នាក់នេះ
xi. នៅពេលដែលអនុវត្តបាន អាជ្ញាប័ណ្ណ ជាអាជ្ញាប័ណ្ណផ្តាច់មុខ អាជ្ញាប័ណ្ណមិនផ្តាច់មុខ ឬអាជ្ញាប័ណ្ណតែមួយ

xii. នៅពេលដែលអនុវត្តបាន អាជ្ញាប័ណ្ណពាក់ព័ន្ធតែផ្នែកមួយនៃដែនដីដែលគ្រប់គ្រងដោយការចុះបញ្ជី រួមជាមួយការចង្អុលបង្ហាញជាក់លាក់ផ្នែកនៃដែនដីនោះ

xiii. រយៈពេលនៃអាជ្ញាប័ណ្ណ

xiv. ការចុះហត្ថលេខាដូចមានចែងក្នុងកថាខណ្ឌ(២)។

(២) [ការចុះហត្ថលេខា] (ក) រដ្ឋជាសមាជិកមួយ ត្រូវទទួលយកការចុះហត្ថលេខារបស់ម្ចាស់ ឬតំណាងរបស់ម្ចាស់ ទោះបីជា មានឬគ្មានអមដោយការចុះហត្ថលេខាអ្នកទទួលអាជ្ញាប័ណ្ណ ឬតំណាងរបស់អ្នកទទួលអាជ្ញាប័ណ្ណក៏ដោយ។

(ខ) រដ្ឋជាសមាជិកមួយត្រូវទទួលយកផងដែរនូវការចុះហត្ថលេខាអ្នកទទួលអាជ្ញាប័ណ្ណ ឬតំណាងរបស់អ្នកទទួលអាជ្ញាប័ណ្ណ ទោះបីជាគ្មានអមដោយហត្ថលេខាម្ចាសឬតំណាង របស់ម្ចាស់ក៏ដោយ ឱ្យតែភ្ជាប់នូវឯកសារដូចខាងក្រោមៈ

i. សម្រង់កិច្ចសន្យាអាជ្ញាប័ណ្ណ ដែលបង្ហាញពីភាគីទាំងឡាយ និងសិទ្ធិផ្តល់អាជ្ញាប័ណ្ណ ដែលបញ្ជាក់ថាត្រឹមត្រូវដោយសារការី ឬអាជ្ញាធរសាធារណៈដែលមានសមត្ថកិច្ចផ្សេងទៀតណាមួយ ថាពិតជាស្រង់ចេញពីកិច្ចសន្យា

ii. សេចក្តីថ្លែងការណ៍ដែលមិនបានបញ្ជាក់នៃអាជ្ញាប័ណ្ណ ដែលធ្វើឡើងក្នុងទម្រង់និងមានមាតិកាដូចបានកំណត់ក្នុងសេចក្តីថ្លែងការណ៍នៃទម្រង់អាជ្ញាប័ណ្ណដែលមានក្នុងឧបសម្ព័ន្ធនៃបទប្បញ្ញត្តិទាំងនេះហើយត្រូវបានចុះហត្ថលេខាដោយម្ចាស់ឬតំណាងរបស់ម្ចាស់និងអ្នកទទួលអាជ្ញាប័ណ្ណឬតំណាងអ្នកទទួលអាជ្ញាប័ណ្ណ ។

(៣) [*ការបង្ហាញសំណើ*] ចំពោះលក្ខខណ្ឌដែលទាក់ទងនឹងការបង្ហាញសំណើ រដ្ឋជាសមាជិកមិនត្រូវបដិសេធសំណើ នៅពេលដែលការបង្ហាញនិងការរៀបចំការចង្អុលបង្ហាញនិងធាតុក្នុងសំណើ ទាកទងនឹងការបង្ហាញនិងការរៀបចំការចង្អុលបង្ហាញនិងធាតុក្នុងទម្រង់សំណើដែលមានក្នុងឧបសម្ព័ន្ធ នៃបទប្បញ្ញត្តិទាំងនេះ។

(៤) [*ភាសា ការបកប្រែ* ] (ក) រដ្ឋជាសមាជិក អាចតម្រូវឱ្យសំណើធ្វើជាភាសា ឬក្នុងភាសាណាមួយ ដែលការិយាល័យទទួលយក។

(ខ) រដ្ឋជាសមាជិកអាចតម្រូវថា ប្រសិនបើ ឯកសារយោងទៅកថាខណ្ឌ(២)(ខ)(i)ឬ(ii) មិនធ្វើជាភាសាឬជាភាសាណាមួយដែលការិយាល័យទទួលយក សំណើត្រូវអមដោយការបក

ប្រែដែលមានការបញ្ជាក់ នៃឯកសារដែលតម្រូវក្នុងភាសាឬក្នុងភាសាណាមួយដែលការិយាល័យទទួលយក។

(៥) [*កម្រៃ* ] ចំពោះការចុះបញ្ជីអាជ្ញាប័ណ្ណ រដ្ឋជាសមាជិកណាមួយអាចតម្រូវឱ្យបង់កម្រៃ ទៅការិយាល័យ។

(៦) [*សំណើតែមួយទាក់ទងនឹងការចុះបញ្ជីច្រើន* ] សំណើតែមួយត្រូវមានលក្ខណៈគ្រប់គ្រាន់ ទោះបីជាអាជ្ញាប័ណ្ណទាក់ទងនឹងការចុះបញ្ជីច្រើនជាងមួយក៏ដោយ ឱ្យតែលេខចុះបញ្ជីនៃការចុះបញ្ជីទាំងអស់ដែលពាក់ព័ន្ធ ត្រូវបានបង្ហាញក្នុងសំណើ ម្ចាស់និងអ្នកទទួលអាជ្ញាប័ណ្ណមានមួយសម្រាប់ការចុះបញ្ជីទាំងអស់ ហើយសំណើបង្ហាញពីវិសាលភាពនៃអាជ្ញាប័ណ្ណតាមកថាខណ្ឌ(១) ចំពោះការចុះបញ្ជីទាំងអស់។

[៧] *[ការហាមឃាត់លក្ខខណ្ឌតផ្សេងទៀត]* រដ្ឋជាសមាជិកមិនអាចតម្រូវឱ្យមានលក្ខខណ្ឌផ្សេងពីលក្ខខណ្ឌដែលត្រូវបំពេញដូចមានចែងក្នុងកថាខណ្ឌ(១)ដល់(៦) ចំពោះការចុះបញ្ជីអាជ្ញាប័ណ្ណនៅការិយាល័យរបស់ខ្លួន។ ជាពិសេស ចំណុចដូចខាងក្រោម អាចមិនត្រូវតម្រូវៈ

i. ឱ្យផ្តល់វិញ្ញាបនបត្រចុះបញ្ជីម៉ាក ដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណ

ii. ឱ្យផ្តល់កិច្ចសន្យាអាជ្ញាប័ណ្ណ ឬការបកប្រែកិច្ចសន្យានេះ

iii. ឱ្យបង្ហាញពីលក្ខខណ្ឌហិរញ្ញវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណ។

(៨) [*សំណើទាក់ទងនឹងពាក្យស្នើសុំចុះបញ្ជី* ] កថាខណ្ឌ(១) ដល់(៧) ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះសំណើចុះបញ្ជីអាជ្ញាប័ណ្ណចំពោះពាក្យស្នើសុំចុះបញ្ជី នៅពេលដែលច្បាប់ដែលអនុវត្តនៃរដ្ឋជាសមាជិកមួយ ចែងពីការចុះបញ្ជីបែបនេះ។

## មាត្រា ៣

## សំណើធ្វើវិសោធនកម្ម ឬលុបចោលការចុះបញ្ជី

មាត្រា២ ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះសំណើទាក់ទងនឹងការធ្វើវិសោធនកម្ម ឬការលុបចោលការចុះបញ្ជីអាជ្ញាប័ណ្ណ។

## មាត្រា៤

## អានុភាពនៃការមិនចុះបញ្ជីអាជ្ញាប័ណ្ណ

(១) [*សុពលភាពនៃការចុះបញ្ជី និងកិច្ចការពារម៉ាក* ] ការមិនចុះបញ្ជីអាជ្ញាប័ណ្ណនៅ

ការិយាល័យឬនៅអាជ្ញាធរផ្សេងទៀតណាមួយនៃរដ្ឋជាសមាជិក មិនត្រូវប៉ះពាល់ដល់សុពលភាពនៃការចុះបញ្ជីម៉ាក ដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណ ឬកិច្ចការពារម៉ាកនេះឡើយ។

(២) [*សិទ្ធិមួយចំនួននៃអ្នកទទួលអាជ្ញាប័ណ្ណ*] (ក) រដ្ឋជាសមាជិកមួយ មិនអាចតម្រូវ ឱ្យការចុះបញ្ជីអាជ្ញាប័ណ្ណ ក្លាយជាលក្ខខណ្ឌចំពោះសិទ្ធិណាមួយ ដែលអ្នកទទួលអាជ្ញាប័ណ្ណ អាចមាន តាមច្បាប់រដ្ឋជាសមាជិកនេះ ដើម្បីចូលរួមក្នុងបណ្ដឹងរំលោភបំពានដែលផ្ដួចផ្ដើមឡើងដោយម្ចាស់ ឬ តាមរយៈបណ្ដឹងនេះ ទទួលបានសំណងការខូចខាត ដែលបណ្ដាលមកពីការរំលោភបំពានម៉ាក ដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណ។

(ខ) ប្រសិនបើអនុកថាខណ្ឌ(ក) មិនស្របនឹងច្បាប់ជាតិនៃរដ្ឋជាសមាជិកមួយ អនុកថាខណ្ឌនេះ មិនត្រូវអនុវត្តចំពោះរដ្ឋជាសមាជិកនេះទេ។

## មាត្រា៥

## ការប្រើប្រាស់ម៉ាកក្នុងនាមម្ចាស់

ការប្រើប្រាស់ម៉ាកមួយដោយរូបវន្តបុគ្គលឬនីតិបុគ្គលក្រៅពីម្ចាស់ ត្រូវចាត់ទុកថាបង្កើតជាការប្រើប្រាស់ដោយម្ចាស់ផ្ទាល់ ប្រសិនបើការប្រើប្រាស់នេះ ត្រូវបានធ្វើឡើងដោយមានការយល់ព្រមពីម្ចាស់។

## មាត្រា៦

## ការចង្អុលបង្ហាញនៃអាជ្ញាប័ណ្ណ

នៅពេលដែលច្បាប់រដ្ឋជាសមាជិក តម្រូវឱ្យចង្អុលបង្ហាញថាម៉ាកត្រូវបានប្រើប្រាស់ក្រោមអាជ្ញាប័ណ្ណ ការមិនស្របតាមទាំងស្រុងឬដោយផ្នែកនឹងលក្ខខណ្ឌនេះ មិនប៉ះពាល់ដល់សុពលភាពនៃការចុះបញ្ជីម៉ាក ដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណឬកិច្ចការពារម៉ាកហើយ មិនត្រូវប៉ះពាល់ដល់ការអនុវត្តមាត្រា៥ឡើយ។

**ឧបសម្ព័ន្ធ**
**ទម្រង់គំរូអន្តរជាតិ លេខ.១**
**សំណើចុះបញ្ជីអាជ្ញាប័ណ្ណ**

## សំណើធ្វើវិសោធនកម្ម/លុបចោលការចុះបញ្ជីអាជ្ញាប័ណ្ណ

ចំពោះពាក្យស្នើសុំចុះបញ្ជី និង/ឬ ម៉ាកដែលបានចុះបញ្ជី
ដែលបានដាក់នៅការិយាល័យនៃ.........

| |
|---|
| សម្រាប់ការិយាល័យប្រើប្រាស់តែប៉ុណ្ណោះ |

| |
|---|
| ការចង្អុលបង្ហាញយោងនៃម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី និង/ឬ អ្នកទទួលអាជ្ញាប័ណ្ណ:[1]...................... |
| ការចង្អុលបង្ហាញយោងនៃតំណាងម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី: ........................ |
| អ្នកទទួលអាជ្ញាប័ណ្ណ:[1] .................. |

---

១. សំណើសុំ[2]

☐ ការកត់ត្រាការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីដែលមានក្នុងសំណើនេះ ដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណ ត្រូវស្នើតាមនេះ។

☐ វិសោធនកម្មការចុះបញ្ជីអាជ្ញាប័ណ្ណដែលទាក់ទងនឹងការចុះបញ្ជី និង/ឬពាក្យស្នើសុំចុះបញ្ជីដែលមានក្នុងសំណើនេះ ត្រូវស្នើតាមនេះ។

---

[1] ការចង្អុលបង្ហាញយោងណាមួយ ដែលផ្តល់ដោយម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនិង/ឬ អ្នកទទួលអាជ្ញាប័ណ្ណនិង/ឬការចង្អុលបង្ហាញយោងណាមួយ ដែលផ្តល់ដោយតំណាងណាមួយ ចំពោះសំណើនេះ អាចត្រូវបានផ្តល់ឱ្យក្នុងកន្លែងចំហនេះ។

[2] ពិនិត្យប្រអប់ដែលត្រឹមត្រូវ។

☐ ការលុបចោលការចុះបញ្ជីអាជ្ញាប័ណ្ណ ដែលទាក់ទងនឹងការចុះបញ្ជី និង/ឬ ពាក្យស្នើសុំចុះបញ្ជីដែលមានក្នុងសំណើនេះ ត្រូវស្នើតាមនេះ។

---

**២. ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីដែលពាក់ព័ន្ធ**

សំណើនេះ ពាក់ព័ន្ធនឹងការចុះបញ្ជី និង/ឬពាក្យស្នើសុំចុះបញ្ជីដូចខាងក្រោម:

២.១ លេខចុះបញ្ជី និង/លេខពាក្យស្នើសុំចុះបញ្ជី:

២.២ ☐ ប្រសិនបើកន្លែងចំហាក្រោមចំនុច២.១ មិនគ្រប់គ្រាន់ ពិនិត្យប្រអប់នេះ ហើយផ្តល់ព័ត៌មានតាមរយៈក្រដាសដែលបន្ថែម។

---

**៣. ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី**

៣.១ ប្រសិនបើម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ជារូបវន្តបុគ្គល

(ក) គោត្តនាមឬឈ្មោះពិតប្រាកដរបស់រូបវន្តបុគ្គល:[3]

(ខ) ឈ្មោះក្រៅ ឬឈ្មោះទីពីររបស់រូបវន្តបុគ្គ:[3]

៣.២ ប្រសិនបើម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ជានីតិបុគ្គល

(ក) ឈ្មោះផ្លូវការពេញរបស់នីតិបុគ្គល:

(ខ) លក្ខណៈផ្លូវច្បាប់នៃនីតិបុគ្គល:

(គ) រដ្ឋ និង នៅពេលដែលអនុវត្តបាន តំបន់ដែនដីក្នុងរដ្ឋនោះតាមច្បាប់ដែលបង្កើតនីតិបុគ្គលនេះ:

៣.៣ អាសយដ្ឋាន (រួមទាំង លេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស):

លេខទូរស័ព្ទ:[4] លេខទូរសារ:[4]

---

[3] ឈ្មោះទាំងឡាយ ដែលត្រូវបង្ហាញតាមចំនុច (ក) និង(ខ) គឺជាឈ្មោះ ដែលមានក្នុងកំណត់ត្រាការិយាល័យចំពោះម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនៃការចុះបញ្ជី/ពាក្យស្នើសុំចុះបញ្ជីដែលពាក់ព័ន្ធសំណើនេះ។

[4] ទោះបីជា ការិយាល័យជ្រើសរើសដើម្បីស្នើព័ត៌មាននេះក៏ដោយ ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬតំណាងរបស់ខ្លួន មានជម្រើសមិនផ្តល់ការចង្អុលបង្ហាញនេះ។ នៅពេលដែលផ្តល់ការចង្អុលបង្ហាញនេះ គួរ ត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

៣.៤ ☐ ពិនិត្យប្រអប់នេះ ប្រសិនបើមានម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី លើសពីម្នាក់ ក្នុងករណីនេះ រាយឈ្មោះម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបន្ថែមលើក្រដាស ដោយឡែកមួយ ហើយចង្អុលបង្ហាញទិន្នន័យដូចមានចែងក្នុងចំនុច៣.១ ឬ៣.២ និង៣.៣ ចំពោះបុគ្គលនីមួយៗនេះ។

---

## ៤. តំណាងម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី

៤.១ ឈ្មោះ:

៤.២ អាសយដ្ឋាន (រួមទាំងលេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស)

លេខទូរស័ព្ទ:[5] លេខទូរសារ:[5]

៤.៣ លេខចុះបញ្ជី ប្រសិនបើចុះបញ្ជីនៅការិយាល័យ:

៤.៤ លេខ ដែលផ្តល់ឱ្យដោយមេធាវី:[6]

---

៥. អាសយដ្ឋានសម្រាប់សេវានៃម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី[7]

---

៦. អ្នកទទួលអាជ្ញាប័ណ្ណ

៦.១ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ ជារូបវន្តបុគ្គល

---

[5] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬតំណាងរបស់ខ្លួន មានជម្រើមិនផ្តល់ការចង្អុលបង្ហាញនេះ។ នៅពេលផ្តល់ការចង្អុលបង្ហាញនេះ គួរត្រូវ បញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

[6] ទុកចន្លោះចោល ប្រសិនបើលិខិតពឹងមេធាវី មិនបាន ឬមិនទាន់បានផ្តល់លេខឱ្យ ឬប្រសិនបើ លេខ មិនត្រូវបានដឹងដល់ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬតំណាង។

[7] តាមមាត្រា ៤(២)(ខ)នៃTLT អាសយដ្ឋានសម្រាប់សេវា ត្រូវតែបង្ហាញក្នុងចន្លោះដែលមានក្រោមចំណងជើងនៃចំនុច៥ នៅពេលដែលម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនបាន ឬមិនទាន់បានបង្ហាញពីលំនៅឋាន ឬសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការលើដែនដីភាគីហត្ថលេខី ដែលការិយាល័យរបស់ខ្លួនជាការិយាល័យដែលមានឈ្មោះនៅទំព័រដំបូងនៃសំណើនេះ លើកលែងតែតំណាង ត្រូវបានបង្ហាញក្នុងចំនុច៤។

(ក) គោត្តនាមឬឈ្មោះពិតប្រាកដនៃរូបវន្តបុគ្គលៈ

(ខ) ឈ្មោះក្រៅ ឬឈ្មោះទីពីរៈ

៦.២ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ ជានីតិបុគ្គល

(ក) ឈ្មោះជាផ្លូវការពេញរបស់នីតិបុគ្គលៈ

(ខ) លក្ខណៈផ្លូវច្បាប់នៃនីតិបុគ្គលៈ

(គ) រដ្ឋ ហើយ នៅពេលដែលអនុវត្តបាន តំបន់ដែនដីក្នុងរដ្ឋនោះ តាមច្បាប់ដែលបង្កើតនីតិបុគ្គលនេះ។

---

---

៦.៣ អាសយដ្ឋាន (រួមទាំងលេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស)

លេខទូរស័ព្ទៈ[8] លេខទូរសារៈ[8]

៦.៤ រដ្ឋនៃសញ្ជាតិរបស់អ្នកទទួលអាជ្ញាប័ណ្ណៈ

៦.៥ រដ្ឋនៃលំនៅឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណៈ

៦.៦ រដ្ឋនៃសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការ របស់អ្នកទទួលអាជ្ញាប័ណ្ណៈ

៦.៧ ☐ ពិនិត្យប្រអប់នេះ ប្រសិនបើមានអ្នកទទួលអាជ្ញាប័ណ្ណលើសពីម្នាក់។ ក្នុងករណីនេះ រាយនាមអ្នកទទួលអាជ្ញាប័ណ្ណបន្ថែមនីមួយៗលើក្រដាសមួយដោយឡែក ហើយបង្ហាញទិន្នន័យដូចមានក្នុងចំនុច៦.១ដល់៦.៦ ចំពោះអ្នកទទួលអាជ្ញាប័ណ្ណនីមួយៗ។

---

៧. តំណាងអ្នកទទួលអាជ្ញាប័ណ្ណៈ

៧.១ ឈ្មោះៈ

៧.២ អាសយដ្ឋាន (រួមទាំងលេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស)ៈ

លេខទូរស័ព្ទៈ[9] លេខទូរសារៈ[9]

---

[8] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ អ្នកទទួលអាជ្ញាប័ណ្ណឬតំណាងរបស់ខ្លួន មានជម្រើសមិនផ្តល់ការចង្អុលបង្ហាញនេះ។ នៅពេលដែលផ្តល់ការចង្អុលបង្ហាញនេះ គួរត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

៧.៣ លេខចុះបញ្ជី ប្រសិនបើបានចុះបញ្ជីនៅការិយាល័យ:

៧.៤ លេខ ដែលផ្តល់ឱ្យលិខិតពឹងមេធាវី:[10]

---

---

**៨. អាសយដ្ឋានសម្រាប់សេវារបស់អ្នកទទួលអាជ្ញាប័ណ្ណ[11]:**

---

**៩. ទំនិញនិង/ឬសេវាដែលផ្តល់អាជ្ញាប័ណ្ណ[12]**

៩.១ ☐ អាជ្ញាប័ណ្ណ ត្រូវបានផ្តល់ឱ្យសម្រាប់ទំនិញនិង/ឬសេវាទាំងឡាយ ដែលមានក្នុងការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជី ដូចមានក្នុងចំនុច២។

៩.២ ☐ ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីតែមួយ ត្រូវចែងក្នុងចំនុច២ ហើយអាជ្ញាប័ណ្ណត្រូវបានផ្តល់ឱ្យតែសម្រាប់ទំនិញនិង/សេវាមួយចំនួន ដែលមានក្នុងការចុះបញ្ជីឬពាក្យស្នើសុំចុះបញ្ជី។ ទំនិញនិង/ឬសេវាខាងក្រោម ត្រូវគ្របដណ្តប់ដោយអាជ្ញាប័ណ្ណ:

៩.៣ ☐ ចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីលើសពីមួយ ត្រូវចែងក្នុងចំនុច២ និងចំពោះយ៉ាងហោចណាស់ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីមួយ អាជ្ញាប័ណ្ណគ្របដណ្តប់តិចជាងទំនិញនិង/ឬសេវាទាំងអស់ ដែលមានក្នុងបញ្ជី។ ក្នុងករណីនេះ បង្ហាញ លើក្រដាសបន្ថែមមួយទៀត ដោយឡែកៗចំពោះការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជី នីមួយៗថាតើ

---

[9] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ អ្នកទទួលអាជ្ញាប័ណ្ណឬ តំណាងរបស់ខ្លួនមានជម្រើសមិនផ្តល់ការចង្អុលបង្ហាញនេះ។ នៅពេលដែលផ្តល់ ការចង្អុលបង្ហាញនេះ គួរត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

[10] ទុកចំហ ប្រសិនបើលិខិតពឹងមេធាវី មិនត្រូវបាន ឬមិនទាន់ត្រូវបានផ្តល់លេខឱ្យ ឬប្រសិនបើ លេខនេះ មិនត្រូវបានដឹងដល់អ្នកទទួលអាជ្ញាប័ណ្ណឬតំណាងរបស់ខ្លួន។

[11] តាមមាត្រា៥(២)(ខ)នៃ TLT អាសយដ្ឋានសម្រាប់សេវា ត្រូវបង្ហាញក្នុងចន្លោះដែលមានក្រោមចំណងជើងនៃចំនុច៨ នៅពេលដែលអ្នកទទួលអាជ្ញាប័ណ្ណ គ្មានឬមិនបានបង្ហាញពីលំនៅឋាន ឬសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការលើដែនដីភាគីហត្ថលេខី ដែលការិយាល័យរបស់ខ្លួនជាការិយាល័យដែលមានឈ្មោះនៅទំព័រដំបូងនៃសំណើនេះ លើកលែងតែតំណាងត្រូវបានបង្ហាញក្នុងចំនុច៧។

[12] ពិនិត្យប្រអប់ដែលត្រឹមត្រូវ។

អាជ្ញាប័ណ្ណនេះគ្របដណ្តប់លើទំនិញនិង/ឬសេវាទាំងអស់ ឬ តែលើទំនិញនិង/ឬសេវាមួយចំនួនតែប៉ុណ្ណោះ។

---

១០. ប្រភេទអាជ្ញាប័ណ្ណ[12]

១០.១ ☐ អាជ្ញាប័ណ្ណជាអាជ្ញាប័ណ្ណផ្តាច់មុខ។

១០.២ ☐ អាជ្ញាប័ណ្ណជាអាជ្ញាប័ណ្ណតែមួយ។

១០.៣ ☐ អាជ្ញាប័ណ្ណជាអាជ្ញាប័ណ្ណមិនផ្តាច់មុខ។

១០.៤ ☐ អាជ្ញាប័ណ្ណពាក់ព័ន្ធតែផ្នែកដូចខាងក្រោមនៃដែនដីគ្របដណ្តប់ដោយការចុះបញ្ជី:

---

---

១១. រយៈពេលអាជ្ញាប័ណ្ណ[12]

១១.១ ☐ អាជ្ញាប័ណ្ណនេះត្រូវបានកម្រិតរយៈពេលនិងផ្តល់ឱ្យចាប់

ពី……………………………ដល់………………………..

១១.១.១ ☐ អាជ្ញាប័ណ្ណនេះជាកម្មវត្ថុនៃការពន្យារដោយស្វ័យប្រវត្តិ។

១១.២ ☐ អាជ្ញាប័ណ្ណនេះត្រូវបានផ្តល់ឱ្យសម្រាប់រយៈពេលមិនកំណត់។

---

**១២. ហត្ថលេខា ឬត្រា[13]**

១២.១ ហត្ថលេខាឬត្រារបស់ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី:

១២.១.១ ឈ្មោះម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីឬ ប្រសិនបើម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីជានីតិបុគ្គល គឺឈ្មោះបុគ្គលដែលធ្វើសកម្មភាពក្នុងនាមម្ចាស់ /អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី:

១២.១.២ កាលបរិច្ឆេទនៃហត្ថលេខាឬបោះត្រា:

១២.១.៣ ហត្ថលេខ ឬត្រា:

---

[13] ប្រសិនបើមានបុគ្គលលើសពីម្នាក់ដែលបានចុះហត្ថលេខាឬប្រើប្រាស់ត្រា រាល់ការចង្អុលបង្ហាញទាំងឡាយតាមអនុចំនុច១២.១ ដល់១២.៤ គួរត្រូវបានផ្តល់ឱ្យនៅលើក្រដាសបន្ថែមមួយទៀត។

១២.២ ហត្ថលេខាឬត្រាអ្នកទទួលអាជ្ញាប័ណ្ណ:[14]

១២.២.១ ឈ្មោះអ្នកទទួលអាជ្ញាប័ណ្ណ ឬ ប្រសិនបើ អ្នកទទួលអាជ្ញាប័ណ្ណជានីតិបុគ្គល គឺឈ្មោះបុគ្គល ដែលធ្វើសកម្មភាពក្នុងនាមអ្នកទទួលអាជ្ញាប័ណ្ណ:

១២.២.២ កាលបរិច្ឆេទនៃហត្ថលេខា ឬបោះត្រា:

១២.២.៣ ហត្ថលេខា ឬត្រា:

---

**១២.៣ ហត្ថលេខា ឬត្រារបស់តំណាងម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី:**

១២.៣.១ ឈ្មោះរូបវន្តបុគ្គល ដែលបានចុះហត្ថលេខា ឬបោះត្រា:

១២.៣.២ កាលបរិច្ឆេទនៃការចុះហត្ថលេខាឬបោះត្រា:

១២.៣.៣ ហត្ថលេខាឬត្រា:

**១២.៤ ហត្ថលេខា ឬត្រារបស់តំណាងអ្នកទទួលអាជ្ញាប័ណ្ណ:**

១២.៤.១ ឈ្មោះរូបវន្តបុគ្គល ដែលបានចុះហត្ថលេខាឬបោះត្រា:

១២.៤.២ កាលបរិច្ឆេទនៃការចុះហត្ថលេខា ឬបោះត្រា:

១២.៤.៣ ហត្ថលេខា ឬត្រា:

---

**១៣. កម្រៃ**

១៣.១ រូបិយវត្ថុនិងចំនួនកម្រៃ ដែលត្រូវបង់ចំពោះសំណើនេះ:

១៣.២ មធ្យោបាយទូទាត់:

---

[14] ហត្ថលេខាអ្នកទទួលអាជ្ញាប័ណ្ណ មានភាពចាំបាច់ តែក្នុងករណីម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមិនបានចុះហត្ថលេខាលើសំណើ។ ក្នុងករណីនេះ តាមជម្រើសរបស់ភាគីស្នើសុំ សំណើត្រូវភ្ជាប់មកជាមួយនូវចំណុចណាមួយដូចខាងក្រោម: (i) សម្រង់កិច្ចសន្យាអាជ្ញាប័ណ្ណដែលបង្ហាញពីភាគីទាំងឡាយ និងសិទ្ធិទទួលអាជ្ញាប័ណ្ណ ដែលសម្រង់នេះអាចតម្រូវឱ្យមានការបញ្ជាក់ពីសារការីឬពីអាជ្ញាធរសាធារណៈមានសមត្ថកិច្ចផ្សេងទៀតណាមួយ ថាជាសម្រង់ពិតប្រាកដពីកិច្ចសន្យា (ii) សេចក្តីថ្លែងការណ៍អាជ្ញាប័ណ្ណដែលមិនបានបញ្ជាក់ ដែលធ្វើឡើងក្នុងទម្រង់ និងមានមាតិកាដូចកំណត់ក្នុងសេចក្តីថ្លែងការណ៍ ទម្រង់អាជ្ញាប័ណ្ណដែលមានក្នុងឧបសម្ព័ន្ធនេះ ហើយត្រូវបានចុះហត្ថលេខាដោយម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬតំណាងរបស់ខ្លួន និងអ្នកទទួលអាជ្ញាប័ណ្ណឬតំណាងរបស់ខ្លួន។

**១៤. ក្រដាសបន្ថែម**

☐ ពិនិត្យប្រអប់នេះ ប្រសិនបើ ត្រូវភ្ជាប់ក្រដាសបន្ថែម និងត្រូវបញ្ជាក់ពីចំនួនក្រដាសសរុបទាំងនេះ:

## ទម្រង់គំរូអន្តរជាតិ លេខ.២

## សេចក្តីថ្លែងការណ៍ពីអាជ្ញាប័ណ្ណ

ចំពោះពាក្យស្នើសុំចុះបញ្ជី និង/ឬ ម៉ាកដែលបានចុះបញ្ជី
ដែលបានដាក់ជូនការិយាល័យនៃ.........

| |
|---|
| សម្រាប់ការិយាល័យប្រើប្រាស់តែប៉ុណ្ណោះ |

| |
|---|
| ការចង្អុលបង្ហាញយោងនៃម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនិង/ឬអ្នកទទួលអាជ្ញាប័ណ្ណ:[1] ........................ |
| ការចង្អុលបង្ហាញយោងនៃតំណាងម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី: ........................ |
| អាជ្ញាប័ណ្ណ:[1] ........................ |

---

**១. សេចក្តីថ្លែងការណ៍**

ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី និងអ្នកទទួលអាជ្ញាប័ណ្ណ បញ្ជាក់ថា ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជី ដែលបានកំណត់អត្តសញ្ញាណខាងក្រោម ជា កម្មវត្ថុនៃអាជ្ញាប័ណ្ណ

---

---

**២. ការចុះបញ្ជី និង/ឬ ពាក្យស្នើសុំចុះបញ្ជីដែលពាក់ព័ន្ធ**

សេចក្តីថ្លែងការណ៍នេះពាក់ព័ន្ធនឹងការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជី ដែលដូចខាងក្រោម:

២.១ លេខចុះបញ្ជីនិង/ឬលេខពាក្យស្នើសុំចុះបញ្ជី:

---

[1] ការចង្អុលបង្ហាញយោងណាមួយ ដែលផ្តល់ដោយម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនិង/ឬ អ្នកទទួលអាជ្ញាប័ណ្ណនិង/ឬ ការចង្អុលបង្ហាញយោងណាមួយ ដែលផ្តល់ដោយតំណាងណាមួយ ទៅ សំណើនេះអាចត្រូវផ្តល់ឱ្យក្នុងចន្លោះចំហនេះ។

២.២ ☐ ប្រសិនបើចន្លោះចំហាក្រោមចំនុច ២.១ មិនគ្រប់គ្រាន់ ពិនិត្យប្រអប់នេះ ហើយផ្តល់ព័ត៌មានក្នុងក្រដាសបន្ថែម។

---

## ៣. ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី

៣.១ ប្រសិនបើម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីជារូបវន្តបុគ្គល

(ក) គោត្តនាម ឬឈ្មោះពិតប្រាកដនៃរូបវន្តបុគ្គល:[2]

(ខ) ឈ្មោះក្រៅ ឬឈ្មោះទីពីរនៃរូបវន្តបុគ្គល:[2]

៣.២ ប្រសិនបើ ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ជានីតិបុគ្គល

(ក) ឈ្មោះផ្លូវការពេញរបស់នីតិបុគ្គល:

(ខ) លក្ខណៈផ្លូវច្បាប់នៃនីតិបុគ្គល:

(គ) រដ្ឋ ហើយ នៅពេលដែលអនុវត្តបាន តំបន់ដែនដីក្នុងរដ្ឋនោះ តាមច្បាប់ដែលបង្កើតនីតិបុគ្គល:

៣.៣ អាសយដ្ឋាន (រួមទាំង លេខកូដប្រៃសណីនិងលេខកូដប្រទេស):

លេខទូរស័ព្ទ:[3] លេខទូរសារ:[3]

៣.៤ ☐ ពិនិត្យប្រអប់នេះ ប្រសិនបើ មានម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី លើសពីម្នាក់ ក្នុងករណីនេះ រាយនាមម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី នៅលើក្រដាសដោយឡែកហើយបង្ហាញទិន្នន័យដូចមានចែងក្នុងចំនុច៣.១ឬ៣.២និង៣.៣ ចំពោះបុគ្គលនីមួយៗ។

## ៤. តំណាងម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី

៤.១ ឈ្មោះ:

---

[2] ឈ្មោះទាំងឡាយ ដែលត្រូវបង្ហាញតាមចំនុច(ក)និង(ខ) ជាឈ្មោះ ដែលមានក្នុងកំណត់ត្រារបស់ ការិយាល័យចំពោះម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនៃការចុះបញ្ជី/ពាក្យស្នើសុំចុះបញ្ជីដែលទាកទងនឹងសំណើនេះ។

[3] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬតំណាងរបស់ខ្លួនមានជម្រើសមិនផ្តល់ការចង្អុលបង្ហាញនេះ។ នៅពេលផ្តល់ការចង្អុលបង្ហាញនេះ គួរត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

៤.២ អាសយដ្ឋាន (រួមទាំងលេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស):

លេខទូរស័ព្ទ:[4] លេខទូរសារ:[4]

៤.៣ លេខចុះបញ្ជី ប្រសិនបើចុះបញ្ជីនៅការិយាល័យ:

៤.៤ លេខ លិខិតពឹងពាក់មេធាវី:

---

## ៥. អ្នកទទួលអាជ្ញាប័ណ្ណ

៥.១ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណជារូបវន្តបុគ្គល

(ក) គោត្តនាម ឬឈ្មោះពិតប្រាកដនៃរូបវន្តបុគ្គល:

(ខ) ឈ្មោះក្រៅ ឬឈ្មោះទីពីរនៃរូបវន្តបុគ្គល:

៥.២ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណជានីតិបុគ្គល

(ក) ឈ្មោះផ្លូវការពេញរបស់នីតិបុគ្គល:

(ខ) លក្ខណៈផ្លូវច្បាប់នៃនីតិបុគ្គល:

(គ) រដ្ឋ ហើយ នៅពេលដែលអនុវត្តបាន តំបន់ដែនដីក្នុងរដ្ឋនោះ តាមច្បាប់ដែលបង្កើតនីតិបុគ្គល:

៥.៣ អាសយដ្ឋាន (រួមទាំងលេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស):

លេខទូរស័ព្ទ:[5] លេខទូរសារ:[5]

៥.៤ រដ្ឋ ដែលអ្នកទទួលអាជ្ញាប័ណ្ណមានសញ្ជាតិ:

៥.៥ រដ្ឋ ដែលអ្នកទទួលអាជ្ញាប័ណ្ណមានលំនៅឋាន:

---

[4] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬតំណាងរបស់ខ្លួន មានជម្រើសមិនផ្ដល់ការចង្អុលបង្ហាញនេះ។ នៅពេលផ្ដល់ការចង្អុលបង្ហាញនេះ គួរត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

[5] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ អ្នកទទួលអាជ្ញាប័ណ្ណ/តំណាងរបស់ខ្លួន មានជម្រើសមិនផ្ដល់ការចង្អុលបង្ហាញនេះ។ នៅពេលផ្ដល់ការចង្អុលបង្ហាញនេះ គួរត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

៥.៦ រដ្ឋ ដែលអ្នកទទួលអាជ្ញាប័ណ្ណមានសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការ:

៥.៧ ☐ ពិនិត្យប្រអប់នេះ ប្រសិនបើមានអ្នកទទួលអាជ្ញាប័ណ្ណលើសពីម្នាក់។ ក្នុងករណីនេះ រាយនាមអ្នកទទួលអាជ្ញាប័ណ្ណបន្ថែមនីមួយៗលើក្រដាសដោយឡែក ហើយបង្ហាញទិន្នន័យ ដូចមានចែងក្នុងចំនុច៥.១ដល់៥.៦ ចំពោះអ្នកទទួលអាជ្ញាប័ណ្ណនីមួយៗ។

---

## ៦. តំណាងរបស់អ្នកទទួលអាជ្ញាប័ណ្ណ

៦.១ ឈ្មោះ:

៦.២ អាសយដ្ឋាន (រួមទាំងលេខកូដប្រៃសណីយ៍ និងលេខកូដប្រទេស)

លេខទូរស័ព្ទ:[6] លេខទូរសារ:[6]

៦.៣ លេខចុះបញ្ជី ប្រសិនបើចុះបញ្ជីនៅការិយាល័យ:

៦.៤ លេខ លិខិតពឹងពាក់មេធាវី:[7]

## ៧. ទំនិញ និង/ឬសេវាដែលត្រូវផ្តល់អាជ្ញាប័ណ្ណ[8]

៧.១ ☐ អាជ្ញាប័ណ្ណ ត្រូវបានផ្តល់ឱ្យសម្រាប់ទំនិញនិង/ឬសេវាទាំងឡាយ ដែលមាន ក្នុងការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជី ដូចមានក្នុងចំនុច២។

៧.២ ☐ ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីតែមួយ ត្រូវចែងក្នុងចំនុច២ ហើយអាជ្ញាប័ណ្ណត្រូវបានផ្តល់ឱ្យតែសម្រាប់ទំនិញនិង/សេវាមួយចំនួន ដែលមានក្នុងការចុះបញ្ជី ឬពាក្យស្នើសុំចុះបញ្ជី។ ទំនិញនិង/ឬសេវាខាងក្រោម ត្រូវគ្របដណ្តប់ដោយអាជ្ញាប័ណ្ណ:

---

[6] ទោះបីជាការិយាល័យស្នើសុំព័ត៌មាននេះក៏ដោយ អ្នកទទួលអាជ្ញាប័ណ្ណ/តំណាងរបស់ខ្លួន មានជម្រើសមិន ផ្តល់ការចង្អុលបង្ហាញនេះ។ នៅពេលផ្តល់ការចង្អុលបង្ហាញនេះ គួរត្រូវបញ្ចូលលេខកូដប្រទេស (នៅពេលដែលសមស្រប) និងលេខកូដតំបន់។

[7] ទុកចំហ ប្រសិនបើមិនទាន់ផ្តល់លេខឱ្យលិខិតពឹងពាក់មេធាវី ឬប្រសិនបើ អ្នកទទួលអាជ្ញាប័ណ្ណ ឬតំណាងរបស់ខ្លួនមិនបានដឹងពីលេខនេះ។

[8] ពិនិត្យប្រអប់ដែលពាក់ព័ន្ធ។

៧.៣ ☐ ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីលើសពីមួយ ត្រូវចែងក្នុងចំនុច២ និងចំពោះយ៉ាងហោចណាស់ការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជីមួយ អាជ្ញាប័ណ្ណពាក់ព័ន្ធតិចជាងទំនិញនិង/ឬសេវាទាំងអស់ ដែលមានបញ្ជី។ ក្នុងករណីនេះ បង្ហាញលើក្រដាសបន្ថែមមួយទៀត ដោយឡែកៗចំពោះការចុះបញ្ជីនិង/ឬពាក្យស្នើសុំចុះបញ្ជី នីមួយៗទោះបីបើអាជ្ញាប័ណ្ណនេះគ្របដណ្តប់លើទំនិញនិង/ឬសេវាទាំងអស់ ឬ តែលើទំនិញនិង/ឬសេវាមួយចំនួនតែប៉ុណ្ណោះ។

---

**៨. ប្រភេទអាជ្ញាប័ណ្ណ**[8]

៨.១ ☐ អាជ្ញាប័ណ្ណជាអាជ្ញាប័ណ្ណផ្តាច់មុខ។

៨.២ ☐ អាជ្ញាប័ណ្ណជាអាជ្ញាប័ណ្ណតែមួយ។

៨.៣ ☐ អាជ្ញាប័ណ្ណជាអាជ្ញាប័ណ្ណមិនផ្តាច់មុខ។

៨.៤ ☐ អាជ្ញាប័ណ្ណពាក់ព័ន្ធតែផ្នែកដូចខាងក្រោមនៃដែនដី ដែលគ្របដណ្តប់ដោយការចុះបញ្ជី:

---

**៩. រយៈពេលអាជ្ញាប័ណ្ណ**

៩.១ ☐ អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យក្នុងរយៈពេលកំណត់ចាប់ ពី……………………………ដល់…………………………

៩.១.១ ☐ អាជ្ញាប័ណ្ណជាកម្មវត្ថុនៃការពន្យារដោយស្វ័យប្រវត្តិ

៩.២ ☐ អាជ្ញាប័ណ្ណត្រូវបានផ្តល់ឱ្យក្នុងរយៈពេលមិនកំណត់។

---

**១០. ហត្ថលេខា ឬត្រា**[9]

១០.១ ហត្ថលេខា ឬត្រារបស់ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី:

---

[9] ប្រសិនបើ មានបុគ្គលលើសពីម្នាក់ ដែលចុះហត្ថលេខាឬបោះត្រា ការចង្អុលបង្ហាញទាំងអស់តាមអនុចំនុច១២.១ ដល់១២.៤ គួរត្រូវធ្វើលើក្រដាសបន្ថែម។

១០.១.១ ឈ្មោះម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬប្រសិនបើ ម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ជានីតិបុគ្គល គឺឈ្មោះបុគ្គលដែលធ្វើសកម្មភាពក្នុងនាមម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី:

១០.១.២ កាលបរិច្ឆេទនៃការចុះហត្ថលេខាឬបោះត្រា:

១០.១.៣ ហត្ថលេខា ឬត្រា:

១០.២ ហត្ថលេខា ឬត្រារបស់អ្នកទទួលអាជ្ញាប័ណ្ណ:

១០.២.១ ឈ្មោះអ្នកទទួលអាជ្ញាប័ណ្ណ ឬប្រសិនបើ អ្នកទទួលអាជ្ញាប័ណ្ណជានីតិបុគ្គល គឺឈ្មោះបុគ្គល ដែលធ្វើសកម្មភាពក្នុងនាមអ្នកទទួលអាជ្ញាប័ណ្ណ:

១០.២.២ កាលបរិច្ឆេទនៃការចុះហត្ថលេខា ឬបោះត្រា:

១០.២.៣ ហត្ថលេខា ឬត្រា:

---

១០.៣ ហត្ថលេខា ឬត្រារបស់តំណាងម្ចាស់/អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី:

១០.៣.១ ឈ្មោះរូបវន្តបុគ្គល ដែលចុះហត្ថលេខា ឬបោះត្រា:

១០.៣.២ កាលបរិច្ឆេទនៃការចុះហត្ថលេខា ឬបោះត្រា:

១០.៣.៣ ហត្ថលេខា ឬត្រា:

១០.៤ ហត្ថលេខា ឬត្រារបស់តំណាងអ្នកទទួលអាជ្ញាប័ណ្ណ:

១០.៤.១ ឈ្មោះរូបវន្តបុគ្គល ដែលចុះហត្ថលេខា ឬបោះត្រា:

១០.៤.២ កាលបរិច្ឆេទនៃការចុះហត្ថលេខា ឬបោះត្រា:

១០.៤.៣ ហត្ថលេខា ឬត្រា:

---

**១១. ក្រដាសបន្ថែម**

☐ ពិនិត្យប្រអប់នេះ ប្រសិនបើ ត្រូវភ្ជាប់ ក្រដាសបន្ថែម ហើយបញ្ជាក់ពីចំនួនសរុបនៃក្រដាសនេះ:

---

# កំណត់ពន្យល់*
# ដែលរៀបចំឡើងដោយការិយាល័យអន្តរជាតិ

*

* កំណត់ពន្យល់ទាំងនេះ ត្រូវបានរៀបចំឡើងដោយការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) សម្រាប់គោលបំណងពន្យល់តែប៉ុណ្ណោះ។

## **កំណត់ចំពោះមាត្រា១**

១.០១ *ចំនុច (i) ដល់ (xi)* ហាក់ដូចជាមានលក្ខណៈពន្យល់ដោយខ្លួនឯង។ *ចំនុច (i) ដល់ (iii) និង(vi)* ទាក់ទងនឹពាក្យបំព្រួញដែលត្រូវបានប្រើប្រាស់ក្នុងអនុសញ្ញាស្តីពីច្បាប់ម៉ាក(TLT)។

១.០២ ពាក្យនានាដែលឱ្យនិយមន័យក្នុងចំនុច(ix)ដល់(xi) ត្រូវបានប្រើប្រាស់ក្នុងមាត្រា២(១)(xi) និងក្នុងផ្នែក១០ នៃទម្រង់គំរូអន្តរជាតិលេខ.១ និងផ្នែក៨នៃទម្រង់គំរូអន្តរជាតិលេខ.២ ដែលមានក្នុងឧបសម្ព័ន្ធ។

## **កំណត់ចំពោះមាត្រា២**

២.០១ មាត្រានេះថែង អំពីបញ្ជីអតិបរមានៃការចង្អុលបង្ហាញនិងធាតុទាំងឡាយ ដែលរដ្ឋជាសមាជិកអាចតម្រូវចំពោះសំណើចុះបញ្ជីអាជ្ញាប័ណ្ណ។ បន្ថែមលើការតម្រូវឱ្យភាគីស្នើសុំផ្តល់ការចង្អុលបង្ហាញនិងធាតុទាំងនេះ ត្រូវយល់ថា រដ្ឋជាសមាជិកអាចតម្រូវឱ្យសំណើបំពេញតាមការត្រួតពិនិត្យលក្ខខណ្ឌទម្រង់ ហើយ ប្រសិនបើការិយាល័យគិតថា ការចង្អុលបង្ហាញ ឬធាតុណាមួយមិនបំពេញតាមការត្រួតពិនិត្យនេះ ត្រូវទាក់ទងភាគីស្នើសុំឱ្យធ្វើការបញ្ជាក់ និង/ឬធ្វើវិសោធនកម្ម។

២.០២ *កថាខណ្ឌ(១)។* បទប្បញ្ញត្តិនេះកំណត់ពីធាតុ ដែលការិយាល័យអាចតម្រូវឱ្យបង្ហាញក្នុងសំណើចុះបញ្ជីអាជ្ញាប័ណ្ណចំពោះការប្រើប្រាស់ម៉ាក។ បញ្ជីធាតុទាំងនេះ មានលក្ខណៈអតិបរមា ការិយាល័យមានសេរីភាពក្នុងការតម្រូវតែធាតុមួយចំនួនក្នុងចំណោមធាតុទាំងនេះ ប៉ុន្តែមិនអាចតម្រូវឱ្យមានលក្ខខណ្ឌផ្សេងទៀងឬបន្ថែមឡើយ(សូមមើលកថាខណ្ឌ(៧))។

២.០៣ *ចំនុច (i) ដល់ (vi)។* ដរាបណាមានការទាក់ទងនឹងការបង្ហាញឈ្មោះនិងអាសយដ្ឋាន វិធាន២ *(លក្ខណៈនៃការបង្ហាញឈ្មោះនិងអាសយដ្ឋាន)* នៃTLT អាចអនុវត្ត។

២.០៤ *ចំនុច (ii) (iii) (v) និង(vi) ។* មាត្រា ៤(២) នៃ TLT អាចត្រូវ អនុវត្តចំពោះចំនុចទាំងនេះ ពីព្រោះការចុះបញ្ជីអាជ្ញាប័ណ្ណ ជា"នីតិវិធីចំពោះមុខការិយាល័យ"។ ដូច្នេះតាមមាត្រានេះ អាចតម្រូវឱ្យមានតំណាង ឬអាសយដ្ឋានសម្រាប់សេវា។

២.០៥ *ចំនុច (v) និង (vi)* ពិចារណាលើ មាត្រា២(២) ដែលអនុញ្ញាតឱ្យអ្នកទទួលអាជ្ញាប័ណ្ណដាក់សំណើចុះបញ្ជីអាជ្ញាប័ណ្ណដោយឯករាជ្យពីម្ចាស់ ហើយយោងលើមាត្រា៤(២)នៃTLT រដ្ឋជាសមាជិកអាចតម្រូវឱ្យបុគ្គលទាំងឡាយណា ដែលគ្មានលំនៅឋានឬគ្មានសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការលើដែនដីរបស់ខ្លួន ត្រូវតំណាងដោយអ្នកតំណាងឬបង្ហាញអាសយដ្ឋានសម្រាប់សេវា។ ដូច្នេះ រដ្ឋជាសមាជិកក៏អាចតម្រូវផងដែរឱ្យសំណើមានព័ត៌មានទាក់ទងនឹងតំណាងអ្នកទទួលអាជ្ញាប័ណ្ណឬអាសយដ្ឋានសម្រាប់សេវា។

២.០៦ *ចំនុច (vii)* អនុញ្ញាតបើចាំបាច់ឱ្យរដ្ឋជាសមាជិកកំណត់ ថាតើត្រូវផ្តល់បដិការ ចំពោះពលរដ្ឋក្នុងប្រទេសដែលអ្នកទទួលអាជ្ញាប័ណ្ណជាពលរដ្ឋរបស់ខ្លួនដែរឬទេ។ ដោយសារ មាត្រា៣នៃអនុសញ្ញាទីក្រុងប៉ារីសសម្រាប់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ចែងថា ពលរដ្ឋប្រទេសទាំងឡាយ ដែលមិនមែនជាសមាជិកសហភាពទីក្រុងប៉ារីស ត្រូវមានសិទ្ធិទទួលបានប្រព្រឹត្តិកម្មជាតិ ប្រសិនបើ ពលរដ្ឋទាំងនេះ មានសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មពិតប្រាកដនិងកំពុងដំណើរការឬ មានលំនៅឋានក្នុងប្រទេសណាមួយនៃប្រទេសសហភាពទីក្រុងប៉ារីស ចំណុចនេះអនុញ្ញាតឱ្យទាមទារការចង្អុលបង្ហាញទាំងនេះ។

២.០៧ *ចំណុច (viii)* អនុញ្ញាតឱ្យរដ្ឋជាសមាជិកតម្រូវឱ្យបញ្ជាក់ពីលក្ខណៈផ្លូវច្បាប់នៃអង្គភាព នៅពេលដែល ម្ចាស់ អ្នកទទួលអាជ្ញាប័ណ្ណ ឬភាគីទាំងពីរជានីតិបុគ្គល។ បទបញ្ញត្តិនេះដូចគ្នានឹងមាត្រា៣(១)(ក)(iv)នៃ TLT ដែលអនុញ្ញាតឱ្យមានលក្ខខណ្ឌប្រហាក់ប្រហែលគ្នាទាក់ទងនឹងពាក្យស្នើសុំចុះបញ្ជីម៉ាក។

២.០៨ *កថាខណ្ឌ(១)ចំណុច(ix)និង(x)។* ចំណុចទាំងនេះហាក់ដូចជាពន្យល់ដោយខ្លួនឯង។

២.០៩ *ចំណុច (xi)។* និយមន័យ "អាជ្ញាប័ណ្ណផ្តាច់មុខ" "អាជ្ញាប័ណ្ណមិនផ្តាច់មុខ" និង "អាជ្ញាប័ណ្ណតែមួយ" មានក្នុងមាត្រា១(ix)ដល់(xi)។ គួរកត់សម្គាល់ថា ដូចបានបង្ហាញដោយពាក្យ "នៅពេលអនុវត្តបាន" ប្រសិនបើច្បាប់រដ្ឋជាសមាជិកមួយ មិនចែងអំពីការចង្អុលបង្ហាញណាមួយទេ មិនគួរផ្តល់ព័ត៌មានទាក់ទងនឹងចំណុចក្រោមការពិចារណានេះឡើយ។

២.១០ *ចំណុច (xii)* អនុញ្ញាតឱ្យរដ្ឋជាសមាជិកមួយ តម្រូវឱ្យមានការចង្អុលបង្ហាញថា អាជ្ញាប័ណ្ណពាក់ព័ន្ធតែផ្នែកមួយនៃដែនដី ដែលការចុះបញ្ជីមានអានុភាព ហើយត្រូវមាន ការចង្អុលបង្ហាញជាក់លាក់នៃដែនដីនេះ។

២.១១ *ចំណុច (xiii)។* រដ្ឋជាសមាជិកអាចតម្រូវឱ្យសំណើបង្ហាញពីរយៈពេលដែលផ្តល់អាជ្ញាប័ណ្ណ ឬថាអាជ្ញាប័ណ្ណត្រូវបានផ្តល់ក្នុងរយៈពេលមិនកំណត់។ ប្រសិនបើការផ្តល់អាជ្ញាប័ណ្ណមានរយៈកំណត់ ប៉ុន្តែត្រូវបានបន្តជាថ្មី ឬពន្យារដោយស្វ័យប្រវត្តិ អាជ្ញាប័ណ្ណនេះអាចត្រូវបានចាត់ទុកថា ត្រូវបានផ្តល់ឱ្យក្នុងរយៈពេលកំណត់មួយ។អាចជាទំនួលខុសត្រូវរបស់ភាគីទាំងឡាយដើម្បីជូនដំណឹងដល់ការិយាល័យពីការបន្តជាថ្មីឬពន្យារអាជ្ញាប័ណ្ណ។

២.១២ *ចំណុច (xiv)* អនុញ្ញាតឱ្យរដ្ឋជាសមាជិកទាមទារឱ្យមានហត្ថលេខា ដែលអាចជាហត្ថលេខា ម្ចាស់ឬអ្នកតំណាងរបស់ខ្លួន ឬតាមលក្ខខណ្ឌមួយចំនួនដែលកំណត់ក្នុងកថាខណ្ឌ (២)(ខ) ទាមទារឱ្យមានហត្ថលេខាអ្នកទទួលអាជ្ញាប័ណ្ណ ឬតំណាងរបស់ខ្លួន។

២.១៣ *កថាខណ្ឌ (២)។* សំណើចុះបញ្ជីអាជ្ញាប័ណ្ណមានលក្ខណៈខុសគ្នាពីសំណើកត់ត្រាការផ្លាស់ប្តូរកម្មសិទ្ធិនៃការចុះបញ្ជីម៉ាកដូចមានចែងក្នុងមាត្រា១១(១)(ឃ)នៃTLT។ ជាឧទាហរណ៍ ប្រទេសមួយចំនួន តម្រូវឱ្យសហកម្មសិទ្ធិករទាំងអស់ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ រីឯ ប្រទេសមួយចំនួនផ្សេងអនុញ្ញាតឱ្យតែសហកម្មសិទ្ធិករមួយចំនួន ចុះហត្ថលេខាផ្តល់អាជ្ញាប័ណ្ណម៉ាកដែលបានចុះបញ្ជី។ ដូច្នេះ មិនដូចបទប្បញ្ញត្តិនៃTLTទេ សំនួរសួរ ថាតើសហកម្មសិទ្ធិករទាំងអស់ ត្រូវផ្តល់ការយល់ព្រមរបស់ខ្លួនចំពោះការចុះបញ្ជីអាជ្ញាប័ណ្ណដែរឬទេ ជាបញ្ហានៃច្បាប់ក្នុងរដ្ឋជាសមាជិក។ ដោយឡែក សំនួរសួរថាតើហត្ថលេខាសហកម្មសិទ្ធិករណាមួយបំពេញលក្ខខណ្ឌដែលសំណើត្រូវចុះហត្ថលេខាដោយ "ម្ចាស់" ឬ ប្រសិនបើតម្រូវហត្ថលេខាសហកម្មសិទ្ធិករទាំងអស់សម្រាប់បំពេញលក្ខខណ្ឌ គឺអាស្រ័យលើច្បាប់ដែលអនុវត្ត។ ក្នុងករណីណាក៏ដោយ ប្រសិនបើ សហកម្មសិទ្ធិករ ណាមួយបដិសេធមិនចុះហត្ថលេខា តាមច្បាប់ដែលអនុវត្ត សំណើនេះមិនអាចទទួលយកបានទេ អ្នកទទួលអាជ្ញាប័ណ្ណអាចស្នើចុះបញ្ជីតាមកថាខណ្ឌ (២)។

២.១៤ *កថាខណ្ឌ(២)(ក)។* ដើម្បីសម្រួលដល់ លក្ខខណ្ឌទម្រង់នៃការចុះបញ្ជីអាជ្ញាប័ណ្ណ រដ្ឋជាសមាជិកទាំងឡាយ អាចតម្រូវឱ្យតែម្ចាស់ឬតំណាងរបស់ខ្លួនចុះហត្ថលេខាលើសំណើប៉ុណ្ណោះ ប្រសិនបើម្ចាស់ដាក់សំណើដោយខ្លួនឯង។ ហត្ថលេខាម្ចាស់គឺគ្រប់គ្រាន់ដើម្បីធានាថា ខ្លួនពិតជាបានយល់ព្រមចំពោះការចុះបញ្ជីនេះមែន។ ត្រូវយកចិត្តទុកដាក់ចំពោះកាតព្វកិច្ចអនុវត្តមាត្រា៨(៤) នៃTLT ដែលហាមឃាត់ការបញ្ជាក់ ការបញ្ជាក់ពីសាការី យថាភាពនីត្យានុគោលកម្ម ឬការបញ្ជាក់ ផ្សេងទៀតនៃហត្ថលេខាឬត្រាណាមួយ។

២.១៥ *កថាខណ្ឌ (២)(ខ)។* បទប្បញ្ញត្តិនេះអនុញ្ញាតឱ្យអ្នកទទួលអាជ្ញាប័ណ្ណដាក់សំណើចុះបញ្ជី ដោយឯករាជ្យពីម្ចាស់ ប្រសិនបើ ម្ចាស់ចង់គេចវេសមិនបង់កម្រៃចុះបញ្ជី ឬបន្ទាប់ពីបានចុះកិច្ចសន្យាអាជ្ញាប័ណ្ណ បដិសេធមិនចុះបញ្ជីអាជ្ញាប័ណ្ណដោយ ហេតុផលណាក៏ដោយ។ ឯកសារទាំងឡាយដែលរាយមានក្នុងកថាខណ្ឌនេះ អាចជំនួសហត្ថលេខាម្ចាស់ ប្រសិនបើមានសំណើ។ ភាគីស្នើសុំ អាចដាក់ឯកសារណាមួយក៏បាន។ បញ្ជីនេះយកតាម បញ្ជីដែលមានក្នុងមាត្រា១១(១)(ខ)នៃTLT ដែលទាក់ទងនឹងលក្ខខណ្ឌទម្រង់សម្រាប់កត់ត្រាការផ្លាស់ប្តូរកម្មសិទ្ធិតាមកិច្ចសន្យា ដោយពិចារណាលើលភាពខុសគ្នាផ្នែកគុណភាព រវាងការផ្ទេរកម្មសិទ្ធិទាំងស្រុងនិងការផ្តល់អាជ្ញាប័ណ្ណសិទ្ធិតែប៉ុណ្ណោះ។ ដោយសារ អនុកថាខណ្ឌ(ខ) រៀបរាប់តែពីស្ថានភាពទាំងឡាយ ដែលតម្រូវឱ្យការិយាល័យ ទទួលយកសំណើ ដែលបានចុះហត្ថលេខាដោយអ្នកទទួលអាជ្ញាប័ណ្ណឬតំណាងរបស់ខ្លួន ការិយាល័យមានសេរីភាពទទួលយកសំណើនេះ ទោះបីជា សម្រង់ដែលមានចែងក្នុងចំណុច(i) មិនត្រូវបានបញ្ជាក់ក៏ដោយ ឬប្រសិនបើសំណើ មិនភ្ជាប់មកជាមួយនូវឯកសារណាមួយក៏ដោយ។ ប៉ុន្តែ ចំពោះចំណុច(ii) សេចក្តីថ្លែងការណ៍នៃអាជ្ញាប័ណ្ណ ត្រូវចុះហត្ថលេខាដោយម្ចាស់និងអ្នកទទួលអាជ្ញាប័ណ្ណ ឬតំណាងរបស់អ្នកទាំងពីរ។ សេចក្តីថ្លែងការណ៍នៃទម្រង់អាជ្ញាប័ណ្ណ មានក្នុងឧបសម្ព័ន្ធ។

២.១៦ *កថាខណ្ឌ(៣)។* បទប្បញ្ញត្តិនេះខុសពីបទប្បញ្ញត្តិនានា ក្នុងTLT ដែលទាក់ទង នឹងការបង្ហាញសំណើ (ដូចជា មាត្រា ១១(១)(ក)នៃTLT) ដោយសារបទប្បញ្ញត្តិនេះមិនកំណត់ជាក់លាក់ពីមធ្យោបាយបញ្ជូន ដូចជា ក្រដាស ឬទូរសារ ប៉ុន្តែផ្តោតលើខ្លឹមសារ នៃសំណើជំនួសវិញ។ អនុភាពនៃកថាខណ្ឌ(៣)គឺថា ការិយាល័យនៃរដ្ឋជាសមាជិកមួយ ត្រូវទទួលយកសំណើ

ចុះបញ្ជីអាជ្ញាប័ណ្ណ នៅពេលដែលសំណើ (i) មានការចង្អុលបង្ហាញឬធាតុទាំងអស់ដែលកំណត់ក្នុងទម្រង់សំណើដែលមានក្នុងឧបសម្ព័ន្ធ និង (ii) បង្ហាញនិងរៀបចំការចង្អុលបង្ហាញទាំងនេះក្នុងរបៀបដូចគ្នានឹងទម្រង់នេះ ។

២.១៧ *កថាខណ្ឌ (៤)។* អនុកថាខណ្ឌ (ក) អនុញ្ញាតឱ្យរដ្ឋជាសមាជិកទាំងឡាយ តម្រូវឱ្យសំណើត្រូវដាក់ជាភាសាទាំងឡាយឬជាភាសាណាមួយ ដែលការិយាល័យអនុញ្ញាត។ ប៉ុន្តែចំពោះឯកសារទាំងឡាយ ដែលរាយមានក្នុងកថាខណ្ឌ(២)(ខ)(i)ឬ(ii) រដ្ឋជាសមាជិកទាំងឡាយ អាចគ្រាន់តែតម្រូវឱ្យអមដោយការបកប្រែតែប៉ុណ្ណោះ។ ឯកសារទាំងនេះផ្ទាល់មិនអាចត្រូវបានតម្រូវឱ្យធ្វើជាភាសាណាមួយ ដែលការិយាល័យអនុញ្ញាតឡើយ។ រដ្ឋជាសមាជិកទាំងឡាយអាចឱ្យមានការបញ្ជាក់ការបកប្រែប៉ុន្តែមិនមែនជាកាតព្វកិច្ចទេ។

២.១៨ *កថាខណ្ឌ (៥)។* ទាក់ទងនឹងបរិមាណកម្រៃ ដែលការិយាល័យ អាចយកចេញពីការចុះបញ្ជីអាជ្ញាប័ណ្ណ គួរតែកត់សម្គាល់ថា អត្ថបទនេះមិនរារាំងការិយាល័យពីការយកកម្រៃផ្សេងៗទៀត អាស្រ័យលើចំនួននៃការចុះបញ្ជីដែលទាក់ទងនឹងសំណើ។

២.១៩ *កថាខណ្ឌ(៦)* ស្របនឹងគំនិត ដែលបានអនុម័តដោយ TLT ក្នុងមាត្រា១០(១)(ង) និង១១(១)(ជ) អនុញ្ញាតឱ្យសំណើចុះបញ្ជី អាចយោងទៅការចុះបញ្ជីច្រើនជាងមួយ។ នេះជាភាពសាមញ្ញយ៉ាងសំខាន់ ក្នុងករណី ដែលអាជ្ញាប័ណ្ណត្រូវផ្តល់ចំពោះម៉ាកច្រើន (ជាឧទាហរណ៍បណ្តុំនៃម៉ាក)។ ប៉ុន្តែ រឿងនេះត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោមៈការចុះបញ្ជីទាំងអស់ដែលគ្របដណ្តប់ដោយអាជ្ញាប័ណ្ណដែលស្នើសុំកត់ត្រា ត្រូវមានម្ចាស់និងអ្នកទទួលអាជ្ញាប័ណ្ណតែមួយ និង នៅពេលដែលអនុវត្តបាន ត្រូវបង្ហាញវិសាលភាពនៃអាជ្ញាប័ណ្ណដូចចែងក្នុងមាត្រា២(១) ចំពោះការចុះបញ្ជីទាំងអស់ដែលគ្របដណ្តប់ដោយអាជ្ញាប័ណ្ណដែលស្នើចុះបញ្ជី។ ក្នុងករណីមិនបានបំពេញលក្ខខណ្ឌទាំងនេះ ដូចជា ប្រសិនបើ ម្ចាស់និងអ្នកទទួលអាជ្ញាប័ណ្ណ មិនដូចគ្នាចំពោះការចុះបញ្ជីទាំងអស់ដែលមានក្នុងសំណើ ការិយាល័យអាចតម្រូវឱ្យដាក់សំណើដោយឡែក។ ដោយសារ កថាខណ្ឌ(៦) រៀបរាប់តែពីស្ថានភាព ដែលតម្រូវឱ្យការិយាល័យទទួលយកសំណើតែមួយសម្រាប់ការចុះបញ្ជីច្រើន ការិយាល័យ មាន

សេរីភាពក្នុងការទទួលយកសំណើតែមួយ ទោះបីជា មិនបានបំពេញលក្ខខណ្ឌទាំងឡាយ ក្នុងកថាខណ្ឌ (៦) ក៏ដោយ។

២.២០ *កថាខណ្ឌ (៧)។* សម្រាប់គោលបំណងចុះបញ្ជីអាជ្ញាប័ណ្ណនៅការិយាល័យរបស់ខ្លួន អានុភាពនៃកថាខណ្ឌនេះគឺថា រដ្ឋជាសមាជិកមួយមិនអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីផ្តល់ព័ត៌មានបន្ថែមទៅលើអ្វីដែលអាចតម្រូវតាមកថាខណ្ឌ(១) ឬតម្រូវឱ្យផ្តល់ឯកសារបន្ថែម ដូចជាភ័ស្តុតាងដែលបង្ហាញពីអត្ថិភាពនៃខត្រួតពិនិត្យគុណភាព (ចំពោះការត្រួតពិនិត្យគុណភាព សូមមើលកំណត់ ៥.០២ និង៥.០៣)។

២.២១ តាមរយៈឧទាហរណ៍ *ចំណុច(i)និង(ii)* លើកឡើងពីព័ត៌មានមួយចំនួនដែលផ្តល់ឱ្យការិយាល័យ ហើយ ជាធម្មតា ភាគីនៃកិច្ចសន្យាអាជ្ញាប័ណ្ណចាត់ទុកជាបន្ទុកបន្ថែមឬជាការបង្ហាញព័ត៌មានពាណិជ្ជកម្មសម្ងាត់(*ចំណុច(iii)*)។ ប៉ុន្តែ គួរកត់សម្គាល់ថា កថាខណ្ឌ (៧) អនុញ្ញាតឱ្យអាជ្ញាធរផ្សេងទៀតនៃរដ្ឋជាសមាជិក (ដូចជា អាជ្ញាធរពន្ធដារ ឬអាជ្ញាធររៀបចំសិត្តិ) តម្រូវឱ្យភាគី នៃកិច្ចសន្យាអាជ្ញាប័ណ្ណ ផ្តល់ព័ត៌មាន ស្របតាមច្បាប់ ដែលត្រូវអនុវត្ត។

២.២២ *កថាខណ្ឌ (៨)។* មាត្រា២ និងទម្រង់សំណើគំរូ ដែលមានក្នុងឧបសម្ព័ន្ធ អាចអនុវត្តបានចំពោះសំណើចុះបញ្ជីអាជ្ញាប័ណ្ណនៃពាក្យស្នើសុំចុះបញ្ជី ប្រសិនបើច្បាប់ជាតិ ឬច្បាប់តំបន់នៃរដ្ឋជាសមាជិកចែងពីការចុះបញ្ជីនេះ ។ គួរកត់សម្គាល់ថា ក្នុងបរិបទនេះ វិធាន៧នៃបទបញ្ជានៃTLT(*របៀបស្វែងរកពាក្យស្នើសុំចុះបញ្ជីដែលគ្មានលេខ* អាចអនុវត្តបាន។

## **កំណត់ចំពោះមាត្រា៣**

៣.០១ ពេលចុះបញ្ជីអាជ្ញាប័ណ្ណរួចហើយ ការចុះបញ្ជីនេះ នៅពេលណាមួយ អាចជាកម្មវត្ថុនៃសំណើធ្វើវិសោធនកម្ម ឬលុបចោល។ សម្រាប់ហេតុផលនេះ មាត្រា៣ ចែងថា មាត្រា២ និងទម្រង់សំណើគំរូ ដែលមានក្នុងឧបសម្ព័ន្ធ អាចអនុវត្តបានផងដែរចំពោះសំណើធ្វើវិសោធនកម្ម ឬលុបចោលការចុះបញ្ជីអាជ្ញាប័ណ្ណ។

## **កំណត់ចំពោះមាត្រា៤**

៤.០១ កថាខណ្ឌ(១)។ គោលបំណងនៃកថាខណ្ឌនេះ គឺដើម្បីញែកសំនួរនៃសុពលភាពការចុះ

បញ្ជីម៉ាកនិងកិច្ចការពារម៉ាក ពីសំនួរថាតើត្រូវកត់ត្រាអាជ្ញាប័ណ្ណទាក់ទងនឹងម៉ាកនេះ។ ប្រសិនបើច្បាប់នៃរដ្ឋជាសមាជិកចែងពីការចុះបញ្ជីអាជ្ញាប័ណ្ណដោយបង្ខំ ការមិនគោរពតាមលក្ខខណ្ឌនេះ អាចធ្វើឱ្យការចុះបញ្ជីម៉ាកដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណរងមោឃភាព ហើយមិនអាចប៉ះពាល់ដល់កិច្ចការពារនៃម៉ាកបានឡើយ។ ត្រូវកត់សម្គាល់ថា កថាខណ្ឌនេះពាក់ព័ន្ធការចុះបញ្ជីអាជ្ញាប័ណ្ណនៅឯការិយាល័យ ឬអាជ្ញាធរផ្សេងទៀតនៃរដ្ឋជាសមាជិក ដូចជា អាជ្ញាធរពន្ធដារ ឬអាជ្ញាធរដែលទទួលខុសត្រូវក្នុងការរៀបចំស្ថិតិ។

៤.០២ *កថាខណ្ឌ (២)(ក)។* បទប្បញ្ញត្តិនេះគ្មានបំណងធ្វើសុខដុមនីយកម្មសំនួរថាតើអ្នកទទួលអាជ្ញាប័ណ្ណ គួរត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងបណ្តឹងដែលផ្តួចផ្តើមឡើងដោយអ្នកផ្តល់អាជ្ញាប័ណ្ណ ឬថាតើគួរមានសិទ្ធិលើការខូចខាត ដែលបណ្តាលមកពីការរំលោភបំពានម៉ាកទទួលបានអាជ្ញាប័ណ្ណដែររឺទេ។ សំនួរនេះទុកឱ្យច្បាប់ដែលត្រូវអនុវត្តជាអ្នកដោះស្រាយ។ ប៉ុន្តែ នៅពេលដែល អ្នកទទួលអាជ្ញាប័ណ្ណមានសិទ្ធិតាមច្បាប់នៃរដ្ឋជាសមាជិកដើម្បីចូលរួមក្នុងបណ្តឹងពីការរំលោភបំពានដែលផ្តួចផ្តើមដោយម្ចាស់ និងទទួលបានសំណងខូចខាត ដែលបណ្តាលមកពីការរំលោភបំពានម៉ាកដែលផ្តល់អាជ្ញាប័ណ្ណ អ្នកទទួលអាជ្ញាប័ណ្ណ គួរអាចអនុវត្តសិទ្ធិទាំងនេះដោយឯករាជ្យទោះបីជាអាជ្ញាប័ណ្ណត្រូវបានចុះបញ្ជីឬមិនបានចុះបញ្ជីក៏ដោយ។

៤.០៣ បញ្ហាទាក់ទងនឹងសិទ្ធអ្នកទទួលអាជ្ញាប័ណ្ណក្នុងការចូលរួមក្នុងបណ្តឹងពីការរំលោភបំពានដែលផ្តួចផ្តើមដោយម្ចាស់និងដើម្បីទទួលបានការខូចខាត ខុសគ្នាពីបញ្ហាថាតើអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបានអនុញ្ញាតឱ្យធ្វើបណ្តឹងពីការរំលោភបំពាន ទាក់ទងនឹងម៉ាកដែលផ្តល់អាជ្ញាប័ណ្ណ ក្នុងនាមខ្លួនផ្ទាល់ឬទេ។ ករណីក្រោយនេះមិនត្រូវបានដោះស្រាយដោយមាត្រាទាំងឡាយនេះទេ។ ដូច្នេះ រដ្ឋជាសមាជិក អាចត្រូវបានអនុញ្ញាតឱ្យតម្រូវការចុះបញ្ជីអាជ្ញាប័ណ្ណជាលក្ខខណ្ឌមួយ សម្រាប់អ្នកទទួលអាជ្ញាប័ណ្ណដើម្បីប្តឹងដោយខ្លួនឯងផ្ទាល់ ទាក់ទងនឹងម៉ាកដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណ។ តាមកថាខណ្ឌ(២)(ក) រដ្ឋជាសមាជិកមានសេរីភាពចែងឱ្យអ្នកទទួលអាជ្ញាប័ណ្ណដែលគ្មានការចុះបញ្ជី មានសិទ្ធិទទួលបានការខូចខាត តែនៅពេលដែលខ្លួនបានចូលរួមក្នុងបណ្តឹងពីការរំលោភបំពានដែលផ្តួចផ្តើមដោយម្ចាស់។ ប៉ុន្តែ នេះជាស្តង់ដារអតិបរិមា ហើយ រដ្ឋជាសមាជិកមានសេរីភាពដូចគ្នា ដើម្បីអនុម័តវិធានការដែលមានលក្ខណៈ

សេរីជាងនេះ ដូចជា ច្បាប់ជាតិឬតំបន់ ដែលត្រូវអនុវត្ត មិនចែងឱ្យមានការចុះបញ្ជី អាជ្ញាប័ណ្ណតែម្តង។

៤.០៤ បញ្ហាថាតើអ្នកទទួលអាជ្ញាប័ណ្ណដែលមិនបានចុះបញ្ជី គួរមានសិទ្ធិចូលរួមក្នុងបណ្តឹងពីការរំលោភបំពាន ដែលផ្តួចផ្តើមឡើងដោយម្ចាស់ និងដើម្បីទទួលសំណង ជាកម្មវត្ថុនៃការពិភាក្សាយ៉ាងខ្លាំង ក្នុងអំឡុងពេលសម័យប្រជុំលើកទីមួយនៃ គណៈកម្មាធិការជំនាញស្តីពីអាជ្ញាប័ណ្ណម៉ាក (សូមមើលឯកសារTML/CE/I/3 កថាខណ្ឌ ៧០ ដល់ ៧៤) និងក្នុងអំឡុងពេលសម័យប្រជុំលើកទីបីនៃគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីច្បាប់ម៉ាក គំនូសឧស្សាហកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រទំនុញ(SCT) (សូមមើលឯកសារSCT/3/10 កថាខណ្ឌ១២២ ដល់ ១២៤)។ គណៈប្រតិភូ ដែលជំទាស់នឹងបទប្បញ្ញត្តិនេះ អះអាងថា តាមច្បាប់ប្រទេសរបស់ខ្លួន អាជ្ញាប័ណ្ណមានអានុភាពចំពោះតតិយជនតែប្រសិនបើ អាជ្ញាប័ណ្ណត្រូវបានចុះបញ្ជី។ គណៈប្រតិភូនិងតំណាងអង្គការជាអ្នកសង្កេតការណ៍ទាំងឡាយដែលបានសំដែងការគាំទ្ររបស់ខ្លួន ចំពោះបទប្បញ្ញត្តិនេះ បានបញ្ជាក់ថា ប្រសិន សិទ្ធិអ្នកទទួលអាជ្ញាប័ណ្ណ ឱ្យជួសជុលការខូចខាតក្នុងបណ្តឹងពីការរំលោភបំពាន ដែល ផ្តួចផ្តើមឡើងដោយម្ចាស់ អាស្រ័យលើការចុះបញ្ជីអាជ្ញាប័ណ្ណ នេះអាចផ្តល់ផលប្រយោជន៍អ្នករំលោភបំពានម៉ាកតែប៉ុណ្ណោះ ដោយសារពួកគេអាចមិនទទួលខុសត្រូវអ្វីទាំងអស់ នៅពេលដែលបុគ្គល ទទួលរងការខូចខាតពីការប្រើប្រាស់ម៉ាកគ្មានការអនុញ្ញាត ជាអ្នកទទួលអាជ្ញាប័ណ្ណ។ តាមទស្សនៈអ្នករំលោភបំពានម៉ាក មិនគួរធ្វើឱ្យខុសគ្នា ទោះបីម៉ាកដែលត្រូវបានការពារ ត្រូវបានប្រើប្រាស់តាមអាជ្ញាប័ណ្ណដែលបាន ចុះបញ្ជី រឺមិនបានចុះបញ្ជី ក៏ដោយ។ បញ្ហាក្នុងករណីនេះគឺថា ម៉ាកត្រូវបានការពារ ហើយនេះអាចត្រូវបានពិនិត្យដោយយោងទៅបញ្ជីម៉ាក។

៤.០៥ សំខាន់ត្រូវកត់សម្គាល់ថា ប្រសិនបើ រដ្ឋជាសមាជិក យល់ឃើញថា អាជ្ញាប័ណ្ណមានអានុភាពតាមផ្លូវច្បាប់ចំពោះតតិយជនតែនៅពេលដែលអាជ្ញាប័ណ្ណត្រូវបានចុះបញ្ជី បទប្បញ្ញត្តិនេះ មិនចាំបាច់ត្រូវបកស្រាយកតាមអត្ថន័យដែល អ្នកទទួលអាជ្ញាប័ណ្ណដែលមិនបានចុះបញ្ជី មិនមានសិទ្ធិឱ្យជួសជុលការខូចខាតពីការរំលោភបំពានម៉ាកដែលផ្តល់អាជ្ញាប័ណ្ណនៅឡើយ។ ប៉ុន្តែ បទប្បញ្ញត្តិនេះ អាចមានអនុភាពក្នុងករណីដែលផ្ទេរការចុះបញ្ជីបន្ទាប់ពីចុះ

អាជ្ញាប័ណ្ណ ដោយសារអ្នកទទួលអាជ្ញាប័ណ្ណដែលមិនបានចុះបញ្ជី មិនអាចប្រើអាជ្ញាប័ណ្ណប្រឆាំងនឹងអនុប្បទានិកបានទេ។ នេះមិនត្រូវបានហាមឃាត់ដោយកថាខណ្ឌ(២) ដែលពាក់ព័ន្ធតែស្ថានភាពជាក់លាក់មួយតែប៉ុណ្ណោះ ពោលគឺសិទ្ធិអ្នកទទួលអាជ្ញាប័ណ្ណដែលមិនបានចុះបញ្ជី ក្នុងការចូលរួមក្នុងបណ្ដឹងពីការរំលោភបំពាន ដែលផ្តួចផ្តើមឡើងដោយម្ចាស់ និងឱ្យជួសជុលការខូចខាត ដោយបណ្ដឹងនេះ។

៤.០៦ *កថាខណ្ឌ (២)(ខ)។* អនុកថាខណ្ឌ (ខ) ពិចារណាពីច្បាប់ដែលពាក់ព័ន្ធ ដែលហាមឃាត់ជាក់លាក់អ្នកទទួលអាជ្ញាប័ណ្ណដែលមិនបានចុះបញ្ជី ពីការចូលរួមក្នុងបណ្ដឹងរំលោភបំពានដែលផ្តួចផ្តើមឡើងដោយម្ចាស់ និងពីការសងការខូតខាត។ ដូច្នេះ ទោះបីជា បទប្បញ្ញត្តិក្នុងអនុកថាខណ្ឌ(ក) ត្រូវបានរក្សាជាគោលការណ៍ទូទៅក៏ដោយ ក៏អនុកថាខណ្ឌ(ខ) បញ្ជាក់ច្បាស់ថា ច្បាប់ទាំងនេះ មិនត្រូវប៉ះពាល់ទេ។ ប៉ុន្តែ ច្បាប់ទាំងឡាយ ដែលអាចត្រូវបានបកស្រាយជាការអនុញ្ញាតឱ្យអ្នកទទួលអាជ្ញាប័ណ្ណដែលមិនបានចុះបញ្ជីចូលរួមក្នុងបណ្ដឹងរំលោភបំពាននិងឱ្យជួសជុលការខូចខាត អាចស្ថិតក្រោមអនុកថាខណ្ឌ(ក) ហើយ ដូច្នេះ អាចត្រូវបានបកស្រាយបែបនេះ។

## កំណត់ចំពោះមាត្រា៥

៥.០១ បញ្ហាថាតើការប្រើប្រាស់ដោយបុគ្គលក្រៅពីម្ចាស់ អាចត្រូវបានចាត់ទុកជា ការប្រើប្រាស់ដោយម្ចាស់ អាចពាក់ព័ន្ធយ៉ាងហោចណាស់ក្នុងបរិបទបីផ្សេងគ្នា: (i) ដើម្បីកំណត់ថាតើម៉ាកមួយមានភាពញែកដាច់ពីគ្នា (ii) ដើម្បីកំណត់ថាតើម៉ាកមួយចាប់ល្បី (iii) ដើម្បីកំណត់ថាតើម៉ាកមួយត្រូវបានប្រើប្រាស់គ្រប់គ្រាន់សម្រាប់រក្សាការចុះបញ្ជីម៉ាក។ មាត្រា៥ពាក់ព័ន្ធតែនឹងស្ថានភាពដែលការប្រើប្រាស់ដោយបុគ្គលក្រៅពីម្ចាស់អាចបង្កើនផលប្រយោជន៍របស់ម្ចាស់។ មាត្រានេះមិនបានបញ្ជាក់អំពីកាលៈទេសៈណាដែលម្ចាស់អាចទទួលខុសត្រូវចំពោះការប្រើប្រាស់នេះ។

៥.០២ គួរកត់សម្គាល់ថា ជាស្តង់ដារដែលទទួលយកជាទូទៅក្នុងច្បាប់ម៉ាក ម៉ាកដែលបានចុះបញ្ជី ដែលមិនត្រូវបានប្រើប្រាស់ក្នុងរយៈពេលណាមួយ អាចត្រូវបានធ្វើមោឃភាព។ ជាឧទាហរណ៍ មាត្រា១៩.១នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(តទៅ

ហៅថា "កិច្ចព្រមព្រៀងTRIPS") អនុញ្ញាតឱ្យសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ធ្វើមោឃភាពម៉ាកដែលបានចុះបញ្ជីដែលមិនត្រូវបានប្រើប្រាស់លើសពី៣(បី)ឆ្នាំ។ ជាទូទៅ ម៉ាកមួយត្រូវប្រើប្រាស់ដោយម្ចាស់ម៉ាក ឬដោយបុគ្គលណាមួយ ដែលមានការអនុញ្ញាតពីម្ចាស់ ដើម្បីរក្សាការចុះបញ្ជីម៉ាក។ ប៉ុន្តែ ច្បាប់ជាតិឬតំបន់មួយចំនួន ចែងពីការ ប្រើប្រាស់ដោយបុគ្គលក្រៅពីម្ចាស់ អាចត្រូវចាត់ទុកថាជាការប្រើប្រាស់ម៉ាកដោយម្ចាស់លុះត្រាតែបានបំពេញលក្ខខណ្ឌមួយចំនួន ដូចជា ការចុះកិច្ចសន្យាអាជ្ញាប័ណ្ណជាផ្លូវការ ដែលមានខស្ដីពីការត្រួតពិនិត្យគុណភាព ឬការចុះបញ្ជីកិច្ចសន្យានេះ។ ក្នុងទិដ្ឋភាពនេះ ត្រូវកត់សម្គាល់ថា មាត្រា១៩.២ នៃកិច្ចព្រមព្រៀងTRIPS អនុញ្ញាតជាក់លាក់ឱ្យមានលក្ខខណ្ឌត្រួតពិនិត្យការប្រើប្រាស់ម៉ាករបស់អ្នកទទួលអាជ្ញាប័ណ្ណដោយម្ចាស់ ដើម្បីឱ្យការប្រើប្រាស់នេះមានសុពលភាពសម្រាប់រក្សាការចុះបញ្ជីម៉ាក។

៥.០៣ អានុភាពនៃមាត្រា៥ គឺថា នៅពេលដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ការប្រើប្រាស់ម៉ាកដោយបុគ្គលណាមួយក្រៅពីម្ចាស់ ត្រូវចាត់ទុក ជាការប្រើប្រាស់ម៉ាកដោយម្ចាស់ ឱ្យតែការប្រើប្រាស់នេះមានការយល់ព្រមពីម្ចាស់។ រដ្ឋជាសមាជិកមិនអាចតម្រូវឱ្យមានលក្ខខណ្ឌផ្សេងទៀតដូចជាម្ចាស់ត្រូវត្រួតពិនិត្យការប្រើប្រាស់ម៉ាកទេ។ ជាវិបាក ក្នុងករណីម្ចាស់មិនបានប្រើប្រាស់ម៉ាក ប្រសិនបើ តតិយជនប្រើប្រាស់ម៉ាកនេះ ដោយមានការយល់ព្រមពីម្ចាស់ ម៉ាកនេះមិនអាចត្រូវបានធ្វើមោឃភាពដោយសារមិនប្រើប្រាស់បានឡើយ។ ចំពោះចំណុចនេះ មាត្រា៥ចែងលើសពីមាត្រា១៩.២ នៃកិច្ចព្រមព្រៀងTRIPS។

៥.០៤ ប៉ុន្តែ មាត្រា៥ ដោះស្រាយតែបញ្ហាជាក់លាក់ ក្រោមកាលៈទេសៈណា ការប្រើប្រាស់ដោយរូបវន្តបុគ្គលឬនីតិបុគ្គលក្រៅពីម្ចាស់ អាចត្រូវបានចាត់ទុកជាការប្រើប្រាស់ដោយម្ចាស់។ មាត្រានេះមិនបញ្ជាក់ពីសុពលភាពនៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណជាទូទៅទេ។ ដូច្នេះលទ្ធភាពភាគីហត្ថលេខីដើម្បីទាមទារខគ្រប់គ្រងគុណភាព ដើម្បីឱ្យកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ មានសុពលភាព មិនត្រូវបានប៉ះពាល់ឡើយ។

៥.០៥ មាត្រា៥ អាចអនុវត្តដោយឯករាជ្យ ទោះបីមានឬគ្មានអាជ្ញាប័ណ្ណ ឬ ក្នុងករណីមាន

អាជ្ញាប័ណ្ណ ទោះបានចុះបញ្ជីឬមិនបានចុះបញ្ជីអាជ្ញាប័ណ្ណក៏ដោយ។ ដូច្នេះ គ្រប់គ្រាន់សម្រាប់ម្ចាស់ដើម្បីយល់ព្រមប្រើប្រាស់ម៉ាករបស់ខ្លួន ដើម្បីទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់នេះ នៅពេលណាដែលពាក់ព័ន្ធនឹងបញ្ហានៃការប្រើប្រាស់ ដូចជា ក្នុងបរិបទនៃម៉ាកដែលមានលក្ខណៈញែកដាច់ពីគ្នាឬចាប់ល្បី ឬសម្រាប់គោលបំណងរក្សាការចុះបញ្ជីម៉ាក។ ជាសំខាន់ ការប្រើប្រាស់ម៉ាកណាមួយ ដោយតតិយជនណាម្នាក់ ដែលមានការយល់ព្រមពីម្ចាស់ ត្រូវចាត់ទុកជា ការប្រើប្រាស់ដោយម្ចាស់។

## កំណត់ចំពោះមាត្រា៦

៦.០១ *មាត្រា៦* ទាក់ទងនឹងការចង្អុលបង្ហាញជាក់លាក់ពាក់ព័ន្ធនឹងអាជ្ញាប័ណ្ណម៉ាក ដែលអាចតម្រូវឱ្យមានលើផលិតផល ឬការវេចខ្ចប់ ឬផ្តល់ទំនាក់ទំនងនឹងការផ្តល់សេវា ឬក្នុងការផ្សាយពាណិជ្ជកម្មទំនិញឬសេវា តាមច្បាប់ម៉ាក តាមច្បាប់ស្លាកសញ្ញាទូទៅ ឬតាមច្បាប់ស្តីពីការផ្សាយពាណិជ្ជកម្ម។ មាត្រានេះគ្មានចេតនាធ្វើនិយតកម្មលើបញ្ហាទូទៅនៃព័ត៌មានផលិតផល (ឬសេវា) ដែលតម្រូវដោយច្បាប់ស្តីពីស្លាកសញ្ញា ច្បាប់ស្តីពីការផ្សាយពាណិជ្ជកម្ម ឬច្បាប់ការពារអ្នកប្រើប្រាស់នោះទេ។ ជាវិបាក ច្បាប់និងបទបញ្ញាជាតិ ដែលតម្រូវឱ្យមានការចង្អុលបង្ហាញមួយចំនួនទាក់ទងនឹងសុវត្ថិភាពផលិតផល សមាសធាតុផលិតផល ការប្រើប្រាស់ផលិតផលត្រឹមត្រូវ ។ល។ ដែលត្រូវមានលើការវេចខ្ចប់ ស្ថិតក្រៅវិសាលភាពនៃមាត្រានេះ។

៦.០២ *មាត្រា៦* ទុកឱ្យច្បាប់របស់រដ្ឋជាសមាជិក កំណត់ថាតើទំនិញដែលត្រូវធ្វើពាណិជ្ជកម្មក្រោមម៉ាកដែលផ្តល់អាជ្ញាប័ណ្ណ ឬការវេចខ្ចប់ ត្រូវមានឬគ្មានការចង្អុលបង្ហាញថាម៉ាកត្រូវបានប្រើប្រាស់តាមកិច្ចសន្យាអាជ្ញាប័ណ្ណ ឬថាតើការចង្អុលបង្ហាញនេះមាន ឬគ្មានទំនាក់ទំនងនឹងការផ្តល់សេវា ឬក្នុងការផ្សាយពាណិជ្ជកម្មទំនិញឬសេវានេះ។ ប៉ុន្តែនៅពេលដែលច្បាប់ដែលត្រូវអនុវត្ត តម្រូវឱ្យមានការចង្អុលបង្ហាញនេះ ការមិនអនុលោមតាម កាតព្វកិច្ចនេះមិនគួរបណ្តាលឱ្យមោឃភាពការចុះបញ្ជីម៉ាកទេ។ អត្ថិភាពនៃការចុះបញ្ជី មិនគួរអាស្រ័យលើការបំពេញលក្ខខណ្ឌ ទាក់ទងនឹងស្លាកសញ្ញាឬការផ្សាយពាណិជ្ជកម្ម ដោយមិនគិតថាតើមានលក្ខខណ្ឌទាំងនេះ ក្នុងច្បាប់ម៉ាក ឬក្នុងច្បាប់ផ្សេងទៀតស្តីពីស្លាកសញ្ញា ឬការផ្សាយពាណិជ្ជកម្មនោះឡើយ។ ដោយឡែក (ហើយនេះជាអានុភាពនៃការយោងទៅមាត្រា៥ ដែលមាននៅខាងចុងមាត្រា៦) រដ្ឋជាសមាជិក មិនត្រូវបានអនុញ្ញាតឱ្យលុបចោលការចុះបញ្ជីម៉ាក ដោយ

សារតែការប្រើប្រាស់ម៉ាកនេះដោយ អ្នកទទួលអាជ្ញាប័ណ្ណ មិនបានចង្អុលបង្ហាញអាជ្ញាប័ណ្ណលើទំនិញឬ លើការវេចខ្ចប់ទំនិញ ឬក្នុងទំនាក់ទំនងនឹងការផ្តល់សេវា ឬក្នុងការផ្សាយពាណិជ្ជកម្មទំនិញឬសេវាដែលប្រើប្រាស់ម៉ាក ទោះបីជាមានលក្ខខណ្ឌក្នុងរដ្ឋ ជាសមាជិកក៏ដោយ។ គំនិតជា មូលដ្ឋានគឺថា មោឃភាពការចុះបញ្ជីម៉ាកដែលផ្តល់អាជ្ញាប័ណ្ណ ជាទណ្ឌកម្មដ៏ធ្ងន់ធ្ងរពេក ចំពោះការមិនបំពេញលក្ខខណ្ឌនៃស្លាកសញ្ញាឬការផ្សាយពាណិជ្ជកម្ម ហើយមិនគួរត្រូវបានអនុញ្ញាតទេ។ ជាងនេះទៅទៀត ការមិនអនុលោមតាមបទប្បញ្ញត្តិស្តីពីស្លាកសញ្ញា ឬការផ្សាយពាណិជ្ជកម្ម មិនគួរបន្ថយលទ្ធភាពអនុវត្តសិទ្ធិដែលភ្ជាប់នឹងម៉ាកដែលផ្តល់អាជ្ញាប័ណ្ណឡើយ។ នេះមានន័យថា ការចង្អុលបង្ហាញដែលខុសឬខ្វះចន្លោះនៃអាជ្ញាប័ណ្ណ មិនអាចឱ្យភាគីចុងចម្លើយជំទាស់នឹងបណ្តឹងរំលោភបំពានបានឡើយ ទោះបីជា ការចង្អុលបង្ហាញនេះតម្រូវតាមច្បាប់ដែលអនុវត្តក៏ដោយ។ លទ្ធផលនៃមាត្រា៦ គឺថា គ្មានទណ្ឌកម្មចំពោះការមិនអនុលោមតាមលក្ខខណ្ឌនៃស្លាកសញ្ញាឬការផ្សាយពាណិជ្ជកម្មឡើយ ទោះបីជាលក្ខខណ្ឌដែលទាក់ទងនឹងការចង្អុលបង្ហាញនៃអាជ្ញាប័ណ្ណ អាចធ្វើឱ្យប៉ះពាល់សិទ្ធិម៉ាកក៏ដោយ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

លេខ: ៤៥៧ សហវ.ប្រក.ចមា

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង

## ស្តីពី

## កំណែទម្រង់រដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និង កំណែទម្រង់រដ្ឋបាលពាក់ព័ន្ធនានា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ, និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការ

គ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ

- បានឃើញ ព្រះរាជក្រមលេខ នស/រកប/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើ នៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ប.ក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យ លេខ ៦៤ អនក្រ បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពី ការអនុវត្តច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពី រដ្ឋទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំ លេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- អនុវត្តន៍តាមបទបញ្ជារាជរដ្ឋាភិបាលលេខ ០៤បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រង ចំណូលមិនមែនសារពើពន្ធ
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** : អនុញ្ញាតឱ្យយកកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ដូចជាការបញ្ជាក់ អំពីការប្រើប្រាស់ ឬ មិនប្រើប្រាស់ម៉ាក ការផ្លាស់ប្តូរផ្សេងៗ ការលុបម៉ាកចេញពីបញ្ជី ការចុះបញ្ជីសាឡើងវិញ និង ការបោះពុម្ពផ្សាយ ។

**ប្រការ ២** : ត្រូវបានកំណត់កម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ពន្ធ័នានា ដូចខាងក្រោម :

| ល.រ | ពិពណ៌នា | ឯកត្តា | តម្លៃ (គិតជាប្រាក់រៀល) |
|---|---|---|---|
| | **I- ការចុះបញ្ជីម៉ាក** | | |
| ១- | ការដាក់ពាក្យសុំចុះបញ្ជីម៉ាក | មួយម៉ាក និងមួយជំពូក | ២០.០០០ រៀល |
| ២- | ការចុះបញ្ជីម៉ាក ( សុពលភាព ១០ឆ្នាំ) | មួយម៉ាក និងមួយជំពូក | ១៨០.០០០ រៀល |
| | **II- ការបញ្ជាក់ អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក** | | |
| ៣- | ការដាក់ពាក្យ និង ការបញ្ជាក់ អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| | **III- ការផ្លាស់ប្តូរផ្សេងៗ** | | |
| ៤- | ការកត់ត្រា ការផ្ទេរកម្មសិទ្ធិម៉ាក (Assignment) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| ៥- | ការកត់ត្រា ការប្តូរឈ្មោះ ឬការរួមបញ្ចូលគ្នា នៃម្ចាស់ម៉ាក (Name Change and Merger) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| ៦- | ការកែតម្រូវនានា ( ជាកំហុសរបស់អ្នកដាក់ពាក្យ) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| ៧- | ការកត់ត្រា ការប្តូរឈ្មោះអាសយដ្ឋាន (Address Change) ( ក្នុងករណីប្តូរតែអាសយដ្ឋានមួយប៉ុណ្ណោះ) | មួយម៉ាក និងមួយជំពូក | ៤០.០០០ រៀល |
| | **IV- ការលុបម៉ាក** | | |
| ៨- | ការលុបម៉ាកចេញពីបញ្ជី ( បង់ដោយអ្នកស្នើសុំលុប) | មួយវិញ្ញាបនប័ត្រ | ២០០.០០០ រៀល |

| | | | |
|---|---|---|---|
| | V- **ការចុះបញ្ជីម៉ាកសាឡើងវិញ** | | |
| ៩- | ការដាក់ពាក្យ និងការចុះបញ្ជីម៉ាកសាឡើងវិញ | មួយម៉ាក និងមួយជំពូក | ២០០.០០០ រៀល |
| | VI- **ការបោះពុម្ពផ្សេងទៀត (ប្រសិនជាមាន)** | | |
| ១០- | ទំហំតូចជាង ១/៣ នៃក្រដាស A4 | មួយឯកត្តា | ៤០.០០០ រៀល |
| ១១- | ទំហំ ១/៣ នៃក្រដាស A4 | មួយឯកត្តា | ៨០.០០០ រៀល |
| ១២- | ទំហំ ១/២ នៃក្រដាស A4 | មួយឯកត្តា | ១២០.០០០ រៀល |
| ១៣- | ទំហំ ៣/៤ នៃក្រដាស A4 | មួយឯកត្តា | ២០០.០០០ រៀល |
| ១៤- | ទំហំ A4 | មួយឯកត្តា | ៤០០.០០០ រៀល |

**ប្រការ ៣ :** ក- ការគ្រប់គ្រងចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ត្រូវអនុវត្តតាមនីតិវិធី នៃកិច្ចសហប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ៧៣ គណនី ៧៣០ អនុគណនី ៧៣០៨ ដោយត្រូវបង់ ១០០% ចូលថវិការដ្ឋ ។

ខ- ចំពោះចំណូល ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបង់ចំណូលនេះចូលរតនាគារជាតិ ដោយអនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

គ- ក្រសួងពាណិជ្ជកម្ម ត្រូវបូកសរុបធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

**ប្រការ ៤ :** ការបង់ប្រាក់ និងការទទួលប្រាក់ចំណូលពីកម្រៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ត្រូវអនុវត្ត តាមរយៈរដ្ឋទេយ្យករចំណូលនៅក្រសួងពាណិជ្ជកម្ម។

**ប្រការ ៥ :** ការផ្តល់ប្រាក់ឧបត្ថម្ភដល់ការងារគ្រប់គ្រង និង ប្រមូលចំណូលនេះ នឹងត្រូវរៀបចំប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៦ :** កម្រៃរដ្ឋបាលក្នុងការបោះពុម្ពផ្សាយម៉ាក ដែលបានចុះបញ្ជីរួចហើយ ក្នុងព្រឹត្តិប័ត្រផ្លូវការ នឹងត្រូវកំណត់នៅពេលក្រោយ ។

**ប្រការ ៧ :** បទប្បញ្ញត្តិ ឬ ប្រកាសទាំងឡាយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**<u>ចម្លងជូន:</u>**
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរសវនកម្មជាតិ
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-គ្រប់ខេត្ត-ក្រុង
-ដូចប្រការ ៨ ដើម្បីអនុវត្ត
-ឯកសារ-កាលប្បវត្តិ

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE
នាយកដ្ឋានកម្មសិទ្ធិបញ្ញា
DEPARTMENT OF INTELLECTUAL PROPERTY RIGHTS

KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

# លិខិតទទួលស្គាល់ការដាក់ពាក្យ
## ACKNOWLEDGEMENT OF FILING INSTRUCTION

លិខិតនេះសំរាប់ទទួលស្គាល់ចំពោះការដាក់ពាក្យស្នើសុំ(និងកម្រៃតម្រូវអោយបង់)សំរាប់ការចុះបញ្ជីនៃម៉ាកខាងក្រោម:
Receipt is acknowledged of the application (and the required fee) for the registration of the following mark:

កាលបរិច្ឆេទដាក់ពាក្យ (Filing Date): October 21, 2011

លេខដាក់ពាក្យ (Application Nº): KH/43435/11

singapore sessions APPLIED

ពិពណ៌នាម៉ាក (Mark Description): Singapore sessions

ជំពូក (Class) : 9

អ្នកស្នើសុំ (Applicant) : ECONOMIC DEVELOPMENT BOARD

អាសយដ្ឋាន (Address) : 250 North Bridge Road, #28-00 Raffles City Tower, Singapore 179101

ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានពិចារណាតាមលំដាប់លំដោយហើយលោកអ្នកនឹងត្រូវបានជូនដំណឹងពីការពិនិត្យម៉ាកនេះ។ សូមបញ្ជាក់អោយ
ច្បាស់នូវលេខដាក់ពាក្យ ព្រមទាំងកាលបរិច្ឆេទដាក់ពាក្យ ឈ្មោះអ្នកស្នើសុំ និងម៉ាកនៅពេលមានការសាកសួរអំពីការដាក់ពាក្យស្នើសុំនេះ។
ាល់លិខិតផ្លូវការ និងទំនាក់ទំនងដទៃទៀត ត្រូវតែបញ្ជូនមកនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

'our application will be considered in its order and you will be notified as to the examination thereof. Be sure to ive the Application Number as well as the DATE OF FILING, NAME OF APPLICANT, and MARK when quiring about this application. All official letters and other communications MUST BE ADDRESSED ONLY ): The Department of Intellectual Property Rights.

ាសយដ្ឋានទំនាក់ទំនង:
dress for service:
IATLEGAL/KIMLY IP SERVICE
ey Piphup Thmey, Somrong Andeth No. 22, St. No
Phum Raungchack, Sangkat Phnom Penh Thmey,
n Sen Sok, Phnom Penh, Cambodia

Phnom Penh 19 DEC 2011
ក.ប. ប្រធាននាយកដ្ឋាន
For and on behalf of the Director

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE
នាយកដ្ឋានកម្មសិទ្ធិបញ្ញា
DEPARTMENT OF INTELLECTUAL PROPERTY RIGHTS

KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

# លិខិតទទួលស្គាល់ការដាក់ពាក្យ

## ACKNOWLEDGEMENT OF FILING INSTRUCTION

លិខិតនេះសំរាប់ទទួលស្គាល់ចំពោះការដាក់ពាក្យស្នើសុំ(និងតម្លៃតម្រូវអោយបង់)សំរាប់ការចុះបញ្ជីនៃម៉ាកខាងក្រោម:
Receipt is acknowledged of the application (and the required fee) for the registration of the following mark:

កាលបរិច្ឆេទដាក់ពាក្យ (Filing Date): October 21, 2011

លេខដាក់ពាក្យ (Application N°): KH/43438/11

singapore sessions

PLIED

ពិពណ៌នាម៉ាក (Mark Description): Singapore sessions

ជំពូក (Class) : 36

អ្នកស្នើសុំ (Applicant) : ECONOMIC DEVELOPMENT BOARD

អាសយដ្ឋាន (Address) : 250 North Bridge Road, #28-00 Raffles City Tower, Singapore 179101

ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានពិចារណាតាមលំដាប់លំដោយហើយលោកអ្នកនឹងត្រូវបានជូនដំណឹងពីការពិនិត្យម៉ាកនេះ។ សូមបញ្ជាក់អោយច្បាស់នូវលេខដាក់ពាក្យ ព្រមទាំងកាលបរិច្ឆេទដាក់ពាក្យ ឈ្មោះអ្នកស្នើសុំ និងម៉ាកនៅពេលមានការសាកសួរអំពីការដាក់ពាក្យស្នើសុំនេះ។ រាល់លិខិតផ្លូវការ និងទំនាក់ទំនងដទៃទៀត ត្រូវតែបញ្ជូនមកនាយកដ្ឋានកម្មសិទ្ធិបញ្ញា។

Your application will be considered in its order and you will be notified as to the examination thereof. Be sure to give the Application Number as well as the DATE OF FILING, NAME OF APPLICANT, and MARK when inquiring about this application. All official letters and other communications MUST BE ADDRESSED ONLY TO: The Department of Intellectual Property Rights.

អាសយដ្ឋានទំនាក់ទំនង:
Address for service:
ALIATLEGAL/KIMLY IP SERVICE
Borey Piphup Thmey, Somrong Andeth No. 22, St. No.
, Phum Raungchack, Sangkat Phnom Penh Thmey,
Khan Sen Sok, Phnom Penh, Cambodia.

Phnom Penh......DEC.....2011
ត.ប. ប្រធាននាយកដ្ឋាន
For and on behalf of the Director

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ព.ណ.......

ភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ ២០......

<u>ជម្រាបមក</u>

**លោកនាយកក្រុមហ៊ុន អេចប៊ីអេស**

អាគារពាណិជ្ជកម្មសោម៉ា (ជាន់ទី ៤ និង ៥) ផ្លូវ ១២០
សង្កាត់ ផ្សារថ្មី ២ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ កម្ពុជា

**<u>កម្មវត្ថុ:</u>** ករណីលុបម៉ាក "BULL Device" លេខចុះបញ្ជី ៣៩៣១៨ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងជំពូក ៣២ ក្នុងនាមក្រុមហ៊ុន Medi Plus Tec Medizinisch-Technische Handelsgesellschaft mbH.

**<u>យោង:</u>** - សំណុំឯកសារលេខ KH/E/2011/79062
- ច្បាប់ ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- ឯកសារគាំទ្ររបស់ភាគីវិវាទ។

បានឃើញ

ពាក្យស្នើសុំលុបម៉ាក "BULL Device" លេខចុះបញ្ជី ៣៩៣១៨ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងជំពូក ៣២ ក្នុងនាមក្រុមហ៊ុន Medi Plus Tec Medizinisch-Technische Handelsgesellschaft mbH ដែលបានទទួលនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ ។ ពាក្យស្នើសុំនេះ បានធ្វើឡើងក្នុងនាមក្រុមហ៊ុន Carabao Tawandang Co., Ltd ជា (**ភាគីដើមចោទ**) មាន ទីស្នាក់ការ 462/59 Nang Linchee Rd, Chong Nonsi, Yanawa, Bangkok 10120, Thailand ដែលតំណាងដោយក្រុមហ៊ុន Tang Seng Huot International Co., Ltd មានអាសយដ្ឋាន ផ្ទះលេខ ១១ ផ្លូវ ២០១ សង្កាត់ ទួលស្វាយ ព្រៃ ២ ខណ្ឌ ចំការមន រាជធានីភ្នំពេញ កម្ពុជា តាមរយៈលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១។

ភាគីក្រុមហ៊ុន Medi Plus Tec Medizinisch-technische Handelsgesellschaft mbH មានទីស្នាក់ការ Baerler Strasse 100, Moers, Germany ដែលតំណាងដោយក្រុមហ៊ុន មេធាវី អេចប៊ីអេស មានទីស្នាក់ការ អាគារសោម៉ា (ជាន់ទី ៤ និង ៥) ផ្លូវ ១២០ សង្កាត់ ផ្សារថ្មី ២ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ កម្ពុជា តាមរយៈលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ ជា (**ភាគីចុងចម្លើយ**)។

ដោយ

- ពាក្យស្នើសុំលុបម៉ាកនេះ បានធ្វើឡើងស្របតាមមាត្រា ១៣ នៃច្បាប់ ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ...

ក្រសួងពាណិជ្ជកម្ម បានយល់ព្រមទទួលយកមកពិចារណា ។

- តាមនីតិវិធីជាត់ការលើពាក្យបណ្ដឹងនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម បានជូនដំណឹងទៅគូភាគី ដោយតម្រូវអោយផ្ដល់ទឡ្ហីករណ៍ និងឯកសារគាំទ្រ ដើម្បីដាក់បន្ទុក និងដោះបន្ទុក តាមរយៈលិខិតលេខ ១២៨/០១/B/L/IPR ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ហើយតាមការស្នើសុំពន្យារពេលពីភាគីចុងចម្លើយ នាយកដ្ឋានបានពន្យារពេលក្នុងការផ្ដល់ឯកសារគាំទ្រចំនួន៨៥ថ្ងៃបន្ថែមទៀតជូនភាគីចុងចម្លើយ តាមរយៈលិខិតលេខ ១៣៥/០៣/B/L/IPR ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២ ។ ក្រោយពីបានទទួល និងសិក្សាលើឯកសារគាំទ្រដែលបានផ្ដល់ដោយភាគីទាំងពីរ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានចេញលិខិតលេខ ១៤៧/០៥/B/L/IPR ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ អញ្ជើញភាគីចុងចម្លើយមកបំភ្លឺបន្ថែម ។ នាយកដ្ឋានកម្មសិទ្ធិបញ្ញាបានពិនិត្យលើការបំភ្លឺ និងឯកសារដែលពាក់ព័ន្ធឃើញថា ក្បាលគោនៃម៉ាក "BULL Device" មានលក្ខណៈស្រដៀងនាំឲ្យភ័ន្តច្រឡំនឹងក្បាលក្របីនៃម៉ាក "Carabao & Device" ទើបនាយកដ្ឋានបានសម្រេចចេញលិខិតលេខ ១៥០/០៧/B/L/IPR ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១២ អញ្ជើញភាគីចុងចម្លើយឲ្យមកធ្វើការកែតម្រូវម៉ាក "BULL Device" សាជាថ្មី ក្នុងរយៈពេល៣០ថ្ងៃ ។ ឆ្លើយតបនឹងការតម្រូវឲ្យកែតម្រូវខាងលើភាគីចុងចម្លើយបានឯកភាពកែតម្រូវ ប៉ុន្តែបានស្នើសុំពន្យារពេលក្នុងការមកកែតម្រូវម៉ាករបស់ខ្លួនក្នុងរយៈពេល៣០ថ្ងៃបន្ថែមទៀត នាយកដ្ឋានបានឯកភាពពន្យារពេលជូនភាគីចុងចម្លើយតាមរយៈលិខិតលេខ ១៦១/០៨/B/L/IPR ចុះថ្ងៃ ទី ១៤ ខែ សីហា ឆ្នាំ ២០១២។ ជាការឆ្លើយតបនឹងការបន្តស្នើសុំពន្យារពេលក្នុងការកែតម្រូវម៉ាករបស់ភាគីចុងចម្លើយ ក្នុងរយៈពេល៣ខែបន្ថែមទៀតនោះ នាយកដ្ឋានបានពិនិត្យឃើញថា ការដែលនៅតែបន្តពន្យារទៅទៀត នឹងអាចធ្វើឲ្យខូចផលប្រយោជន៍ដល់ភាគីដែលពាក់ព័ន្ធ ទើបនាយកដ្ឋានធ្វើការបដិសេធក្នុងការពន្យារបន្តទៀត ដោយបានបញ្ជាក់ថា នាយកដ្ឋាននឹងពិនិត្យសម្រេចលើករណីនេះក្នុងរយៈពេលមួយសប្ដាហ៍ តាមរយៈលិខិតលេខ ១៦៨/០៩/B/L/IPR ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២។

- ក្រុមហ៊ុន Tang Seng Huot International Co., Ltd បានផ្ដល់សំណុំឯកសារគាំទ្របញ្ជាក់ថា ភាគីដើមចោទបានចុះបញ្ជីការពារម៉ាក "Carabao & Device" ក្នុងជំពូក ៣២ សម្រាប់ផលិតផលភេសជ្ជៈប៉ូវកម្លាំងជាលើកដំបូងនៅប្រទេសអូស្ត្រាលីចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ និងនៅបណ្ដាប្រទេសមួយចំនួនផ្សេងទៀតជាបន្តបន្ទាប់ រួមមាន សហរដ្ឋអាមេរិក កាណាដា OHIM ស្វីស ញូស៊ីឡែន ជប៉ុន ចិន សិង្ហបុរី វៀតណាម និង កម្ពុជា ឆ្នាំ ២០០៤ ហើយឯកសារទាំងនេះ ក៏បានបញ្ជាក់ផងដែរថា ម៉ាកនេះបានកំពុងតែប្រើប្រាស់ក្នុងទីផ្សារកម្ពុជា ដែលរហូតមកទល់នឹងពេលនេះមានរយៈពេល ៩ ឆ្នាំ មកហើយ ។ម្យ៉ាងទៀត ផលិតផលម៉ាក "Carabao & Device" បាននាំមកប្រទេសកម្ពុជា តាមរយៈក្រុមហ៊ុន Tang Seng Huot International Co., Ltd ដែលជាភ្នាក់ងារនាំចូល និងចែកចាយផ្ដាច់មុខតែមួយគត់ ។

- ក្រុមហ៊ុនមេធាវី អេចប៊ីអេស បានផ្ដល់សំណុំឯកសារគាំទ្របញ្ជាក់ថា ភាគីចុងចម្លើយបានចុះបញ្ជីម៉ាក "BULL Device" ជាលើកដំបូង នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩

នៅប្រទេសអាល្លឺម៉ង់សម្រាប់ផលិតផលក្នុងជំពូក ១៤ ១៦ ១៨ ២១ ២៥ ៣២ ៣៣ និង ៣៤ និងនៅបណ្តាប្រទេសផ្សេងទៀតដូចជា លីបង់ អាហ្គានីស្ថាន កម្ពុជា ឆ្នាំ ២០១១ និងអង្គការកម្មសិទ្ធិបញ្ញាអាហ្វ្រិក ។ លើសពីនេះ នៅមានឯកសារមួយចំនួនទៀតក៏បានបង្ហាញអំពីការផ្សព្វផ្សាយ និងការប្រើប្រាស់ម៉ាកនេះរបស់ភាគីចុងចម្លើយផងដែរ ។

- បានពិនិត្យឃើញថា ម៉ាក "BULL Device" របស់ភាគីចុងចម្លើយដែលបានចុះបញ្ជីរួចនៅកម្ពុជា មានតែរូបក្បាលគោដែលជាធាតុសំខាន់ ចំណែកម៉ាក "Carabao & Device" របស់ភាគីដើមបណ្តឹងដែលបានធ្វើការចុះបញ្ជីនៅកម្ពុជាមុន ដែលមានធាតុសំខាន់គឺរូបក្បាលក្របីនៅក្នុងរង្វង់មូល និងពាក្យ Carabao ។ ម៉ាករបស់ភាគីទាំងពីរត្រូវបានប្រើប្រាស់សម្រាប់ផលិតផលក៏ដូចគ្នាទៀតផង។ ភាពស្រដៀងគ្នានៃម៉ាកទាំងនេះពិតជានឹងអាចកើតឡើងដោយសារភាពរំលេចនៃនិមិត្តសញ្ញាក្បាលគោ និងក្បាលក្របីនៃម៉ាកទាំងពីរ ដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំង ដែលបណ្តាលអតិថិជនមានការភាន់ច្រឡំ ។ ការភាន់ច្រឡំទាំងនេះ បាននាំឲ្យការចុះបញ្ជីម៉ាក "BULL Device" មិនអាចបំពេញតួនាទីជាម៉ាកក្នុងការញែកផលិតផលរបស់ខ្លួនឲ្យដាច់ចេញពីផលិតផលរបស់ភាគីដើមចោទបានឡើយ ហើយសាធារណជនប្រាកដជាយល់ច្រឡំក្នុងការជ្រើសរើស និងយល់ថាផលិតផលដែលពាក់ម៉ាកទាំងពីរចេញមកពីប្រភពតែមួយ ឬក្រុមហ៊ុនតែមួយ ។ ដូច្នេះការចុះបញ្ជីម៉ាក "BULL Device" ក្នុងនាមភាគីចុងចម្លើយបានធ្វើឡើងមិនអាចបំពេញលក្ខខ័ណ្ឌនៃច្បាប់ម៉ាកត្រង់ មាត្រា២(ក) និងមាត្រា៤ បានឡើយ។ ម្យ៉ាងវិញទៀតនៅពេលចុះបញ្ជី ម៉ាក "BULL Device" មានតែនិមិត្តសញ្ញាក្បាលគោប៉ុណ្ណោះ ប៉ុន្តែនៅក្នុងដំណាក់កាលនៃការប្រើប្រាស់បែរជាភាគីចុងចម្លើយបានប្រើប្រាស់ម៉ាក ដោយរចនាបន្ថែមនូវនិមិត្តសញ្ញានៅលើសំបកវេចខ្ចប់ផលិតផលខុសពីការចុះបញ្ជី ។ ការរចនានិមិត្តសញ្ញាបន្ថែមទាំងនេះ អាចនាំឲ្យភាន់ច្រឡំទៅនឹងនិមិត្តសញ្ញានៃម៉ាក "Carabao & Device" ដែលត្រូវបានហាមឃាត់ ដូចមានចែងក្នុងមាត្រា ២៤(៣) នៃអនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ហើយភាគីចុងចម្លើយក៏បានខកខានមិនបានធ្វើការកែតម្រូវម៉ាករបស់ខ្លួន តាមការតម្រូវរបស់នាយកដ្ឋាន ។ លើសពីនេះ បើធ្វើការប្រៀបធៀបតុល្យភាពនៃកិច្ចប្រឹងប្រែងរបស់ភាគីទាំងពីរ លើម៉ាកទាំងពីរនេះ បានបង្ហាញឲ្យឃើញថា ភាគីដើមចោទបានវិនិយោគមានវិសាលភាពធំ និងយូរជាងភាគីចុងចម្លើយ ហើយបើពិនិត្យលើការចុះបញ្ជី និងវត្តមាននៃប្រើប្រាស់យូររបស់ភាគីដើមចោទនៅកម្ពុជា ភាគីចុងចម្លើយពិតជាបានដឹងច្បាស់អំពីប្រភព និងភាពជាម្ចាស់នៃម៉ាក "Carabao & Device" យ៉ាងពិតប្រាកដ ។

ដោយឡែក នៅក្នុងដំណាក់កាលនៃការស្នើសុំចុះបញ្ជី ភាគីចុងចម្លើយបានធ្វើការសន្យាជាលាយលក្ខណ៍អក្សរថា ប្រសិនបើ មានភាគីដែលពាក់ព័ន្ធណាមួយស្នើសុំលុបការចុះ

បញ្ជីនៃម៉ាក "BULL Device" នេះចេញពីបញ្ជី នោះភាគីចុងចម្លើយឯកភាពឲ្យធ្វើការលុបដោយមិនធ្វើការតវ៉ាណាមួយឡើយ។

ដូច្នេះ ទាំងការចុះបញ្ជី ទាំងការប្រើប្រាស់ម៉ាក "BULL Device" របស់ភាគីចុងចម្លើយ បានធ្វើឡើងមានលក្ខណៈស្រដៀងនាំឲ្យភ័ន្តច្រឡំទៅនឹងម៉ាក "Carabao & Device" ក្នុងបំណងដើម្បីទាញយកផលប្រយោជន៍ពីភាពល្បីរបស់ភាគីដើមចោទ។

ពាក្យស្នើសុំលុបម៉ាកនេះ មានភ្ជាប់នូវឯកសារពាក់ព័ន្ធ និងបានផ្តល់នូវមូលដ្ឋានផ្លូវច្បាប់ ដែលអាចសម្រេចដាក់ចេញនូវបញ្ហាលុបម៉ាកនេះបាន។

ដោយអនុលោមមាត្រា ២៨(៣) នៃអនុក្រឹត្យ និងមាត្រា ១៣ និងមាត្រា ១៤(ច) នៃច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

## **សម្រេច**

ម៉ាក "BULL Device" លេខចុះបញ្ជី ៣៩៣១៨ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក្នុងជំពូក ៣២ ក្នុងនាមក្រុមហ៊ុន Medi Plus Tec Medizinisch-Technische Handels gesellschaft mbH ត្រូវបានលុបចេញពីបញ្ជីម៉ាក ។ ការលុបម៉ាកចេញពីបញ្ជីនេះ ត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី។

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម